សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

Universite’ Royale de droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការកាត់កាល់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ : លោក **ទួន តារាម្យ**

លោក **បឿន វណ្ណឌី**

សាស្រ្តាចារ្យណែនាំ

លោក **គង់ សុភ័ក្រ្ត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **នួន តារម្យ** និង ខ្ញុំបាទ **មឿន វណ្ណឌី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៣-២០១៧ សូមសម្តែងនូវកតញ្ញូតាធម៌ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

សូមលើកអញ្ជលីលំឱនកាយវាចាចិត្តគោរពដល់ ៖

- **លោកឪពុក នួន ធីរ៉ូ**
- **លោកឪពុក មឿន វណ្ណៈ**
- **អ្នកម្តាយ កែន ផល្លី**
- **អ្នកម្តាយ ខួន លាភយាង**
- **ក្រុមគ្រួសារបងប្រុស ជុង សុខចេង**

ដែលបានផ្តល់កំណើត ផ្តល់សេចក្តីស្រលាញ់ ផ្តល់ជំបូន្មាន ផ្តល់ការអប់រំ និងបានជួយឧបត្ថម្ភគាំទ្រផ្នែកថវិកា ការលើកទឹកចិត្ត និងជំរុញស្មារតី ដើម្បីផ្តល់ជាមធ្យោបាយឲ្យ យើងខ្ញុំបានក្រេបជញ្ជក់យកនូវចំណេះដឹង រហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយទេពកោសល្យដ៏ប៉ិនប្រសប់គ្មានគូប្រៀបរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ទាំងលើសមរភូមិការទូត និងអន្តរជាតិ ទាំងលើសមរភូមិសេដ្ឋកិច្ច និងសង្គមកិច្ចទាំងលើសមរភូមិការពារអធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាហេតុបានផ្តល់នូវសន្តិភាព ជាឱកាសឲ្យយើងខ្ញុំបានសិក្សាក្រេបយកចំណេះវិជ្ជា ដើម្បីជាស្ពានឈានទៅ អនាគត។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យ យើងខ្ញុំបានចូលសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។

**លោកសាស្ត្រាចារ្យ គង់ សុភ័ក្រ្ត** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មមាញឹកក្នុងការបង្ហាត់បង្ហាញផ្តល់ការណែនាំ ថែមទាំងបានផ្តល់នូវឯកសារមួយចំនួនដល់យើងខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

**សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ** ទាំងអស់ឲ្យជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការធានានាឧត្តមប្រយោជន៍ និងកិច្ចការពារកុមារ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នាដែលត្រូវគិតគូរឲ្យកុមារ មានការរីកចម្រើនធំធាត់ និងអភិវឌ្ឍន៍នៅក្នុងគ្រួសារមួយដ៏ល្អប្រកបដោយភាពកក់ក្ដៅ និងគ្មានការបំពានសិទ្ធិ។ ផ្ទុយមកវិញ បើការទុកដាក់កុមារនៅក្នុងគ្រួសារមួយ ដែលមិនមានលក្ខណៈសមស្រប វានឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កុមារ ដែលជាកត្តានាំឲ្យជះឥទ្ធិពលដល់សង្គមនាពេលអនាគត ព្រោះថាកុមារជាសរសរទ្រូង សម្រាប់ស្ទួងប្រទេសជាតិ។

ដោយមើលឃើញ នូវសារៈប្រយោជន៍ទាក់ទងនឹងការទុកដាក់កុមារ នៅក្នុងគ្រួសារនេះហើយ ទើបក្រុមរបស់យើងខ្ញុំបានជ្រើសរើសយកប្រធានបទពាក់ព័ន្ធ "**ការកាត់កាល់**" ដែលគួរឲ្យមានការចាប់អារម្មណ៍ មិនថាតែរដ្ឋាភិបាលក៏បានខិតខំបង្កើតច្បាប់ជាតិ អនុក្រឹត្យ ឬបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធទៅនឹងការកាត់កាល់នេះ ។ ទន្ទឹមនឹងគ្នានេះផងដែល យើងខ្ញុំ រួមជាមួយសាស្ត្រាចារ្យទាំងអស់ ពិតជាបានកំពុងយកចិត្តទុកដាក់លើបញ្ហាកាត់កាល់នេះ ឲ្យកាន់តែស៊ីជម្រៅ និងអនុវត្តបាន ជាបន្តបន្ទាប់ ដើម្បីឲ្យមានភាពស៊ីចង្វាក់ សមស្របជាមួយការអភិវឌ្ឍនៃសង្គមឥតឈប់ឈរ។

ពួកយើងសង្ឃឹមយ៉ាងមុតមាំថាប្រធានបទនេះ ក៏អាចស្រាយចម្ងល់ និងជាប្រទីបដល់បងប្អូននិស្សិត ក៏ដូចជាប្រជាពលរដ្ឋ សម្រាប់ការសិក្សាស្រាវជ្រាវ ចង់យល់ឲ្យច្បាស់ពីបញ្ហាកាត់កាល់នេះ ស្របពេលដែលយើងកំពុងតែមានចម្ងល់ថា តើការកាត់កាល់ជាអ្វី ? តើវាអាចមានអានុភាពអនុវត្តចំពោះនរណាខ្លះ? ហើយការអនុវត្តស្ថិតនៅក្នុងស្ថានភាពយ៉ាងដូចម្ដេច និងអាចមានគុណសម្បត្តិ គុណវិបត្តិអ្វីខ្លះ? ជាមួយគ្នានេះដែល យើងខ្ញុំសូមអភ័យទោសលើរាល់កំហុសឆ្គង ដែលកើតឡើងដោយអចេតនា នូវរាល់ពាក្យពេជន៍ និងខ្លឹមសារដែលមានភាពខុសឆ្គង ឬមិនទាន់គ្រប់គ្រាន់ជាដើម។

ជាចុងក្រោយយើងខ្ញុំសូមគោរពជូនពរដល់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក៏ដូចជាបងប្អូនមិត្តនិស្សិតគ្រប់ជំនាន់ឲ្យមានសុខភាពល្អ សំណាងល្អ ជាពិសេសជួបប្រកបនូវពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូក១.មូលហេតុនៃការកាត់កាល់ និងអ្នកមានសិទ្ធិ**

**ផ្នែកទី១. មូលហេតុ និងអ្នកមានសិទ្ធិកាត់កាល់កូនសុំធម្មតា** ........ ៦

**កថាខណ្ឌទី១ .ការកាត់កាល់សុំកូនធម្មតាដោយការព្រមព្រៀង និងអ្នកមានសិទ្ធិ** ........ ៦

ក.ករណីកូនសុំជានីតិជន ........ ៦

ក.១. ការព្រមព្រៀងរវាងភាគីសុំកូន ........ ៦

ក.២. អ្នកមានសិទ្ធិកាត់កាល់ ........ ៧

ខ.ករណីកូនសុំជាអនីតិជន ........ ៧

ខ.១. ការព្រមព្រៀងរវាងភាគីឪពុកម្តាយចិញ្ចឹម និងអ្នកតំណាងដែលច្បាប់កំណត់របស់កូនសុំ .. ៧

ខ.២.អ្នកមានសិទ្ធិកាត់កាល់ ........ ៨

**កថាខណ្ឌទី២. មូលហេតុដែលកំណត់ដោយច្បាប់ និងអ្នកមានសិទ្ធិ** ........ ៨

ក.មូលហេតុដែលកំណត់ដោយច្បាប់ ........ ៨

ក.១.ភាគីម្ខាងនៃសុំកូនបានបោះបង់ភាគីម្ខាងទៀតដោយគំនិតទុច្ចរិត ........ ៩

ក.២. ភាពមិនច្បាស់លាស់នៃការនៅរស់របស់ភាគីសុំកូន ........ ៩

ក.៣.មូលហេតុធ្ងន់ធ្ងរដែលជាហេតុធ្វើឲ្យពិបាកក្នុងការបន្តសុំកូន ........ ៩

ខ.អ្នកមានសិទ្ធិកាត់កាល់ដោយមូលហេតុកំណត់ដោយច្បាប់ ........ ១០

ខ.១.ករណីកូនសុំជានីតិជន ........ ១០

ខ.២.ករណីកូនសុំជាអនីតិជន ........ ១០

**ផ្នែកទី២. ការកាត់កាល់សុំកូនពេញលេញ** ........ ១១

**កថាខណ្ឌទី១.មូលហេតុនៃការកាត់កាល់សុំកូនពេញលេញ** ........ ១១

ក.ការបំពានប្រយោជន៍របស់កូនសុំ ........ ១១

ខ.លទ្ធភាពរបស់ឪពុកម្តាយបង្កើត ........ ១២

**កថាខណ្ឌទី២.អ្នកមានសិទ្ធិកាត់កាល់សុំកូនពេញលេញ** ........ ១៣

ក.កូនសុំ ........ ១៣

ខ.ឪពុកម្តាយបង្កើត ........ ១៣

គ.តំណាងអយ្យការ ........ ១៣

## ជំពូកទី២.នីតិវិធីនៃការកាត់កាល់

**ផ្នែកទី១.នីតិវិធីមុនការជម្រះក្តី និងសមត្ថកិច្ចសាលាជម្រះក្តី** ........ ១៥

**កថាខណ្ឌទី១.ពាក្យសុំកាត់កាល់** ........ ១៥

ក.ទម្រង់នៃពាក្យសុំ ........ ១៥

ខ.ប្រាក់ប្រដាប់ក្តី ........ ១៦

គ.សមត្ថកិច្ចនៃសាលាជម្រះក្តី ........ ១៧

**កថាខណ្ឌទី២.ពាក្យបណ្តឹងកាត់កាល់** ........ ១៧

ក.ទម្រង់នៃពាក្យបណ្តឹង ........ ១៧

ខ.ប្រាក់ប្រដាប់ក្តី ........ ១៨

គ.សមត្ថកិច្ចសាលាជម្រះក្តី ........ ១៩

**ផ្នែកទី២.នីតិវិធីនៃការជម្រះក្តី** ........ ២០

**កថាខណ្ឌទី១.នីតិវិធីនៃការជម្រះក្តីតាមរយៈពាក្យសុំ** ........ ២០

ក.ការសម្រេចសេចក្តីដោយមិនឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ ........ ២០

ខ.ការសម្រេចសេចក្តីដោយឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ ........ ២០

**កថាខណ្ឌទី២.នីតិវិធីជម្រះក្តីតាមរយៈពាក្យបណ្តឹង** ........ ២១

ក.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ........ ២១

ខ.នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........ ២២

ខ.១.ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន ........ ២៣

ខ.២.ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៣

**ផ្នែកទី៣.សេចក្តីសម្រេចកាត់កាល់** ........ ២៤

**កថាខណ្ឌទី១.ការសម្រេចសេចក្តីកាត់កាល់ដោយដីកាសម្រេច** ........ ២៤

ក.សេចក្តីសម្រេចនៃពាក្យសុំកាត់កាល់ ........ ២៤

ខ.បណ្តឹងជំទាស់លើដីកាសម្រេច ........ ២៥

ខ.១ .ថេរវេលាក្នុងការធ្វើបណ្ដឹងជំទាស់ ............ ២៥
ខ.២.នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ ............ ២៥
**កថាខណ្ឌទី២.ការសម្រេចសេចក្តីកាត់កាល់ដោយសាលក្រម ឬសាលដីកា ............ ២៦**
ក.សាលក្រមនៃពាក្យបណ្ដឹងកាត់កាល់ ............ ២៦
ខ.បណ្តឹងឧបាស្រ័យ ............ ២៦

## ជំពូក៣.អានុភាពនៃការកាត់កាល់

**ផ្នែកទី១.ញាតិភាព ............ ២៨**
**កថាខណ្ឌទី១.ញាតិភាពនៃសុំកូនធម្មតា ............ ២៨**
ក.ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត ............ ២៨
ខ.ញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ............ ២៩
**កថាខណ្ឌទី២.ញាតិភាពនៃសុំកូនពេញលេញ ............ ២៩**
ក.ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ............ ២៩
ខ.ញាតិភាពនៃកូនសុំ និងឪពុកម្តាយចិញ្ចឹម ............ ៣០
**ផ្នែកទី២.សន្តតិកម្ម ............ ៣១**
**កថាខណ្ឌទី១.កូនសុំធម្មតា ............ ៣១**
**កថាខណ្ឌទី២.សុំកូនពេញលេញ ............ ៣១**
**ផ្នែកទី៣.សិទ្ធិ និងករណីយកិច្ចផ្សេងៗទៀត ............ ៣២**
**កថាខណ្ឌទី១.អាហារកាតព្វកិច្ច ............ ៣២**
**កថាខណ្ឌទី២.អំពើរអនីត្យានុកូល និងអភ័យឯកសិទ្ធិគ្រួសារ ............ ៣៣**
ក.អំពើរអនីត្យានុកូល ............ ៣៣
ខ.អភ័យឯកសិទ្ធិគ្រួសារ ............ ៣៣
**សេចក្តីសន្និដ្ឋាន ............ ៣៤**
**អនុសាសន៍ ............ ៣៦**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នបញ្ហាកាត់កាល់ គឺស្ថិតនៅក្នុងភាពមិនច្បាស់លាស់នៅឡើយ នៅក្នុងផ្នត់គំនិតរបស់ប្រជាពលរដ្ឋយើង ។ ប្រជាពលរដ្ឋខ្លះមិនទាន់បានជ្រាបច្បាស់អំពីអ្វីទៅជាការកាត់កាល់ និងការកាត់កាល់អាចធ្វើបានក្នុងស្ថានភាពបែបណាខ្លះ ទាំងនេះគឺសុទ្ធតែតម្រូវអោយមានការបកស្រាយពន្យល់ ព្រមទាំងបង្ហាញទៅកាន់សាធារណជនអោយបានយល់ច្បាស់ ។ ការកាត់កាល់នៅក្នុងផ្នត់គំនិតប្រជាពលរដ្ឋបច្ចុប្បន្ន គឺជាការកាត់ផ្តាច់ទំនាក់ទំនងរវាងពួកគាត់ដែលជាឪពុកម្តាយជាមួយកូនរបស់ពួកគាត់ដោយហេតុផលណាមួយសមស្រប ដូចជាកូនអកតញ្ញូ មិនដើរតាមគន្លងធម៌ មិនស្តាប់ដំបូន្មាន មិនបានជួយកិច្ចការងារឬមិនខិតខំសិក្សារៀនសូត្រ បានប្រព្រឹត្តអំពើមិនល្អក្នុងសង្គម ជាដើម។ល។ ជារឿយយើងទាំងអស់គ្នាតែងឃើញប្រជាពលរដ្ឋលោកបានធ្វើការកាត់កាល់កូនរបស់ខ្លួនតាមរយៈបណ្តាញសារព័ត៌មាន ដូចជាកាសែត ទស្សនាវដ្តី ហើយខ្លះទៀតគឺធ្វើឡើងតាមការបង្ហោះ តាមបណ្តាញទំនាក់ទំនងសង្គម(ហ្វេសប៊ុក) ក្នុងគោលបំណងចង់ផ្តាច់នូវទំនាក់ទំនងញាតិ និងរួចផុតពីទំនួលខុសត្រូវផ្សេងៗ ដែលបណ្តាលមកពីអំពើអនីត្យានុកូលរបស់កូនខ្លួន ។ នៅក្នុងអត្ថន័យនេះ ការកាត់កាល់តាមរយៈបណ្តាញសារព័ត៌មាន ដូចជាកាសែត ទស្សនាវដ្តី ឬតាមរយៈបណ្តាញទំនាក់ទំនងសង្គម(ហ្វេសប៊ុក)គឺពុំមានអនុភាពគតិយុត្តសម្រាប់អនុវត្តនោះទេ ។ នៅក្នុងន័យនេះ គឺបានបង្ហាញថាប្រជាពលរដ្ឋកម្ពុជាភាគច្រើនពុំបានយល់ច្បាស់អំពីការកាត់កាល់ ដែលត្រឹមត្រូវតាមច្បាប់ ឬហៅម្យ៉ាងទៀតថាការកាត់កាល់ដែលច្បាប់ទទួលស្គាល់នោះទេ ប្រការនេះ គឺវាធ្វើអោយមានភាពមិនច្បាស់លាស់ស្របពេលដែលច្បាប់បានកំណត់រួចហើយ។

ក៏ប៉ុន្តែបើយើងក្រឡេកទៅមើលពាក្យកាត់កាល់ ត្រូវបានគេកំណត់និយមន័យ ខុសៗគ្នាទៅតាមសម័យកាល និងបរិបទនៃសង្គមផ្សេងៗគ្នាៗ តួយ៉ាង៖

បើយោងតាមវចនានុក្រមនៃសម្តេចសង្ឃរាជ **ជួន ណាត**[1] បានកំណត់និយមន័យនៃពាក្យកាត់កាល់ ថាកាត់កាល់ មានថ្នាក់ពាក្យកិរិយាស័ព្ទ មានន័យថាបោះបង់លែងរាប់អានតទៅទៀត ។

ចំណែកសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់ឆ្នាំ ១៩២០ បានឲ្យនិយមន័យពាក្យកាត់កាល់ មានន័យថា បដិសេធជនណាម្នាក់ ឬច្រើននាក់មិនឲ្យមានសិទ្ធិទទួលមត៌កនៃខ្មោច ។

[1] វចនានុក្រមនៃសម្តេចសង្ឃរាជ **ជួន ណាត** ភាគ១និងភាគ២ បោះពុម្ពឆ្នាំ១៩៦៧

ហើយបើយោងទៅតាម សន្ទានុក្រមច្បាប់របស់ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** [2] បានកំណត់និយមន័យនៃពាក្យកាត់កាល់ថា ការកាត់កាល់គឺជាការដកសិទ្ធិពីទាយាទ ដែលត្រូវទទួលមរតកលែងឲ្យមានសិទ្ធិទទួលមរតកវិញ ។ ការកាត់កាល់ មានន័យថាបដិសេធជនណាម្នាក់ ឬច្រើនអ្នកមិនឲ្យមានសិទ្ធិទទួលមរតក ។ កាត់កាល់ ជនណាម្នាក់ពុំមែនមានសេចក្តីថា លុបអត្រានុកូលដ្ឋាន ឬយកសំបុត្រកំណើតជននោះមកលុបចោលទេ គឺមានន័យថាបោះបង់លែងរាប់អាន មិនឲ្យមានសិទ្ធិទទួលមរតក ។

តែបើយោងតាមវចនានុក្រមច្បាប់អង់គ្លេស-ខ្មែរ របស់អង្គការមូលនិធិអាស៊ី[3] បោះពុម្ពឆ្នាំ១៩៩៧ បានកំណត់និយមន័យការកាត់កាល់ថា ការកាត់កាល់មាននៅក្នុងច្បាប់ទ្រព្យសម្បត្តិកម្ពុជា គឺជាការដកហូតសិទ្ធិពីទាយាទ ដែលត្រូវទទួលមតិកដែលច្បាប់ផ្តល់ឲ្យមិនឲ្យទទួលមតិកនោះវិញ ។ ការកាត់កាល់ បណ្តាលមកពីមានពាក្យបញ្ញត្តិក្នុងមតិកសាសន៍មិនឲ្យទាយាទនោះទទួលបានមតិក ។

ក៏ប៉ុន្តែបើយើងក្រឡេកទៅមើល និយមន័យដោយយោងទៅតាម ស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧បានកំណត់និយមន័យ[4]នៃពាក្យកាត់កាល់ថា ៖ ការកាត់កាល់ គឺជាហេតុនៃការបញ្ចប់នូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលហេតុនាំឲ្យការកាត់ផ្តាច់នូវទំនាក់ទំនងនូវសិទ្ធិ និងកាតព្វកិច្ច ដូចជាអាហារកាតព្វកិច្ច[5] និងសន្តតិកម្ម[6]ជាដើម ។

មួយវិញទៀតក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ នៅឆ្នាំ ២០០៧ បានបញ្ញត្តិទាក់ទងនឹងប្រភេទនៃការកាត់កាល់មាន២ ៖គឺ. ការកាត់កាល់សុំកូនពេញលេញ និងការកាត់កាល់សុំកូនធម្មតា ដោយមិនបានកំណត់អំពី ការកាត់កាលកូនបង្កើតនោះទេ នេះបង្ហាញថាច្បាប់មិនបានអនុញ្ញាតអោយធ្វើការកាត់កាល់កូន បង្កើតនោះទេ ហើយការកាត់កាល់លើកូនសុំទាំងពីរប្រភេទខាងលើនេះ គឺមានបែបបទ និងនីតិវិធី ច្បាស់លាស់ដែលបានកំណត់ក្នុងច្បាប់ ដោយត្រូវធ្វើឡើងតាមរយៈតុលាការដែលមានសមត្ថកិច្ច និងសម្រេចអំពីការកាត់កាល់តាមរយៈសេចក្តីសម្រេច (ដីកាសម្រេច ឬ សាលក្រម) នៃតុលាការ ដែលមានសមត្ថកិច្ចនោះ ។

[2] សន្ទានុក្រមច្បាប់របស់ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** បោះពុម្ពលើកទី៣ ឆ្នាំ២០១០
[3] វចនានុក្រមច្បាប់អង់គ្លេស-ខ្មែរ របស់អង្គការមូលនិធិអាស៊ី បោះពុម្ពឆ្នាំ១៩៩៧
[4] មាត្រា៩៨២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[5] អាហារកាតព្វកិច្ច៖ ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់មានកាតព្វកិច្ចជាមួយ បុគ្គលម្នាក់ឬច្រើននាក់ផ្តល់នូវទ្រព្យ ឬប្រាក់ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ។
[6] សន្តតិកម្ម៖ ជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជន ទៅឲ្យសន្តតិជនម្នាក់ឬច្រើននាក់ តាមឆន្ទះ ឬតាមច្បាប់។

ដូចនេះហើយដើម្បីធ្វើការដោះស្រាយនូវបញ្ហាអវិជ្ជមានទាំងនេះ យើងខ្ញុំទាំងពីរនាក់ក្នុងនាមជានិស្សិតដែលសិក្សាផ្នែកនីតិសាស្ត្រ និងទទួលបានការជ្រោមជ្រែងចង្អុលបង្ហាញពីសំណាក់លោកសាស្ត្រាចារ្យណែនាំផងនោះយើងខ្ញុំបានស្រាវជ្រាវលើប្រធានបទ "**ការកាត់កាល់**"នេះដើម្បីឲ្យលម្អិត ព្រមទាំងបានស្វែងយល់ និងមានបំណងបង្ហាញពីអត្ថន័យពិតប្រាកដនៃការកាត់កាល់ និងនីតិវិធីក្នុងការធ្វើការកាត់កាល់ ដែលជាប្រយោជន៍ ដល់ការសិក្សាស្រាវជ្រាវក្រោយៗផង និងជាប្រយោជន៍នៃការសិក្សាផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មកទល់ពេលនេះ យើងទាំងអស់គ្នាបានដឹងខ្លះអំពីការកាត់កាល់ដែលអាចធ្វើឡើងចំពោះតែកូនសុំតែប៉ុណ្ណោះ ហើយការកាត់កាល់គឺធ្វើឡើងដើម្បីប្រយោជន៍នៃកូនសុំដែលរងការធ្វើបាប ឬបំពានផលប្រយោជន៍ ពីសំណាក់ឪពុកម្តាយចិញ្ចឹម ។ ដូច្នេះសំណួរនៅក្នុងការស្រាវជ្រាវលើប្រធានបទនេះបានលើកឡើងថា តើជនណាខ្លះមានសិទ្ធិកាត់កាល់ មូលហេតុអ្វីខ្លះទើបអាចកាត់កាល់បាន ហើយឆ្លងកាត់នីតិវិធីអ្វីខ្លះទើបការកាត់កាល់អាចមានអានុភាពនៅក្នុងការអនុវត្ត?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងនៅក្នុងគោលបំណងដើម្បីរកឲ្យឃើញអំពីចំណុចសំខាន់នៃការកាត់កាល់ ពាក់ព័ន្ធទៅនឹង ជនណាខ្លះដែលអាចមានសិទ្ធិនៅក្នុងការការកាត់កាល់ មូលហេតុ នីតិវិធី និងអានុភាពនៃការកាត់កាល់។ ការសិក្សាស្រាវជ្រាវធ្វើឡើងដើម្បីជាប្រយោជន៍ នៅក្នុងការយល់ដឹង និងដើម្បីចែកជាពុទ្ធិទៅដល់បងប្អូនមិត្តនិស្សិតនៅក្នុងសិក្សារៀនសូត្រ ស្វែងយល់បន្ថែមពីការកាត់កាល់នេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការសិក្សាស្រាវជ្រាវនេះ គឺនឹងត្រូវសិក្សានៅក្នុងរង្វង់ នៃការកាត់កាល់ សុំកូនពេញលេញ និងសុំកូនធម្មតាប៉ុណ្ណោះ ។ ជាងនេះទៅទៀតដែននៃការស្រាវជ្រាវគឺចាប់ពីក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ចូលជាធរមានតែប៉ុណ្ណោះ ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ នឹងចូលរួមជាផ្នែកមួយដ៏សំខាន់សម្រាប់ការសិក្សាស្រាវជ្រាវ របស់បងប្អូនមិត្តនិស្សិត ក៏ដូចជាចូលរួមជាវិភាគទាន នៅក្នុងចែកជាពុទ្ធិជូនទៅដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធទៅនឹងការកាត់កាល់នេះ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ទិន្នន័យដែលប្រមូលបាន គឺយកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព ដោយប្រើ ទិន្នន័យទីមួយ ( Primary Data ) និងទិន្នន័យទីពីរ ( Secondary Data ) បូករួមបញ្ចូលគ្នា ដើម្បីបាន សមិទ្ធផលនៃស្នាដៃមួយនេះឡើង។

- ទិន្នន័យទីមួយ ជាប្រភេទទិន្នន័យផ្ទាល់( Primary Data ) ដោយបានសាកសួរនៅសំណួរ មួយចំនួនទៅកាន់ សាស្ត្រាចារ្យណែនាំ។
- ទិន្នន័យទីពីរ ( Secondary Data ) ដែលបានមកពីការដកស្រង់ចំពោះខ្លឹមសារសំខាន់ៗ និង ចាំបាច់នានា ដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តជាតិ ដែលមានជាធរមាន សៀវភៅ របាយការណ៍ នៅតាមបណ្ណាលបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ ព្រមទាំងឯកសារសារ ណាសិស្សច្បងមួយចំនួន ដែលយើងខ្ញុំបានដាក់នៅក្នុងឧបសម្ព័ន្ធ និងឯកសារយោងខ្លះៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការបែងចែកជា ៣ ជំពូកធំៗ ដូចជា៖

- សេចក្តីផ្តើម ៖ ផ្នែកនេះចង់បង្ហាញឲ្យឃើញអំពី លំនាំបញ្ហានៃសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការ ស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។
- ជំពូកទី១ ៖ មូលហេតុនៃការកាត់កាល់ និងអ្នកមានសិទ្ធិ ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញលោកអ្នក ឲ្យបានយល់ដឹងអំពី និយមន័យនៃពាក្យគន្លឹះខ្លះអំពី ការកាត់កាល់ស៊ុំកូនពេញលេញ និងស៊ុំកូនធម្មតា មូលហេតុនៃការកាត់កាល់ និង អំពីជនណាខ្លះដែលមានសិទ្ធិនៅក្នុងការកាត់កាល់។
- ជំពូកទី២ ៖ នីតិវិធីនៃការកាត់កាល់ ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឲ្យឃើញអំពីនីតិ វិធីនៃការកាត់កាល់ ដែលយើងបានធ្វើការបែងចែង តាមរយៈពាក្យសុំ និងតាមរយៈ ពាក្យបណ្តឹង។
- ជំពូកទី៣ ៖ អានុភាពនៃការកាត់កាល់ ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឲ្យឃើញអំពី អានុភាពនៅក្រោយការកាត់កាល់ ដែលយើងធ្វើការបែងចែកជា២ គឺ ទំនាក់ទំនង ញាតិ និង ទំនាក់ទំនងទ្រព្យ។

- សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៖ យើងខ្ញុំធ្វើការលើកឡើងនូវសេចក្តីសន្និដ្ឋានជារួម និងលើកយកចំណុចមួយចំនួនមកផ្តល់ជាអនុសាសន៍ដែលពួកយើងខ្ញុំបានរកឃើញនៅក្នុងប្រធានបទនេះ។

# ជំពូក១
## មូលហេតុនៃការកាត់កាល់និងអ្នកមានសិទ្ធិ

# ជំពូក១

# មូលហេតុនៃការកាត់កាល់ និងអ្នកមានសិទ្ធិ

ការកាត់កាល់ អាចមានអានុភាពគតិយុត្តអនុវត្តទៅបាន លុះត្រាណាតែមានមូលហេតុសមរម្យ និងច្បាស់លាស់ និងត្រូវធ្វើឡើងដោយអ្នកមានសិទ្ធិដែលបានទទួលស្គាល់ដោយច្បាប់ ។ មូលហេតុនៃកាត់កាល់ និងអ្នកមានសិទ្ធិក្នុងការកាត់កាល់ ប្រែប្រួលទៅតាមប្រភេទនៃទំនាក់ទំនងឪពុកម្តាយ និងកូននីមួយៗ ។ ដែលក្នុងនោះមាន មូលហេតុនៃកាត់កាល់ និងអ្នកមានសិទ្ធិក្នុងការកាត់កាល់សុំកូនធម្មតា(ផ្នែកទី១) និងមូលហេតុនៃការកាត់កាល់ និងអ្នកមានសិទ្ធិក្នុងការកាត់កាល់សុំកូនពេញលេញ (ផ្នែកទី២)។

## ផ្នែកទី១ មូលហេតុ និងអ្នកមានសិទ្ធិការកាត់កាល់ សុំកូនធម្មតា

សុំកូនធម្មតា ជាការសុំកូនដែលកូននោះអាចជានីតិជន ឬអនីតិជនដោយមិនកាត់ផ្តាច់នីតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

សុំកូនធម្មតា អាចហៅបានថាជាសុំកូនសាមញ្ញ។ សុំកូនធម្មតា គឺជាទម្រង់មួយដែលជួយសម្រួលពីសុំកូនពេញលេញ ដោយដាក់កូនសុំទៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ហើយមិនមាននូវការកាត់ផ្តាច់ទំនាក់ទំនងជាមួយគ្រួសារឪពុកម្តាយបង្កើត និងកូនសុំឡើយ[7]។

សុំកូនធម្មតានេះ ក៏ត្រូវបានបញ្ចប់ផងដែលតាមរយៈការការកាត់កាល់កូនសុំធម្មតា ។ ការកាត់កាល់កូនសុំធម្មតា អាចធ្វើទៅបានដោយមានមូលហេតុព្រមព្រៀង ( កថាខណ្ឌទី១ ) និងដោយតាមច្បាប់កំណត់ (កថាខណ្ឌទី២)។

### កថាខណ្ឌទី១ ការកាត់កាល់សុំកូនធម្មតាដោយការព្រមព្រៀង និងអ្នកមានសិទ្ធិ

នៅក្នុងលក្ខខណ្ឌនៃកូនសុំធម្មតា ការកាត់កាល់ដោយមូលហេតុនៃការព្រមព្រៀងអាចកើតមានឡើងជា២ករណី៖ ករណីកូនសុំជានីតិជន( ក ) និងករណីកូនសុំជាអនីតិជន(ខ) ។

#### ក. ករណីកូនសុំជានីតិជន

##### ក.១.ការព្រមព្រៀងរវាងភាគីសុំកូន

ជាគោលការណ៍ នីតិជនត្រូវបានក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថាជាជនដែលមានសមត្ថភាពក្នុងយល់ដឹងអំពីលទ្ធភាពនៃអំពើរបស់ខ្លួន តួយ៉ាងដូចជាការសម្រេចចិត្តក្នុងការកាត់កាល់សុំកូនធម្មតា ជាមួយឪពុកម្តាយចិញ្ចឹមនេះជាដើម។

[7] មាត្រា១០២០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ដូចនេះហើយប្រសិនកូនសុំជានីតិជន ការកាត់កាល់កូនស្មុំធម្មតា អាចធ្វើទៅបានដោយមានការព្រមព្រៀងដោយឆន្ទះពិតប្រាកដរវាងភាគីស្មុំកូន។ ភាគីស្មុំកូន សំដៅទៅដល់ឪពុកម្តាយចិញ្ចឹម និងកូនសុំ ។

**ក.២.អ្នកមានសិទ្ធិកាត់កាល់**

ចំពោះការកាត់កាល់កូនស្មុំធម្មតា ដោយមូលហេតុព្រមព្រៀង ក្នុងករណីកូនសុំជានីតិជន ភាគីនីមួយៗនៃស្មុំកូនបានដាក់ពាក្យសុំកាត់កាល់ទៅតុលាការ[8]។ ក្នុងករណីនេះ តុលាការអាចសម្រេចឲ្យកាត់កាល់ស្មុំកូនបាន លុះត្រាតែបានបញ្ជាក់ថា ភាគីនៃស្មុំកូននីមួយៗមានបំណងពិតប្រាកដនៅក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ។

ជារួមមក ចំពោះការកាត់កាល់កូនស្មុំធម្មតាដោយមូលហេតុព្រមព្រៀង ក្នុងករណីកូនសុំជានីតិជន ទាំងឪពុកម្តាយចិញ្ចឹម ទាំងកូនសុំ សុទ្ធតែត្រូវបានទទួលស្គាល់ថា ជាអ្នកមានសិទ្ធិដាក់សុំកាត់កាល់។

**ខ.ករណីកូនសុំជាអនីតិជន**

**ខ.១.ការព្រមព្រៀងរវាងភាគីឪពុកម្តាយចិញ្ចឹមនិងអ្នកតំណាងដែលច្បាប់កំណត់របស់កូនសុំ**

អនីតិជន ត្រូវបានក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់ថាៈ ជាជនដែលមានអាយុក្រោម១៨ឆ្នាំ ដែលពុំមានសមត្ថភាពនៅក្នុងការបង្ហាញឆន្ទះរបស់ខ្លួនបាននោះទេ ។ ដូច្នេះការកាត់កាល់កូនស្មុំធម្មតាដោយការព្រមព្រៀង ក្នុងករណីកូនសុំជាអនីតិជន កូនសុំមិនអាចធ្វើការព្រមព្រៀងបានឡើយ។

ការព្រមព្រៀងក្នុងការកាត់កាល់កូនសុំជាអនីតិជន អាចធ្វើទៅបានរវាងឪពុកម្តាយចិញ្ចឹម និងអ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់។

អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់ អាចជាឪពុកម្តាយបង្កើតរបស់កូនសុំដែលមានអំណាចមេបារួមគ្នាលើកូនសុំ ។ ប៉ុន្តែក្នុងករណីឪពុកម្តាយបង្កើតរបស់កូនសុំលែងលះគ្នា ឪពុកម្តាយបង្កើតរបស់កូនសុំនោះត្រូវពិភាក្សាដើម្បីកំណត់ថា អ្នកណាត្រូវក្លាយជាអ្នកមានអំណាចមេបា ក្រោយការកាត់កាល់ ។ ប្រសិនបើការពិភាក្សាគ្នាមិនឈានដល់ការដាច់ស្រេចទេ តុលាការត្រូវសម្រេចអំពីអ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍នៃកូនស្មុំនោះ[9]។

---

[8] មាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា ១០២៨ កថាខណ្ឌទី៣ និងទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់ ក៏អាចជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនលើកូនសុំផងដែរ[10]។

**ខ.២ អ្នកមានសិទ្ធិកាត់កាល់**

ការព្រមព្រៀងកាត់កាល់ ត្រូវបានធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងអ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់ នោះពាក្យសុំកាត់កាល់ទៅតុលាការ ក៏ត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងអ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់ដែរ ។ ប៉ុន្តែ នៅក្នុងករណីកូនសុំជាអនីតិជនដែលមានអាយុលើសពី១៥ឆ្នាំ នោះចាំបាច់ត្រូវមានការយល់ព្រមពីកូនសុំនោះជាមុនសិន ទើបតុលាការអាចសម្រេចអំពីការកាត់កាល់ដោយផ្អែកលើការព្រមព្រៀងបាន។

ទោះបីជាកូនសុំមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើកូនសុំជាអនីតិជននោះអាចធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវតែសួរយោបល់ពីកូនសុំដែលជាអនីតិជននោះ ដោយករណីនេះផ្តើមចេញពីទស្សនៈ នៃការគោរពឆន្ទៈរបស់កូនសុំ[11] ដោយពិចារណាទៅលើមាត្រា១២[12] នៃអនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៨៩ ក្នុងករណីការកាត់កាល់នោះធ្វើឡើងដោយការព្រមព្រៀង។

មួយវិញទៀត នៅក្នុងករណីដែលសហព័ទ្ធបានសុំកូនដោយសហការគ្នា ជាឪពុកម្តាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជនដោយការព្រមព្រៀង ឪពុកម្តាយចិញ្ចឹមនោះត្រូវរួមគ្នាដាក់ពាក្យសុំកាត់កាល់សុំកូនធម្មតាជាមួយគ្នា លើកលែងតែសហព័ទ្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន។

**កថាខណ្ឌទី២ មូលហេតុដែលកំណត់ដោយច្បាប់ និងអ្នកមានសិទ្ធិ**

**ក. មូលហេតុដែលកំណត់ដោយច្បាប់**

ទោះបីជាមិនមានការព្រមព្រៀងរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់ក៏ដោយ ការកាត់កាល់កូនសុំធម្មតា ក៏អាចប្រព្រឹត្តទៅ

[10] មាត្រា ១០៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[11] មាត្រា១០២៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] មាត្រា១២ នៃអនុសញ្ញាស្តីសិទ្ធិកុមារឆ្នាំ១៩៨៩ បានបញ្ញត្តិថា៖

១. រដ្ឋភាគីត្រូវធានាដល់កុមារដែលអាចបង្កើតទស្សនៈផ្ទាល់ខ្លួនឲ្យមានសិទ្ធិក្នុងការបញ្ចេញទស្សនៈទាំងនោះដោយសេរីនៅក្នុងវិស័យទាំងអស់ដែលទាក់ទិននឹងកុមារ ទស្សនៈរបស់កុមារត្រូវយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និងសភាពចាស់ទុំឬកម្រិតយល់ដឹងកុមារនោះ។

២. ក្នុងទិសដៅនោះ កុមារត្រូវទទួលបានជាពិសេសនូវឱកាសបញ្ចេញយោបល់ខ្លួន នៅក្នុងដំណើរការផ្នែកច្បាប់ និងផ្នែករដ្ឋបាលដែលទាក់ទិននិងកុមារនៅក្នុងលក្ខណៈមួយដែលស្របគ្នា ទៅនឹងវិធាននីតិវិធីនៃច្បាប់ក្នុងប្រទេស។ ការបញ្ចេញមតិនេះអាចប្រព្រឹត្តទៅដោយផ្ទាល់ឬតាមរយៈអ្នកតំណាង ឬតាមរយៈអង្គការសមស្របណាមួយ។

បានប្រសិនបើមានមូលហេតុដែលកំណត់ដោយច្បាប់[13] ដូចជា ភាគីម្ខាងនៃស្មុំកូនបានបោះបង់ភាគីម្ខាងទៀតដោយគំនិតទុច្ចរិត (ក.១) ភាពមិនច្បាស់លាស់នៃការនៅរស់របស់ភាគីស្មុំកូន (ក.២) និងមូលហេតុធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យពិបាកក្នុងការបន្តស្មុំកូន (ក.៣)។

**ក.១. ភាគីម្ខាងនៃស្មុំកូនបានបោះបង់ភាគីម្ខាងទៀតដោយគំនិតទុច្ចរិត**

ការបង្កើតរបបស្មុំកូនធម្មតាឡើង គឺដើម្បីប្រយោជន៍ទាំងភាគីកូនសុំ និងភាគីដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ។ ក៏ប៉ុន្តែនៅក្នុងករណីដែលបើភាគីណាម្ខាងនៃស្មុំកូនមានគំនិតទុច្ចរិត ហើយត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀត ដោយគំនិតទុច្ចរិត និងគ្មានទំនួលខុសត្រូវលែងផ្ដល់ផលប្រយោជន៍ ទៅដល់គ្នាទៅវិញទៅមក វាក៏ជាមូលហេតុមួយនៃការកាត់កាល់ស្មុំកូនធម្មតានោះដែរ ។

**ក.២. ភាពមិនច្បាស់លាស់នៃការនៅរស់របស់ភាគីស្មុំកូន**

ការបង្កើតស្មុំកូនធម្មតា គឺក្នុងគោលបំណងផ្ដល់ផលប្រយោជន៍ឲ្យភាគីស្មុំកូន ដូចជា ការរស់នៅ ការថែរក្សាគ្នា ជាដើម...។ ល។ ប៉ុន្តែ ផលប្រយោជន៍ទាំងនោះប្រែទៅជាគ្មាន នៅក្នុងករណីដែលកូនសុំមិនដឹងថាឪពុកម្ដាយចិញ្ចឹមរបស់ខ្លួន នៅរស់ ឬទទួលមរណភាព ក្នុងអំឡុងរយៈពេលវែងមួយ ដោយសារការបាត់ខ្លួន ឬ អវត្តមាន ជាដើម។

ដូចនេះ នៅក្នុងលក្ខខណ្ឌដែលភាគី កូនសុំមិនដឹងថាឪពុកម្ដាយចិញ្ចឹមរបស់ខ្លួន នៅរស់ ឬទទួលមរណភាព ឬ ឪពុកម្ដាយចិញ្ចឹម មិនដឹងថាកូនសុំរបស់ខ្លួន នៅរស់ ឬទទួលមរណភាពនៅក្នុងរយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ក៏ជាមូលហេតុ នៃការទាមទារឲ្យមានការកាត់កាល់ស្មុំកូនធម្មតាដែរ។

**ក.៣. មូលហេតុធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យពិបាកក្នុងការបន្តស្មុំកូន**

ស្មុំកូននឹងពិបាកបន្តទៅទៀត បើភាគីម្ខាងនៃស្មុំកូនត្រូវបានទទួលរងនូវអំពើហិង្សា ការធ្វើទារុណកម្ម ការជេរប្រមាថ ការប្រព្រឹត្តអំពើពុំត្រឹមត្រូវ និងធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់ពីសំណាក់ភាគីម្ខាងទៀតជាអាទិ៍ ដែលជាសត្យានុម័ត[14] ធ្វើឲ្យទំនាក់ទំនងនៃស្មុំកូនវិនាស និងមិនអាចរំពឹងថាអាចស្ដាឡើងវិញបាន នៃផលប្រយោជន៍របស់ភាគីស្មុំកូន។

[13] មាត្រា១០៣១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[14] សត្យានុម័ត ជាការស្ដែងឡើងជារូបភាព

## ខ. អ្នកមានសិទ្ធិកាត់កាល់ដោយមូលហេតុកំណត់ដោយច្បាប់

### ខ.១.ករណីកូនសុំជានីតិជន

ក្នុងករណីកូនសុំជានីតិជន ភាគីនៃស្មុំកូន អាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់បាន។ មានន័យថា ទាំងភាគីកូនសុំ និងភាគីឪពុកម្តាយចិញ្ចឹម សុទ្ធតែអាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់បាន តាមមូលហេតុសមស្របដូចដែលបានរៀបរាប់ខាងលើ[15] ដូចជា ដោយការបោះបង់ដោយគំនិតទុច្ចរិត ការបាត់ខ្លួន ឬអវត្តមាននៃភាគីនៃស្មុំកូន និងមូលហេតុធ្ងន់ធ្ងរជាដើម។

### ខ.២.ករណីកូនសុំជាអនីតិជន

ដើម្បីការពារនូវប្រយោជន៍នៃកូនសុំជាអនីតិជន ឪពុកម្តាយចិញ្ចឹមពុំអាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់ចំពោះកូនសុំបានឡើយ[16] ទោះបីជាមានមូលហេតុដូចបានរៀបរាប់ខាងលើក៏ដោយ ។ ផ្ទុយទៅវិញ ច្បាប់បានអនុញ្ញាតឲ្យកូនសុំដែលជាអនីតិជន ក្នុងការធ្វើបណ្តឹងកាត់កាល់ចំពោះឪពុកម្តាយចិញ្ចឹមរបស់ខ្លួនបាន តាមមូលហេតុសមស្រប ដូចជាដោយការបោះបង់ដោយគំនិតទុច្ចរិត ការបាត់ខ្លួន ឬអវត្តមាននៃភាគីនៃស្មុំកូន និងមូលហេតុធ្ងន់ធ្ងរជាដើម។

ម្យ៉ាងទៀត អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំក្រោយការកាត់កាល់ ក៏អាចធ្វើបណ្តឹងទាមទារឲ្យកាត់កាល់បានដែរ ។ ករណីនេះ ប្រសិនបើកូនសុំនោះដល់អាយុ១៥ឆ្នាំហើយ ចាំបាច់ត្រូវមានការយល់ព្រមពីកូនសុំ ដើម្បីសម្រេចអំពីការកាត់កាល់ ។ ដោយផ្តើមចេញទស្សនៈនៃការគោរពឆន្ទៈរបស់កូនសុំ តុលាការត្រូវសួរយោបល់កូនសុំដែលអាចបង្ហាញឆន្ទៈបាន ទោះបីកូនសុំនោះមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ[17]។

ក្នុងករណីកូនសុំជាអនីតិជន តើតំណាងអយ្យការអាចដាក់ពាក្យបណ្តឹងកាត់កាល់ស្មុំកូនធម្មតាបានដែរ ឬ ទេ?

មួយវិញទៀតនៅក្នុងករណីកូនសុំជាអនីតិជន តំណាងអយ្យការក៏អាចមានសិទ្ធិនៅក្នុងការដាក់ពាក្យបណ្តឹងកាត់កាល់កូនស្មុំធម្មតាបានដែរ ។ នៅក្នុងករណីដែលកូនសុំជាអនីតិជនគ្មានឪពុកម្តាយបង្កើតនៅក្នុងការធ្វើពាក្យបណ្តឹង តំណាងអយ្យការ មានសិទ្ធិតំណាងឲ្យកូនសុំជាអនីតិជននោះធ្វើបណ្តឹងកាត់កាល់ ដើម្បីការពារនូវប្រយោជន៍របស់កូនសុំនោះ[18]។

---

[15] មូលហេតុដែលស្ថិតនៅក្នុងចំនុចក( ករណីព្រមព្រៀង)និង ខ (ករណីកំណត់ដោយច្បាប់)

[16] មាត្រា ១០៣១ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[17] មាត្រា ១០២៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[18] មាត្រា ១០២៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ផ្នែកទី២៖ ការកាត់កាល់សុំកូនពេញលេញ

សុំកូនពេញលេញ សំដៅដល់ការសុំកូនដែលមានអាយុក្រោម០៨ (ប្រាំបី)ឆ្នាំ យកមកធ្វើជាកូនសុំហើយ មានអានុភាព បង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយនិងកូន រវាងឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម និងកូនសុំ និងបញ្ចប់សិទ្ធិនិងកាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើតឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន[19]។

ការកាត់កាល់សុំកូនពេញលេញ សំដៅដល់ការកាត់ផ្តាច់ទំនាក់ទំនងអចិន្ត្រៃយ៍ និងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាង កូនសុំ និងឪពុកម្តាយចិញ្ចឹម។ ការកាត់កាល់សុំកូនពេញលេញ អាចមានអានុភាពទៅបាន លុះត្រាណាតែមាន មូលហេតុសមស្រប( កថាខណ្ឌទី១) និង អ្នកមានសិទ្ធិនៅក្នុងការកាត់កាល់( កថាខណ្ឌទី២) និងធ្វើឡើងតាមរយៈផ្លូវតុលាការទើបការកាត់កាល់កូនសុំពេញលេញមានអានុភាព។

### កថាខណ្ឌទី១៖ មូលហេតុនៃការកាត់កាល់សុំកូនពេញលេញ

ការកាត់កាល់កូនសុំពេញលេញ អាចធ្វើទៅបានលុះត្រាតែមានមូលហេតុទាំងពីរនេះគឺ ៖ ការបំពានផលប្រយោជន៍របស់កូនសុំ(ក) និងលទ្ធភាពរបស់ឪពុកម្តាយបង្កើត (ខ) ។

#### ក. ការបំពានប្រយោជន៍របស់កូនសុំ

ការបង្កើតនូវរបបកូនសុំពេញលេញ គឺជាវិធីមួយ ឬជាមធ្យោបាយមួយ ក្នុងការសង្គ្រោះក្មេងអភ័ព្វដែលជាកូនសុំ ដោយការផ្តល់នូវគ្រួសារមួយដែលមានឪពុកម្តាយ និងមានលំនឹងជីវភាពជួយទៅដល់ពួកគេសម្រាប់ជីវភាពរស់នៅ និងការលូតលាស់របស់កូនសុំ ។ តែបើស្ថិតនៅក្នុងករណីដែលកូនសុំ ត្រូវទទួលរងការបំពានផលប្រយោជន៍ នោះការកាត់កាល់អាចធ្វើទៅបាន ដោយយោងទៅតាមមូលហេតុសមរម្យ ដូចជា៖

-មានផលប៉ះពាល់ទៅលើផលប្រយោជន៍នៃកូនសុំ ដោយការធ្វើបាបរបស់ឪពុកម្តាយចិញ្ចឹម ឬ

-ការបោះបង់កូនសុំចោលដោយគំនិតទុច្ចរឹតពីសំណាក់ឪពុកម្តាយចិញ្ចឹម ឬ

-អំពើផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ដែលជាហេតុពុំអាចបន្តនៅសុំកូនបានទៀត[20] ឬ

-ករណីដែលបំពានទៅនឹងផលប្រយោជន៍របស់កុមារ ឬ

---

[19] មាត្រា៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស

[20] មាត្រា១០១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

-ករណីដែលមានការបំពានករណីយកិច្ចរបស់ឪពុកម្ដាយចិញ្ចឹម ដូចជាការវាយធ្វើបាប ទារុណកម្ម ឬអំពើហិង្សា ដោយឪពុកម្ដាយចិញ្ចឹម ជាដើម...។ល។

**ខ. លទ្ធភាពរបស់ឪពុកម្ដាយបង្កើត**

នៅក្នុងរបបនៃសុំកូនពេញលេញ លទ្ធភាពក្នុងការថែរក្សាកូន របស់ឪពុកម្ដាយបង្កើតនៃកូនសុំ ក៏ជាមូលហេតុនៅក្នុងការសុំកាត់កាល់ដែរ ប្រសិនបើឪពុកម្ដាយបង្កើតយល់ឃើញថាខ្លួន មានលទ្ធភាពសមរម្យគ្រប់គ្រាន់ ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឲ្យរស់នៅក្នុងភាពសមរម្យ ថ្លៃថ្នូរ អាចផ្គត់ផ្គង់ជីវភាព និងអាចផ្ដល់នូវការអប់រំសិក្សារៀនសូត្រ វិញបាន ។

ប្រសិនបើយើងពិនិត្យលើមាត្រា ១០១៦ កថាខណ្ឌទី១ ការកាត់កាល់អាចប្រព្រឹត្តទៅបានលុះត្រាតែត្រូវនឹងមូលហេតុទាំងពីរ។ ពោលគឺ មានការបំពានពីសំណាក់ឪពុកម្ដាយចិញ្ចឹម និងឪពុកម្ដាយបង្កើតមានលទ្ធភាពគ្រប់គ្រងថែរក្សាកូនវិញ ។ ហើយប្រសិនបើយើងពិនិត្យលើមាត្រាដដែលនេះ ក្នុងកថាខណ្ឌទី២វិញបានបញ្ជាក់ឲ្យកាន់ច្បាស់ថាការកាត់កាល់មិនអាចធ្វើទៅបានឡើយ ប្រសិនបើពុំផ្អែកលើមូលហេតុទាំងពីរខាងលើ ។ ត្រង់ចំណុចនេះ មានការលើកឡើង និងការព្រួយបារម្ភថា ប្រសិនបើកូនសុំបានទទួលរងនូវការបំពានពីឪពុកម្ដាយចិញ្ចឹម ដូចជាបានធ្វើទារុណកម្ម ប៉ុន្តែឪពុកម្ដាយបង្កើតរបស់កូនសុំ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការថែរក្សាកូនសុំវិញឡើយ។ ករណីបែបនេះតើអាចធ្វើបណ្ដឹងកាត់កាល់សុំកូនពេញលេញបានដែរ ឬ ទេ?

ឆ្លើយតបនឹងបញ្ហា និងសំណួរខាងលើ មានអ្នកច្បាប់មួយចំនួនបានបកស្រាយ ពាក្យថា ឪពុកម្ដាយបង្កើតក្នុងមាត្រា ១០១៦ កថាខណ្ឌទី១ ចំណុច ខ ដោយរាប់បញ្ចូលទាំងរដ្ឋផងដែរ ។ ការបកស្រាយបែបនេះ ដោយផ្អែកទៅលើគោលការណ៍ទូទៅមួយគឺ ប្រជាជនទាំងអស់នៅក្នុងសង្គម សុទ្ធតែជាសមាជិកនៃសង្គមដែលមានរដ្ឋជាអាណាព្យាបាល។ ជាជម្រើសដែលល្អមួយដើម្បីធានាដល់នូវប្រយោជន៍របស់កូនសុំ និងជាទណ្ឌកម្មដល់ឪពុកម្ដាយចិញ្ចឹម ក្នុងករណីដែលឪពុកម្ដាយចិញ្ចឹមបានបំពានផលប្រយោជន៍ដល់កូនសុំ ហើយឪពុកម្ដាយបង្កើត គ្មានលទ្ធភាពនៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឲ្យបានសមរម្យ ឬឪពុកម្ដាយបង្កើតបានស្លាប់បាត់បងជីវិត តុលាការអាចសម្រេចព្យួរ ឬ ដកហូតអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម[21] ហើយជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញ ដើម្បីឲ្យសុំកូនបន្តនូវសិទ្ធិ ទទួលបានអាហារកិច្ច និងសិទ្ធិផ្នែកសន្តតិកម្ម ជាអាទិ៍ ជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។ នេះប្រសិនបើកូនសុំជាអនីតិជន ។

[21] មាត្រា១០៩៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**កថាខណ្ឌទី២៖ អ្នកមានសិទ្ធិកាត់កាល់ស្មុំកូនពេញលេញ**

ក្រោយពីស្វែងរកអំពីមូលហេតុនៃការកាត់កាល់ហើយ អ្នកដែលមានសិទ្ធិដាក់ពាក្យបណ្ដឹងទាមទារឲ្យកាត់កាល់គឺជាកត្តាចម្បងសម្រាប់ការពិចារណារបស់តុលាការផងដែរ។ អ្នកមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ស្មុំកូនពេញលេញ រួមមាន កូនសុំ (ក) ឪពុកម្ដាយបង្កើតរបស់កូនសុំ (ខ) និងតំណាងអយ្យការ (គ)។

ដោយឡែកចំពោះឪពុកម្ដាយចិញ្ចឹម មិនត្រូវបានច្បាប់ទទួលស្គាល់ថាជាអ្នកមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ស្មុំកូនពេញលេញឡើយ។ ដូចនេះ ឪពុកម្ដាយចិញ្ចឹមគ្មានសិទ្ធិដាក់ពាក្យសុំកាត់កាល់ស្មុំកូនពេញលេញទេ ទោះកាលៈទេសៈណាក៏ដោយ។

**ក. កូនសុំ**

ដើម្បីធានានូវផលប្រយោជន៍ដល់កូនសុំ ក្រមរដ្ឋប្បវេណីយើងបានផ្ដល់សិទ្ធិឲ្យទៅកូនសុំដើម្បីដាក់ពាក្យប្ដឹងទាមទារឲ្យកាត់កាល់ស្មុំកូនពេញលេញ ដោយយោងតាមមូលហេតុដូចបានរៀបរាប់ខាងលើ ទោះបីកូនសុំជាអនីតិជនក៏ដោយ ។ នីតិវិធីនៃការកាត់កាល់ ក្នុងករណីកូនជាអនីតិជន នឹងសរសេរលម្អិតក្នុងចំណុចស្ដីពីនីតិវិធីនៃការកាត់កាល់។

ដើម្បីបញ្ចៀសផលប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់កូនសុំ ដែលជាហេតុធ្វើឲ្យកូនសុំពិបាកនៅក្នុងការរស់នៅក្នុងគ្រួសារនៃឪពុកម្ដាយចិញ្ចឹម។

**ខ. ឪពុកម្ដាយបង្កើត**

ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើការប្ដឹងទាមទារឲ្យមានការកាត់កាល់កូនស្មុំពេញលេញបានដោយយោងតាមមាត្រា១០១៦។ ការអនុញ្ញាតបែបនេះ ដោយសារតែឪពុកម្ដាយបង្កើតគឺជាអ្នកដែលមានបុគ្គភាពជាមួយកូនសុំ តាំងមុនពេលបង្កើតស្មុំកូនពេញលេញម៉្លេះ ទើបច្បាប់បានផ្ដល់សិទ្ធិឲ្យឪពុកម្ដាយបង្កើតមានសិទ្ធិនៅក្នុងការកាត់កាល់នេះដោយយោងតាមជីវភាពរបស់ពួកគេ ព្រោះក្រោយពេលកាត់កាល់ ឪពុកម្ដាយបង្កើតជាអ្នកបីបាច់ថែរក្សាកូនសុំនោះវិញ។

**គ. តំណាងអយ្យការ**

នៅក្នុងរឿងក្ដីរដ្ឋប្បវេណី តំណាងអយ្យការគឺជាគូក្ដីរណបនៅក្នុងនីតិវិធីតុលាការ[22] ។ ក្នុងករណីដែលយល់ឃើញថាចាំបាច់ត្រូវការពារនូវផលប្រយោជន៍របស់សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថាពាក្យបណ្ដឹង បានទទួល ។ ទោះបីជាគ្មានការជូនដំណឹងដូចបានកំណត់ខាងលើពីតុលាការក៏ដោយ ក៏តំណាងអយ្យការអាចចូលរួមនៅក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែល ប្រសិនបើខ្លួនយល់ឃើញថាដើម្បីការពារនៅប្រយោជន៍

[22] យោងតាមមាត្រា ៦ វាក្យខណ្ឌទី២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងឋានៈបុគ្គល ។

សាធារណៈ[23] ស្របទៅតាមនេះដែលប្រសិនបើកូនសុំជាអនីតិជន ហើយឪពុកម្តាយបង្កើតគ្មានលទ្ធភាព ឬ ឪពុកម្តាយបង្កើតបានទទួលមរណភាព ឬ ករណីមួយចំនួនដែលការកាត់កាល់ ធ្វើឡើងដោយមូលហេតុមានអំពើហិង្សា ទារុណកម្ម ដែលប៉ះពាស់ដល់ផលប្រយោជន៍សាធារណៈ ។ ដូចនេះហើយដោយយោងតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណី បានផ្តល់សិទ្ធិជូនតំណាងអយ្យការដើម្បីធ្វើពាក្យបណ្តឹងកាត់កាល់បានដែរ ។

[23] យោងតាមមាត្រា ៦ នៃក្រមនីតិវិធិរដ្ឋប្បវេណី ឆ្នាំ២០០៦។

# ជំពូក២
# នីតិវិធីនៃការកាត់កាល់

# ជំពូកទី២
# នីតិវិធីនៃការកាត់កាល់

ដើម្បីឲ្យការកាត់កាល់មានសុពលភាពគតិយុត្ត លុះត្រាណាតែការកាត់កាល់នោះបាន អនុវត្តតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ។ រឿងក្តីកាត់កាល់ខ្លះត្រូវ បានអនុវត្តតាមច្បាប់ស្តី នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលបានចូលជាធរមាន នៅឆ្នាំ២០១០ ( ពាក្យសុំកាត់កាល់) និង រឿងក្តីកាត់កាល់ខ្លះត្រូវបានអនុវត្តតាមនីតិវិធីដែលចែងនៅ ក្នុងច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានចូលជាធរមាន និងប្រកាសឲ្យប្រើ នៅក្នុងឆ្នាំ២០១០ ។ ដែលច្បាប់ទាំងពីរខាងលើនេះ បង្កើតឡើងដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់នៅ ក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមានក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវ ចូលជាធរមាននៅឆ្នាំ២០០៦ ជាគោល។

## ផ្នែកទី១៖ នីតិវិធីមុនការជម្រះក្តី និងសមត្ថកិច្ចសាលាជម្រះក្តី

មុននឹងឈានដល់ការជំនុំជម្រះ នៅក្នុងដំណាក់កាលមុនជំនុំជម្រះគឺជាដំណាក់កាល សំខាន់មួយដែលភាគីនៃរឿងក្តីកាត់កាល់ ត្រូវតែយល់ដឹងអំពីវិធីធ្វើពាក្យសុំ ( ការកាត់កាល់នៃការ ព្រមព្រៀង) ឬ ពាក្យបណ្តឹង ( ការកាត់កាល់ដោយច្បាប់បានកំណត់) ។ លើសពីនេះទៅទៀត តុលាការដែលមានសមត្ថកិច្ចនៅក្នុងការជម្រះនៅក្នុងរឿងក្តីកាត់កាល់ក៏ជាចំណុចដ៏សំខាន់ផងដែរ។

### កថាខណ្ឌទី១៖ ពាក្យសុំកាត់កាល់

#### ក. ទម្រង់នៃពាក្យសុំ

ប្រសិនបើការកាត់កាល់ធ្វើឡើងដោយការព្រមព្រៀង ភាគីនៃស្ពុំកូនដែលមានបំណង ចង់កាត់កាល់ ត្រូវធ្វើពាក្យសុំទៅតុលាការក្រោយពីមានការឯកភាពគ្នា ។ របៀប និងទម្រង់ នៃពាក្យសុំក្នុងករណីនេះ ត្រូវធ្វើដូចបានកំណត់ខាងក្រោម៖

- ពាក្យសុំអាចធ្វើឡើងជាលាយល័ក្ខអក្សរ ឬដោយផ្ទាល់មាត់បានលើកលែងតែក្នុងករណី ដែលមានបញ្ញាត្តិពិសេសក្នុងច្បាប់នេះ ឬច្បាប់ផ្សេងទៀត ។
- នៅក្នុងពាក្យសុំ ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

  . ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនិងឈ្មោះ ឬអាសយដ្ឋាន របស់អ្នកតំណាងស្របច្បាប់ បានកំណត់ ( ករណីកូនស្ពុំជា អនីតិជន )

  . ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ ពាក្យសុំ ទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំនុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ។
- ក្នុងករណីដែលមានឯកសារ ជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ។[24]

### ខ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តី ជាប្រាក់ពន្ធ ឬសាហ៊ុយដែលភាគី ឬអ្នកដាក់ពាក្យសុំត្រូវបានបង់ដើម្បីចាត់ការរឿងក្តីរបស់ខ្លួនក្នុងតុលាការតាមនីតិវិធីច្បាប់។ ប្រាក់ប្រដាប់ក្តីរួមមានពន្ធដាក់ពាក្យសុំ[25] ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ[26] (ប្រាក់ប្រដាប់ក្តីតុលាការ) និងប្រាក់ប្រដាប់ក្តីភាគី។

ជាគោលការណ៍ នៅក្នុងនីតិវិធីនៃរឿងក្តីកាត់កាល់ដោយការព្រមព្រៀង ច្បាប់តម្រូវឲ្យអ្នកដាក់ពាក្យសុំត្រូវបង់ពន្ធដាក់ពាក្យសុំ ដែលមានចំនួន ៥០០០ ៛ (ប្រាំពាន់រៀល) លើកលែងតែនៅក្នុងករណីដែលមានការកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ[27] ។ នៅក្នុងរឿងក្តីកាត់កាល់នេះផងដែរ ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធត្រូវបានកំណត់ជាទឹកប្រាក់ចំនួន ៥៥០០០០០ រៀល ( ប្រាំលានប្រាំសែនរៀល)[28] ។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់នូវកំឡុងពេលសមរម្យ និងបង្គាប់ឲ្យបង់ពន្ធនោះ ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីការសម្រេច[29]។

---

[24] មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

[25] ពន្ធដាក់ពាក្យសុំ ជាប្រាក់ប្រដាប់ក្តីមួយប្រភេទដែលត្រូវបានបង់នៅពេលដែលដាក់ពាក្យបណ្តឹង ឬពាក្យសុំទៅតុលាការ

[26] ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ ជាសោហ៊ុយចំណាយចាំបាច់ដែលដើម្បីបំពេញកិច្ចនីតិវិធីដែលភាគី ឬបុគ្គលដែលពាក់ព័ន្ធនឹងរឿងក្តីត្រូវបង់ដូចជា ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និងការចាត់ចែងផ្សេងទៀត។

[27] មាត្រា ២២.២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០

[28] ប្រកាសស្តីពី ប្រភេទពាក្យសុំ ដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និងមាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៧។

[29] មាត្រា ២២.៦ នៃច្បាប់ស្តីពីនិតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០។

ជាទូទៅ បន្ទុកនៃប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ[30] តែក្នុងករណីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ តុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីប្រាក់ប្រដាប់ក្តីខាងលើត្រូវជាបន្ទុករបស់រដ្ឋ។[31]

**គ. សមត្ថកិច្ចនៃសាលាជម្រះក្តី**

ជាទូទៅរឿងក្តីដែលបានកើតឡើងដោយពាក្យសុំ ដូចមានកំណត់ទុកនៅក្នុងបញ្ជីឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ជាប្រភេទរឿងក្តីដែលមិនមានទំនាស់ ពោលមិនមានបុគ្គលដែលមានលក្ខណៈសម្បត្តជាចុងចម្លើយនោះទេ ។ ដូចនេះការកំណត់សមត្ថកិច្ចទៅតាមមូលដ្ឋានរបស់ចុងចម្លើយដូចមាន កំណត់នៅក្នុងមាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនអាចធ្វើទៅបាននោះទេ ។ ហេតុនេះហើយបានជាច្បាប់នេះកំណត់សមត្ថកិច្ចតុលាការមានលក្ខណៈទូលាយ ដោយកំណត់ពីសមត្ថកិច្ចរបស់សាលាដំបូង រាជធានី ខេត្ត ដោយពិចារណាទៅលើភាពសមរម្យងាយស្រួល សមធម៌ ការពិនិត្យភស្តុតាង ដើម្បីធ្វើការវិនិច្ឆ័យអំពីរឿងក្តីដែលកម្មវត្ថុនោះ ។

**កថាខណ្ឌទី២ ពាក្យបណ្តឹងកាត់កាល់**

**ក. ទម្រង់នៃពាក្យបណ្តឹង**

ក្រៅពីការកាត់កាល់ស្នំកូនធម្មតាដោយការព្រមព្រៀង កាតកាត់កាល់ក៏អាចធ្វើទៅតាមកំណត់ច្បាប់ផងដែរ។ ការកាត់កាល់ដែលធ្វើឡើងដោយច្បាប់កំណត់ ភាគីនៃស្នំកូនដែលមានបំណងចង់កាត់កាល់ ត្រូវធ្វើពាក្យបណ្តឹងទៅតុលាការ ដោយមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់។ របៀបនៃធ្វើពាក្យបណ្តឹងគឺមានកំណត់នៅក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានខ្លឹមសារ ដូចបានកំណត់ខាងក្រោមៈ

- ពាក្យបណ្តឹងអាចធ្វើឡើងជាលាយល័ក្ខអក្សរ បានលើកលែងតែក្នុងករណីដែលមានបញ្ញាត្តិពិសេសក្នុងច្បាប់នេះ ឬច្បាប់ផ្សេងទៀត។
- នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមៈ
  - ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនិងឈ្មោះ ឬអាសយដ្ឋានរបស់អ្នកតំណាងស្របច្បាប់ បានកំណត់ ( ករណីកូនស្នំជាអនីតិជន )
  - ខ្លឹមសារនៃសាលក្រម ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យបណ្តឹងទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

[30] មាត្រា ២២.៣ នៃច្បាប់ស្តីពីនិតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០។

[31] មាត្រា ២២.៤ នៃច្បាប់ស្តីពីនិតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០។

- ដើម្បីដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ អ្នកដាក់ពាក្យបណ្តឹងត្រូវធ្វើសេចក្តីថ្លែងការណ៍នូវ ចំនុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជា ពាក្យបណ្តឹង។
- ក្នុងករណីដែលមានឯកសារ ជាភស្តុតាង អ្នកដាក់ពាក្យបណ្តឹងត្រូវភ្ជាប់មកជាមួយនូវឯកសារដើម ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិត នៃពាក្យបណ្តឹង ឬដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យបណ្តឹង។

### ខ. ប្រាក់ប្រដាប់ក្តី

នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ ភាគីត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងនោះជាគោលការណ៍ នៅក្នុងនីតិវិធីនៃរឿងក្តីកាត់កាល់ ច្បាប់តម្រូវឲ្យអ្នកដាក់ពាក្យបណ្តឹងត្រូវបង់ពន្ធដាក់ពាក្យបណ្តឹង ដែលមានចំនួន ៥០០០ ៛ (ប្រាំពាន់រៀល) លើកលែងតែនៅក្នុងករណីដែលមានការកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ[32] ។ នៅក្នុងរឿងក្តីកាត់កាល់នេះផងដែរ ប្រាក់ ប្រដាប់ក្តីក្រៅពីពន្ធត្រូវបានកំណត់ជាទឹកប្រាក់ចំនួន ៥៥០០០០០ រៀល ( ប្រាំលានប្រាំសែនរៀល)[33] ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់នូវកំឡុងពេលសមរម្យ និងបង្គាប់ឲ្យបង់ពន្ធនោះ ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងមិនបានបង់ពន្ធ នោះទេ តុលាការត្រូវលើកលិខិតពាក្យបណ្តឹងចោលដោយដីការសម្រេច[34]។ ក្រៅពីប្រាក់ដែលដើមចោទបានបង់ នៅពេលដាក់ពាក្យបណ្តឹង ដើមចោទក៏ត្រូវបង់ផងដែលនូវប្រាក់ប្រដាប់ក្តីក្រៅពីពន្ធមួយចំនួនជាមុន និងជាការចាំបាច់ដែរ សម្រាប់តុលាការធ្វើការបញ្ជូនឯកសារបន្ទាប់ពីបណ្តឹងត្រូវបានដាក់ ដូចជា ការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ការបញ្ជូនដីការកោះហៅភាគីចំនួនទឹកប្រាក់ក្នុងការផ្ញើរសំបុត្រ តាមរយៈបុស្តិ៍ប្រៃសណីយ៍ ឬអាជ្ញាសាលាជាអាទិ៍។ ប្រសិនបើប្រាក់ប្រដាប់ក្តីនោះ ដើមចោទបង់ឲ្យតុលាការប្រើប្រាស់មិនគ្រប់ទេនោះ តុលាការអាចបង្គាប់ឲ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីបន្ថែមទៀតបាន ។ ក្រៅពីប្រាក់ប្រដាប់ក្តីក្រៅពីពន្ធផ្សេងពីការចាំបាច់ខាងលើ តុលាការអាចបង្គាប់ឲ្យបង់តាមករណីជាក់ស្តែងដែលត្រូវបានចំណាយ និងតាមនីតិវិធី

[32] មាត្រា ២២.២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០

[33] ប្រកាសស្តីពី ប្រភេទពាក្យសុំ ដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និងមាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៧។

[34] មាត្រា ២២.៦ នៃច្បាប់ស្តីពីនិតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០។

ដូចមានកំណត់នៅក្នុងមាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី[35] ។ ហេតុដូចនេះនៅពេលដែលបណ្តឹងកាត់កាល់(បណ្តឹងទាក់ទងនឹងឋានៈបុគ្គល) ត្រូវបានដាក់ដល់តុលាការ ភាគីត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងតាមមាត្រា ៦១ និងបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពន្ធតាមមាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី បើមិនដូចនេះទេ តុលាការអាចធ្វើការបដិសេធចោលនូវពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ ដោយមូលហេតុពុំបង់ប្រាក់ប្រដាប់ក្តីបាន។

នៅពេលចេញសាលក្រមសម្រេចបញ្ចាប់បណ្តឹងអង្គសេចក្តី នៃរឿងក្តីឋានៈបុគ្គល តុលាការត្រូវសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ពោលគឺជាបន្ទុករបស់អ្នកចាញ់ក្តី។ ប៉ុន្តែក្នុងករណីដែលមានការស្នើសុំពីដើមចោទ បន្ទុកនៃប្រាក់ប្រដាប់ក្តីនោះខ្លួនជាអ្នកទទួលខុសត្រូវ នោះតុលាការត្រូវសម្រេចតាមការស្នើរសុំនោះ។ ដោយឡែកនៅពេលដែលតំណាងអយ្យការជាភាគីនៃវិវាទនៃទំនាក់ទំនងឋានៈបុគ្គល ហើយតំណាងអយ្យការជាអ្នកចាញ់ក្តី បន្ទុកនៃប្រាក់ប្រដាប់ក្តីជាបន្ទុករបស់រដ្ឋ។

### គ. សមត្ថកិច្ចនៃសាលាជម្រះក្តី

តុលាការ ជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិក្នុងការជំនុំជម្រះក្តីលើវិវាទ ។ យ៉ាងណាមិញ បណ្តឹងទាក់ទងការកាត់កាល់ក្នុងករណីមិនមានការព្រមព្រៀង គឺជាបណ្តឹងទាក់ទងទៅនឹងឋានៈបុគ្គល ដោយមានភាពចាំបាច់ក្នុងការពង្រឹងស្ថិរភាពនៃទំនាក់ទំនងនេះ ច្បាប់បានកំណត់សមត្ថកិច្ចតុលាការក្នុងការដោះស្រាយវិវាទទាក់ទងនឹងឋានៈបុគ្គល ជាសមត្ថកិច្ចផ្តាច់មុខ[36] ។ សមត្ថកិច្ចនោះសំដៅទៅលើសាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គល ពាក់ព័ន្ធនឹងបណ្តឹងនោះ ។ ចាំបាច់ត្រូវកំណត់ឲ្យច្បាស់លាស់នូវតុលាការដែលចាត់ការនូវបណ្តឹងនោះ និងត្រូវប្រមូលផ្តុំនូវបណ្តឹងទាក់ទងឋានៈបុគ្គលដែលអាចប្តឹងដោយបុគ្គលដែលមានទំនាក់ទំនងនិងផលប្រយោជន៍ច្រើននាក់ ហើយធ្វើការកំណត់នូវដែនសមត្ថកិច្ចរបស់តុលាការឲ្យបានច្បាស់លាស់ ដោយយកកន្លែងដែលអាចមានសាមីភាគី ញាតិបុគ្គលដែលពាក់ព័ន្ធនឹងវិវាទ

---

[35] ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ ទៅតាមចំនួនដែលកំណត់ដោយតុលាការៈ

ចំនួនទឹកប្រាក់ដែលចាំបាច់ដើម្បីឲ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗទៀតតាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី

ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងៗទៀត ដែលប្រព្រឹត្តទៅក្រៅប្រព័ន្ធតុលាការ។

[36] សមត្ថកិច្ចផ្តាច់មុខៈ ជាសមត្ថកិច្ចដែលកំណត់ដោយច្បាប់ ប៉ុន្តែដោយមានការពាក់ព័ន្ធនឹងប្រយោជន៍សាធារណៈ គួយ៉ាងភាពចាំបាច់ដោះស្រាយរឿងក្តីឲ្យទាន់ពេលវេលាវេលា ត្រឹមត្រូវនឹងសម្រួលដល់ការដល់ការស្វែងរកការពិត ព្រមទាំងតម្រូវឲ្យមានការដោះស្រាយទៅលើវិវាទទាំងស្រុងតាមរយៈតុលាការ។

ដែលជាភស្តុតាងជាក់លាក់ ដើម្បីសម្រួលដល់ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ ។ ប៉ុន្តែក៏មានអញ្ញាត្រកម្មមួយចំនួនផងដែល ក្នុងករណីដែលបណ្ដឹងនោះស្ថិតនៅក្នុងសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការមួយ ហើយដោយមើលឃើញអំពីភាពអវិជ្ជមាន អាចកើតមានឡើងដូចជាភាពយឺតយ៉ាវនៃនីតិវិធី អសមធម៌រវាងគូភាគីនោះបណ្ដឹងនឹងត្រូវបានផ្ទេរ។

## ផ្នែកទី២ នីតិវិធីនៃការជម្រះក្ដី

នៅក្នុងដំណាក់កាលជំនុំជម្រះក្ដី ជាដំណាក់កាលដ៏សំខាន់មួយនៅក្នុងរឿងក្ដីកាត់កាល់ដែលនៅក្នុងនេះ យើងធ្វើការបែងចែកជា២ផ្នែកធំ គឺ ការកាត់កាល់តាមរយៈការព្រមព្រៀងគឺជាការជម្រះក្ដីតាមរយៈពាក្យសុំ( កថាខណ្ឌទី១ ) និងការកាត់កាល់តាមរយៈច្បាប់បានកំណត់គឺជាការជម្រះក្ដីតាមរយៈពាក្យបណ្ដឹង ( កថាខណ្ឌទី២)។

### កថាខណ្ឌទី១ នីតិវិធីនៃការជម្រះក្ដីតាមរយៈពាក្យសុំ

#### ក.ការសម្រេចសេចក្ដីដោយមិនឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់

ជាទូទៅនៅក្នុងនីតិវិធីបណ្ដឹង មុនឈានចូលទៅដល់ដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាគោលការណ៍ត្រូវឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ជាមុនសិន ។ តែចំពោះរឿងក្ដីទាក់ទងនឹងការកាត់កាល់តាមរយៈការព្រមព្រៀង វាស្ថិតនៅក្នុងរឿងក្ដី រដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដូចនេះការសម្រេចសេចក្ដីតុលាការពុំចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហេតុផលដោយផ្ទាល់មាត់ឡើយ[37]។ យ៉ាងណាមិញ តុលាការក៏អាចធ្វើការសម្រេចសេចក្ដីតាមការទាញហេតុផលដោយផ្ទាល់មាត់ដែរ[38]។

#### ខ.ការសម្រេចសេចក្ដីដោយឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់

ជាទូទៅនៅក្នុងរឿងក្ដីកាត់កាល់តាមរយៈពាក្យសុំ នៅក្នុងសវនាការនៃរឿងក្ដីរដ្ឋប្បវេណីសមាសភាពអ្នកចូលរួមមានដូចជា ចៅក្រម ក្រឡាបញ្ជី តំណាងអយ្យការ( គូក្ដីរណប) ជនពាក់ព័ន្ធ អ្នកបកប្រែជាដើម ។ នៅក្នុងនីតិវិធីនេះ ជូនការត្រូវបានវិនិច្ឆ័យដោយចៅក្រមមួយរូប( ចៅក្រមទោល) ឬដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមដែលមានចៅក្រម៣រូប[39]។

គោលការណ៍មួយចំនួន ដែលក្រុមប្រឹក្សាជំនុំជម្រះត្រូវបំពេញមានជាអាទិ៍[40]៖

. អសាធារណៈភាពនៃការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

---

[37] មាត្រា ២៨.១ ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង

[38] មាត្រា ៣០ និងមាត្រា៣៤.២ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[39] មាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ និងមាត្រា១១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[40] មាត្រា១២ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

. ការបើក និងដឹកនាំសវនាការដោយក្រុមប្រឹក្សាជំនុំជម្រះ

. ការចូលរួមមតិយោបល់ប្រកបដោយសុទ្ធចិត្ត

. ការសម្ងាត់នៃចំនួនសំឡេងដែលចូលរួម

. ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ

. ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះត្រូវមានសិទ្ធិសសម្រេចស្មើគ្នាៗ

គោលការណ៍ទាំងនេះនឹងធ្វើឲ្យមានការទាញហេតុផលដោយផ្ទាល់មាត់ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់។ បន្ទាប់ពីការវិនិច្ឆ័យទៅលើភស្តុតាងក៏ដូចជាបន្ទាល់នានាក្នុងសវនាការទៅកាលបរិច្ឆេទក្រោយ ។ គួរកត់សម្គាល់ថាសវការមានពីរប្រភេទគឺ សវនាការមុនអង្គសេចក្តី[41] និងសវការដល់អង្គសេចក្តី[42]។

**កថាខណ្ឌទី២ នីតិវិធីជម្រះក្តីតាមរយៈពាក្យបណ្តឹង**

រឿងក្តីកាត់កាល់ដែលជាបណ្តឹង ត្រូវបានដំណើរការតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងទៅនឹងឋានៈបុគ្គល ដូចនេះចាំបាច់មាននីតិវិធីធំ២សំខាន់ៗ គឺនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់(ក) និង ការទាញហេតុផលផ្ទាល់មាត់(ខ) ដែលត្រូវយកមកអនុវត្តផងដែរ ដើម្បីធ្វើការវិនិច្ឆ័យទៅលើបណ្តឹងកាត់កាល់ ។

**ក. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់**

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជានីតិវិធីដែលដំណើរការមុនការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងគោលបំណងបំភ្លឺឲ្យបានច្បាស់លាស់នូវចំនុចវិវាទក្នុងបណ្តឹង ដោយរៀបចំនូវការអះអាងរបស់ភាគី ព្រមទាំងការរៀបចំភស្តុតាងដែលត្រូវធ្វើការបញ្ជាក់សម្រាប់ចំណុចវិវាទជាមុន ដើម្បីសម្រួលការវិនិច្ឆ័យទៅក្នុងការទាញហេតុផលផ្ទាល់មាត់ឲ្យមានដំណើរការលឿន។ ចំពោះកាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ នៃរឿងក្តីកាត់កាល់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់រួចរាល់ ។ កាលបរិច្ឆេទដែលបានកំណត់នោះ ត្រូវកំណត់នៅក្នុងកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងកាត់កាល់បានដាក់។[43]

នៅក្នុងដំណាក់កាលនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ នៃរឿងក្តីកាត់កាល់តាមរយៈពាក្យបណ្តឹងនេះពេលដែលចុងចម្លើយ ទទួលបានដំណឹងពីកាលបរិច្ឆេទនៃការត្រៀមទាញហេតុផល

[41] សវនាការមុនអង្គសេចក្តី ជាការសម្រេចទៅលើបញ្ហាបន្ទាន់នានាដែលមិនទាក់ទងទៅដល់អង្គសេចក្តី។

[42] សវនាការដល់អង្គសេចក្តី គឺជាការសម្រេចសេចក្តីជុំវិញខ្លឹមសារ ឬកម្មវត្ថុនៃពាក្យសុំដែលទាមទារអោយតុលាការចេញ

[43] មាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

តាមរយៈដីកាកោះហៅចូលរួមនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ប៉ុន្តែចុងចម្លើយបានអវត្តមាននៅកាលបរិច្ឆេទត្រៀមនោះតុលាការមិនអាចចាត់ទុកថាអវត្តមានរបស់ចុងចម្លើយជាការសារភាពទេ[44]។

**ខ. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមានតួនាទីកំណត់កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ហើយត្រូវធ្វើការកោះហៅភាគីទាំងសងខាងនៃបណ្ដឹងឲ្យមកចូលរួមសវនាការនៅកាលបរិច្ឆេទដែលបានកំណត់នោះ[45]។ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានលក្ខណៈប្រហាក់ប្រហែលទៅនឹង ការទាញហេតុផលផ្ទាល់មាត់ដែរ ។ តែនីតិវិធីនេះមិនអាចជំនួសការទាញហេតុផលផ្ទាល់មាត់ទេ ព្រោះថាជាគោលការណ៍ការជំនុំជម្រះក្ដីលើបណ្ដឹងត្រូវធ្វើឡើងដោយការទាញហេតុផលផ្ទាល់មាត់ ។ នៅក្នុងនីតិវិធីនេះ តុលាការអាចសាកល្បងធ្វើការផ្សះផ្សារបានផងដែរ បើពិចារណាឃើញថាការផ្សះផ្សាអាចឲ្យដើមចោទដកពាក្យបណ្ដឹងវិញ ដើម្បីចេញសាលក្រមបញ្ចប់វិវាទនៃបណ្ដឹងកាត់កាល់នេះ[46] ។

ជាគោលការណ៍នៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៃរឿងក្ដីកាត់កាល់សមាសភាពចូលរួមមានដូចជា ចៅក្រម ក្រឡាបញ្ជី តំណាងអយ្យការ( គូក្ដីរណប) ជនពាក់ព័ន្ធ អ្នកបកប្រែជាដើម ។ នៅក្នុងនីតិវិធីនេះ ជូនការត្រូវបានវិនិច្ឆ័យដោយចៅក្រមមួយរូប( ចៅក្រមទោល) ឬដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមដែលមានចៅក្រម៣រូប[47]។

យោងលើមាត្រា១២នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ក្រុមប្រឹក្សាជំនុំជម្រះត្រូវបំពេញគោលការណ៍មួយចំនួន មានជាអាទិ៍ ៖

. អសាធារណៈភាពនៃការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ[48]

. ការបើក និងដឹកនាំសវនាការដោយក្រុមប្រឹក្សាជំនុំជម្រះ

. ការចូលរួមមតិយោបល់ប្រកបដោយសុទ្ធចិត្ត

. ការសម្ងាត់នៃចំនួនសំឡេងដែលចូលរួម

. ការសម្រេចសេចក្ដីត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ

---

[44] មាត្រា ១៣ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងឋានៈបុគ្គល ២០១០

[45] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

[46] មាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ ការសាកល្បងធ្វើការផ្សះផ្សា ៖ តុលាការអាចធ្វើការសាកល្បងផ្សះផ្សាបានទោះបីជាបណ្ដឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។

[47] មាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ និងមាត្រា១១ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[48] ការទាញហេតុផលផ្ទាល់នៅក្នុងបណ្ដឹងកាត់កាល់ត្រូវបានធ្វើឡើងជាអសធារណៈ ដោយសារតែដើម្បីផានានូវប្រយោយជន៍របស់ភាគីបណ្ដឹង និងការពារនូវសណ្ដាប់ធ្នាប់ពាក់ព័ន្ធទៅនិងឋានៈបុគ្គលឯកជន។

. ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះត្រូវមានសិទ្ធិសសម្រេចស្មើគ្នាៗ

គោលការណ៍ទាំងនេះនឹងធ្វើឲ្យមានការទាញហេតុផលដោយផ្ទាល់មាត់ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ខ.១. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន

ដើមចោទត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីមូលហេតុនៃការដាក់សំណូមពរ ហើយចុងចម្លើយត្រូវធ្វើសេចក្ដីថ្លែងការណ៍ចំពោះមូលហេតុនៃការឆ្លើយតបរបស់ ខ្លួន។ សេចក្ដីថ្លែងការណ៍របស់ដើមចោទ ហៅថាមធ្យោបាយតទល់[49] ឯសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយហៅថាមធ្យោបាយការពារខ្លួន[50]។

នៅក្នុងបណ្ដឹងកាត់កាល់ សិទ្ធិរបស់គូភាគីក្នុងការដាក់នូវមធ្យោបាយតទល់ ឬការពារខ្លួនត្រូវបានផ្ដល់នូវលក្ខខ័ណ្ឌកាន់តែប្រសើរ ពោលគឺទោះបីជាការដាក់មធ្យោបាយតទល់ ឬការពារខ្លួនយឺត ឬមិនត្រូវនឹងពេលសមរម្យដែលបានកំណត់ក្ដី តុលាការពុំអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនយឺតយ៉ាវនោះទេ ព្រោះថាបណ្ដឹងនេះទាមទារឲ្យភាគីបង្ហាញនូវតម្រុយ ឬឯកសារភស្តុតាងជាក់លាក់ ដើម្បីទុកលទ្ធភាពបន្ថែមឲ្យតុលាការពិចារណា និងស្រាវជ្រាវបន្ថែមដើម្បីស្វែងរកការពិតនៃរឿងក្ដី[51]។

### ខ.២. ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

ក្រោយពីបានស្ដាប់ការអះអាងរបស់ភាគី ពិនិត្យទៅលើសំណុំរឿង ឯកសារពាក់ព័ន្ធ និងដោយផ្អែកលើការស្រាវជ្រាវស្វែងរកការពិត តុលាការត្រូវចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទាររបស់ដើមចោទ ដោយបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ និងចេញសាលក្រមចុងក្រោយ ។ តែមុននឹងបញ្ចប់ តុលាការអនុញ្ញាតឲ្យភាគីទាញហេតុផលចុងក្រោយបាន ហើយវាជាឱកាសដែលភាគីនីមួយៗ អាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួនពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ។ ក៏ប៉ុន្តែទោះបីជាការទាញហេតុផលចុងក្រោយបានបញ្ចប់ហើយក្ដី បើយល់ថាចាំបាច់តុលាការអាចបើកឲ្យមានការទាញហេតុផលសារជាថ្មីបាន នៅមុនពេលចេញសាលក្រមចុងក្រោយ[52] ។

---

[49] មធ្យោបាយតទល់ ជាសេចក្ដីថ្លែងការណ៍ដែលអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាការទាមទារតាមផ្លូវបណ្ដឹង។

[50] មធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ ជាសេចក្ដីថ្លែងការណ៍ដែលអះអាងតបចំពោះមូលហេតុនៃការទាមទាររបស់ដើមចោទ ឬអះអាងនូវអង្គហេតុថ្មីដែលជាកម្មវត្ថុនៃបណ្ដឹងតបដាក់ដោយចុងចម្លើយ។

[51] មាត្រា ១៣ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីនីតិវិធីទាក់ទងឋានៈបុគ្គល ២០១០

[52] មាត្រា ១៨០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ២០០៦

## ផ្នែកទី៣ សេចក្ដីសម្រេចកាត់កាល់

នៅក្រោយបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចេញសេចក្ដីសម្រេចចុងក្រោយទាក់ទងនឹងការកាត់កាល់។ នៅក្នុងរឿងក្ដីកាត់កាល់អាចមានសេចក្ដីពីរប្រភេទផ្សេងគ្នា គឺពាក្យសុំកាត់កាល់ តុលាការត្រូវសម្រេចដោយដីកាសម្រេច (កថាខណ្ឌទី១) និងពាក្យបណ្ដឹងកាត់កាល់ តុលាការត្រូវសម្រេចដោយសាលក្រម ឬ សាលដីកា (កថាខណ្ឌទី២)។

### កថាខណ្ឌទី១ ៖ ការសម្រេចសេចក្ដីកាត់កាល់ដោយដីកាសម្រេច

នៅក្នុងការសម្រេចសេចក្ដីចំពោះរឿងក្ដីកាត់កាល់ដោយការព្រមព្រៀង តុលាការត្រូវសេចក្ដីសម្រេចតាមរយៈដីកាសម្រេច។ ដីការសម្រេចនេះ ត្រូវបានធ្វើឡើងជាលាយល័ក្ខអក្សរដោយមានសំអាងហេតុ និងសេចក្ដីសម្រេចបញ្ចាប់ ចៅក្រមត្រូវចុះហត្ថលេខាលើសេចក្ដីសម្រេចនោះ[53] ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងទៅដល់ជនដែលត្រូវបានទទួល( ភាគីនៃបណ្ដឹងកាត់កាល់នោះ) ដីកាសម្រេចនោះ តាមរយៈការបញ្ជូនឯកសារចម្លងជាយថាភូតនៃដីកាសម្រេចនេះ[54]។

#### ក. សេចក្ដីសម្រេចនៃពាក្យសុំកាត់កាល់

នៅពេលដែលពាក្យសុំកាត់កាល់ត្រូវបានដាក់ នោះនីតិវិធីនៃការកាត់កាល់និងត្រូវបានចាប់ផ្ដើមនីតិវិធី ។ តាមរយៈពាក្យសុំខាងលើ តុលាការនិងចេញដីកាសម្រេចដែលមានខ្លឹមសារដូចពាក្យស្នើសុំបានកំណត់ ។ ចំពោះខ្លឹមសារ[55]នៃដីកាសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវសរសេរសំអាងហេតុ ដើម្បីបង្ហាញឲ្យបានច្បាស់លាស់នូវមូលហេតុនៃការវិនិច្ឆ័យចំពោះភាគី ព្រមទាំងសេចក្ដីសម្រេចបញ្ចាប់ដោយត្រូវមានចុះហត្ថលេខារបស់ចៅក្រម ។ ដីកាសម្រេចខាងលើនិងចូលជាស្ថាពរនៅពេលផុតរយៈពេលបណ្ដឹងជំទាស់របស់ជនពាក់ព័ន្ធ ។ ដីកាសម្រេចស្ថាពរ នឹងនាំឲ្យមានអានុភាពដល់ជនពាក់ព័ន្ធមានកាតព្វកិច្ចគោរពតាម មិនអាចប្ដូរ ឬលុបដីកាសម្រេចបានឡើយ ព្រោះថាការសម្រេចខាងលើគឺជាលទ្ធផលនៃការវិនិច្ឆ័យដោយសិទ្ធិអំណាចសាធារណៈ ម្យ៉ាងទៀតបើតុលាការអាចលុបចោល ឬផ្លាស់ប្ដូរសេចក្ដីសម្រេចបានស្រួលៗទៅ ស្ថានភាពនោះនឹងបណ្ដាលឲ្យបាត់បង់ស្ថេរភាពគតិយុត្ត នឹងធ្វើឲ្យខូចកិត្យានុភាពរបស់តុលាការជាក់ជាមិនខាន។ ដីកាសម្រេចជាស្ថាពរត្រូវតែគោរព ។ ក៏ប៉ុន្តែជនពាក់ព័ន្ធអាចប្ដឹងជំទាស់បាននៅក្នុងករណីដែលដីកាសម្រេចមិនទាន់ចូលជាស្ថាពរ។

[53] មាត្រា ៣៥ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[54] មាត្រា៣៦ នៃច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

[55] មាត្រា ៣៥ នៃច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

### ខ. បណ្តឹងជំទាស់លើដីកាសម្រេច

#### ខ.១ ថេរវេលាក្នុងការបណ្តឹងជំទាស់

បណ្តឹងជំទាស់អាចធ្វើឡើង ដើម្បីប្រឆាំងទៅលើផ្នែកណាមួយនៃដីកាសម្រេច ឬទាំងមូល។ បណ្តឹងជំទាស់អាចធ្វើទៅបានក្នុងរយៈពេល ២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការជូនដំណឹងពីដីកាសម្រេចនោះ[56]។ គួរបញ្ជាក់ផងដែលថា រឿងក្តីដែលចាប់ផ្តើមដោយឆន្ទានុសិទ្ធរបស់តុលាការ ពោលពុំមានដាក់ពាក្យសុំទេ ករណីនេះរយៈពេលនៃការប្តឹងជំទាស់ខាងលើត្រូវកំណត់ជនដែលបានទទួលដំណឹងក្រោយគេជាមូលដ្ឋាន[57]។ ជាគោលការណ៍ រយៈពេល២ សប្តាហ៍ខាងលើពុំអាចពន្យាបាននោះទេ តែករណីជនដែលដាក់ពាក្យសុំមានមូលហេតុថាខ្លួនគ្មានកំហុសនៅក្នុងការបង្ហាញខ្លួនខាងលើ ជននោះអាចដាក់ពាក្យសុំបានមួយសប្តាហ៍ទៀត ក្រោយពេលមូលហេតុនោះបានរលត់ ។ តែករណីដែលជននោះនៅបរទេស នោះថេរវេលា មានរហូតដល់ទៅ ២ខែ (ករណីនេះពុំអាចពន្យាបានទេ)[58]។ សិទ្ធិដែលត្រូវផ្តល់សម្រាប់នីតិវិធីខាងលើត្រូវបានបកស្រាយដោយនីតិវិធីមួយជាកំណត់។

#### ខ.២ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់

ចំពោះបណ្តឹងជំទាស់នៅក្នុងច្បាប់នេះ បានបញ្ញាត្តិបន្ថែមថា ក្រៅពីបញ្ញាត្តិនៃជំពូកទី៥ (ការវិនិច្ឆ័យ) នៃច្បាប់នេះបានបញ្ញាត្តិនៃជំពូកទី៤ (បណ្តឹងជំទាស់) គន្លឹទី៣ នៃ(បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានយកមកអនុវត្តដូចគ្នាផងដែល នៅក្នុងករណីនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ (លើកលែងតែករណីមានបញ្ញាត្តិពិសេសនៅក្នុងជំពូកទី៧)[59] ។

នៅក្នុងនីតិវិធីដែលច្បាប់បានតម្រូវ ការប្តឹងជំទាស់បានត្រូវបានធ្វើឡើងដោយការប្រកាសប្តឹងជាលាយល័ក្ខអក្សរនៅចំពោះមុខក្រឡាបញ្ជីនៃតុលាការជំនុំជម្រះលើរឿងក្តីដើម[60] ។ បន្ទាប់មកទើបតុលាការចាត់ចែងបញ្ជូនបណ្តឹង និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ដើម្បីចាត់ចែងតាមនីតិវិធី។ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែង បណ្តឹងនេះក៏អាចធ្វើដោយប្រកាសប្តឹងដោយផ្ទាល់មាត់បានដែល។ ករណីនេះក្រឡាបញ្ជីត្រូវធ្វើការកំណត់ហេតុបណ្តឹង ហើយកំណត់ហេតុនេះត្រូវចាត់ទុកជាបណ្តឹង។

[56] មាត្រា ៤០.១ នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[57] មាត្រា៣៩.៣ នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលិនមែនជាបណ្តឹង
[58] មាត្រា ៤១.១ នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[59] មាត្រា ៤២.២ នៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[60] មាត្រា៣០១.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

## កថាខណ្ឌទី២ ៖ ការសម្រេចសេចក្ដីកាត់ក្ដីដោយសាលក្រម ឬ សាលដីកា

នៅក្នុងរឿងក្ដីកាត់កាល់តាមរយៈពាក្យបណ្ដឹង តុលាការត្រូវសម្រេចសេចក្ដីដោយចេញនូវសាលក្រម ចំពោះតុលាការជាន់ទាប និង សាលដីកា ចំពោះតុលាការជាន់ខ្ពស់ ។ ចំពោះរឿងក្ដីកាត់កាល់តាមរយៈបណ្ដឹង តុលាការពុំអាចចេញសាលក្រមកំបាំងមុខលើដើមចោទ ឬសាលក្រមកំបាំងមុខចុងចម្លើយតាមក្រមនីតិវិធីរដ្ឋប្បវេណីបានទេ ដោយហេតុថា ចំពោះរឿងក្ដីកាត់កាល់ វាធ្វើឲ្យប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ភាគី យ៉ាងខ្លាំង ទើបមានការហាមឃាត់ចំពោះការអនុវត្តនៃការចេញនូវសាលក្រមកំបាំងមុខ ។

ហេតុដូចនេះមុននឹងតុលាការចេញសេចក្ដីសម្រេចចាំបាច់ត្រូវមានវត្តមានរបស់គូភាគី ដើម្បីធានានូវសិទ្ធិក្នុងការបញ្ចេញមតិយោបល់ សំណូមពរ ក៏ដូចជាដំណាក់កាលចុងក្រោយនៃការទាមទាររបស់ខ្លួនចំពោះមុខចៅក្រមជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះ ។ ម្យ៉ាងទៀត តុលាការក៏អាចពិចារណាបន្ថែមទៀត ទៅលើការអះអាងនោះដើម្បីចេញនៅសាលក្រមចុងក្រោយឲ្យមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ដល់ភាគីផ្អែកលើការស្រាវជ្រាវ និងការពិតជាក់ស្ដែង។ ជាពិសេសនៅក្នុងកាលបរិច្ឆេទលើកទី១នៃនីតិវិធីទាញហេតុផល តុលាការមិនអាចចេញសាលក្រមកំបាំងមុខ ហើយច្រានចោលការទាមទាររបស់ដើមចោទនៃរឿងក្ដីកាត់កាល់បានឡើយ។

### ក. សាលក្រមនៃពាក្យបណ្ដឹងកាត់កាល់

ចំពោះរឿងក្ដីទាក់ទងទៅនឹងបណ្ដឹងកាត់កាល់ តុលាការមិនត្រូវអនុញ្ញាតឲ្យចេញនូវសាលក្រមកំបាំងមុខមកអនុវត្តឡើយ ។

ជាគោលការណ៍ សាលក្រមមានអានុភាពទៅលើគូភាគីតែប៉ុណ្ណោះដែលហៅថាគោលការណ៍សាបេក្ខភាព ( ភាពមិនដាច់ខាត)[61] ។ ជាអញ្ញត្រកម្មចំពោះនីតិវិធីពិសេស សាលក្រមនៃបណ្ដឹងទាក់ទង ទៅនឹងឋានៈបុគ្គលត្រូវបានពង្រីកវិសាលភាពដល់តតិយជន។

### ខ. បណ្ដឹងឧបាស្រ័យ

ក្រោយពេលដែលតុលាការចេញសាលក្រម នៃបណ្ដឹងទាក់ទងទៅនឹងការកាត់កាល់រួចហើយ ភាគីនៃបណ្ដឹងអាចមានសិទ្ធក្នុងការប្ដឹងឧបាស្រ័យមុនពេលដែលសាលក្រមនោះចូលជាស្ថាពរ ។ ការប្ដឹងឧបាស្រ័យនេះគឺវាមានលក្ខណៈដូចនីតិវិធីបណ្ដឹងរដ្ឋប្បវេណីដែលគឺភាគីត្រូវបានធ្វើតាមរយៈបណ្ដឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ ដើម្បីទទួលបានចំណាត់ការបន្តលើសេចក្ដីវិនិច្ឆ័យរបស់តុលាការសាលាដំបូង ។ បណ្ដឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងរយៈពេល ១(មួយ)ខែ ដោយចាប់គិតពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រម ទៅកាន់សាលាដំបូងដែលចេញសាលក្រមនោះ។

[61] មាត្រា ១៩៨ កថាខណ្ឌទី១ នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

ក្នុងករណីនេះតុលាការដើមត្រូវតែផ្ញើរឲ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ (សាលាឧទ្ធរណ៍) ហើយសាលាឧទ្ធរណ៍មានសមត្ថកិច្ចនៅក្នុងការពិនិត្យ និងសម្រេចអំពីសាលក្រមរបស់សាលាដំបូង ។ បើសាលាឧទ្ធរណ៍ទទួលស្គាល់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍ នោះសាលាឧទ្ធរណ៍ នឹងចេញដីកាលុបចោលនូវសាលក្រមសាលាដំបូង និងចេញនូវសេចក្ដីសម្រេចថ្មី ។ សាលដីការបស់សាលាឧទ្ធរណ៍ដែលពុំទាន់ចូលជាស្ថាពរ ភាគីដែលចាញ់ក្ដីអាចដាក់ពាក្យបណ្ដឹងសាទុក្ខជាមួយក្រឡាបញ្ជីដែលកាន់សំណុំរឿងនៅសាលាឧទ្ធរណ៍ទៅតុលាការកំពូលក្នុងរយៈពេល ១(មួយ)ខែ ចាប់គិតពីថ្ងៃទទួលបានការបញ្ជូនសាលដីការបស់សាលាឧទ្ធរណ៍។

# ជំពូក៣
# អានុភាពនៃការកោត់កាល់

# ជំពូកទី៣

# អានុភាពនៃការកាត់កាល់

បន្ទាប់ពីរឿងក្តីកាត់កាល់ត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចចុងក្រោយ និង បានចូលជាស្ថាពរ នឹងមានអានុភាពអនុវត្ត ដោយបង្កើតនូវអានុភាពនៅលើទំនាក់ទំនងគិតយុត្តមួយចំនួនដូច

ញាតិភាព (ផ្នែកទី១) សន្តតិកម្ម (ផ្នែកទី២) និងសិទ្ធិ និងករណីផ្សេងៗទៀត នៃកូនសុំ និងជនដែលធ្លាប់ជាឪពុកម្តាយចិញ្ចឹម។

## ផ្នែកទី១៖ ញាតិភាព

នៅពេលសុំកូនត្រូវបានបញ្ចប់ដោយការកាត់កាល់ វាបណ្តាលឲ្យមានអានុភាពនៃទំនាក់-ទំនងញាតិនៃភាគីទាំងសងខាងនៃសុំកូននោះ ពោលគឺ ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹមនិងញាតិភាពរវាង កូនចិញ្ចឹម និងឪពុកម្តាយបង្កើត ។ ការបញ្ចប់ទំនាក់ទំនងញាតិក្រោយការកាត់កាល់មានភាពខុសគ្នារវាង ការបញ្ចប់ញាតិភាពនៃសុំកូនធម្មតា ( កថាខណ្ឌទី១ ) និងការបញ្ចប់ញាតិភាពនៃសុំកូនពេញលេញ (កថាខណ្ឌទី២) ។

### កថាខណ្ឌទី១ ញាតិភាពនៃសុំកូនធម្មតា

#### ក. ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

សុំកូនធម្មតាត្រូវបានបង្កើតឡើងដោយពុំបានកាត់ផ្តាច់ញាតិរវាងកូនចិញ្ចឹម និងឪពុកម្តាយបង្កើតនោះទេ ។ ដូចនេះ ការកាត់កាល់សុំកូនធម្មតា ក៏មិន សូវបង្កើតអានុភាពអ្វីចំពោះទំនាក់ទំនងញាតិជាមួយឪពុកម្តាយបង្កើតដែរ ក្រៅពីអំណាចមេបាចំពោះកូនចិញ្ចឹមជាអនីតិជនតែប៉ុណ្ណោះ។ ក្នុងករណីដែលកូនចិញ្ចឹមជាអនីតិជន នៅពេលមានការកាត់កាល់សុំកូនធម្មតា អំណាចមេបាត្រូវផ្ទេរទៅឪពុកម្តាយបង្កើតវិញ តែប្រសិនបើឪពុកម្តាយបង្កើតបានលែងលះគ្នា ករណីនេះឪពុកម្តាយត្រូវពិភាក្សាគ្នា បើមិនអាចសម្រេចបានទេតុលាការ ត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា[62]។

មួយវិញទៀត ចំពោះនាមត្រកូលរបស់កូនសុំ ប្រសិនបើបានដូរនាមត្រកូលពេលសុំកូន កូនសុំអាចទទួលវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ដោយនេះជាការផ្តល់ជម្រើសចំពោះនាមត្រកូលកូនសុំ។[63]

[62] មាត្រា ១០២៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[63] កថាខណ្ឌទី២ នៃមាត្រា ១០៣២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

**ខ. ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹម**

នៅក្នុងរឿងក្ដីកាត់កាល់កូនសុំធម្មតា ចំពោះទំនាក់ទំនងញាតិភាពរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹម ក្រោយពេលដែលសេចក្ដីសម្រេចមានអានុភាពគតិយុត្ត នោះការកាត់កាល់សុំកូនធម្មតាជាមូលហេតុនាំឲ្យបញ្ចាប់នូវញាតិភាពរវាង ឪពុកម្ដាយចិញ្ចឹម និងកូនចិញ្ចឹម ។ អានុភាពទាំងឡាយនៃការកាត់កាល់ ត្រូវបានបញ្ចាប់ឆ្ពោះទៅកាន់អនាគតដោយការកាត់កាល់ មានន័យថា អានុភាព នៃការកាត់កាល់មានអានុភាពតែទៅអនាគតតែប៉ុណ្ណោះ គ្មានអានុភាពប្រតិសកម្មនោះទេ[64]។

ការកាត់កាល់ មិនត្រឹមតែបញ្ចប់ញាតិភាពរវាងកូនចិញ្ចឹម និងឪពុកម្ដាយចិញ្ចឹមនោះទេ វាក៏បញ្ចប់ញាតិភាពមួយចំនួនដូចតទៅ៖

- បើកូនចិញ្ចឹមមានសហព័ទ្ធ ញាតិភាពរវាងសហព័ទ្ធរបស់កូនចិញ្ចឹម និងឪពុកម្ដាយចិញ្ចឹមក៏ត្រូវរលត់។ លើសពីនេះ ញាតិភាពរវាងសហព័ទ្ធរបស់កូនចិញ្ចឹម និងញាតិលោហិតនៃឪពុកម្ដាយចិញ្ចឹមក៏ត្រូវបានរលត់ផងដែរ។
- បើកូនចញ្ចឹម មានបច្ឆាញាតិផ្ទាល់ដូចជាកូន និងចៅជាដើម ញាតិភាពរវាងបច្ឆាញាតិផ្ទាល់របស់កូនចិញ្ចឹម និងឪពុកម្ដាយចិញ្ចឹមត្រូវបានរលត់។ បន្ថែមពីនេះ ញាតិភាពរវាងបច្ឆាញាតិផ្ទាល់របស់កូននោះ និងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះក៏ត្រូវរលត់ផងដែរ។
- បើបច្ឆាញាតិផ្ទាល់របស់កូនចិញ្ចឹមមានសហព័ទ្ធ ញាតិភាពរវាងសហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ និងឪពុកម្ដាយចិញ្ចឹមត្រូវរលត់។ ម៉្យាងទៀត ញាតិភាពរវាងសហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នេះ និងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ ក៏ត្រូវរលត់ផងដែរ។

លើសពីនេះទៅទៀត នាមត្រកូលកូនសុំ ប្រសិនបើបានដូរនាមត្រកូលពេលសុំកូន កូនសុំអាចទទួលបានវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បានតាមជម្រើសឲ្យកូនចិញ្ចឹម[65]។

**កថាខណ្ឌទី២ ញាតិភាពនៃសុំកូនពេញលេញ**

**ក. ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត**

យើងដឹងហើយថា ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើតត្រូវបានបញ្ចប់ នៅពេលដែលសុំកូនពេញលេញត្រូវបានបង្កើត ។ ផ្ទុយទៅវិញ ទំនាក់ទំនងញាតិភាពរបស់កូនចិញ្ចឹម និង

[64] មាត្រា ១០៣២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[65] មាត្រា១០៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

ឪពុកម្តាយបង្កើតនឹងត្រូវបានបង្កើតឡើងសារជាថ្មី នៅពេលសុំកូនពេញលេញត្រូវបានបញ្ចប់តាមការកាត់កាល់។ មិនតែប៉ុណ្ណោះ ញាតិភាពរវាងកូនចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយបង្កើតក៏ត្រូវបានបង្កើតឡើងជាថ្មីផងដែរ។ វានឹងមាន[66]។

មួយវិញទៀត នៅក្នុងករណីដែលការកាត់កាល់កើតចេញពីមូលហេតុដែលឪពុកម្តាយចិញ្ចឹមបានបំពានផលប្រយោជន៍ដល់កូនសុំ ហើយឪពុកម្តាយបង្កើត គ្មានលទ្ធភាពនៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឲ្យបានសមរម្យ ឬឪពុកម្តាយបង្កើតបានស្លាប់បាត់បង់ជីវិត តុលាការអាចសម្រេចព្យួរ ឬដកហូតអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម[67]ហើយជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញ ដើម្បីឲ្យសុំកូនបន្តនូវសិទ្ធិទទួលបានអាហារកាតព្វកិច្ច និងសិទ្ធិផ្នែកសន្តតិកម្មជាអាទិ៍ ជាមួយនឹងឪពុកម្តាយចិញ្ចឹម ។ នេះប្រសិនបើកូនសុំជាអនីតិជន ។

ចំពោះនាមត្រកូល នៃកូនសុំក៏ត្រូវបានផ្លាស់ប្តូរដែរ ព្រោះថាដូចយើងបានដឹងស្រាប់ហើយនាមត្រកូលរបស់កូនសុំត្រូវបានផ្លាស់ប្តូរ ដោយយកតាមនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមនៅពេលបង្កើតសុំកូនពេញលេញ ។ ដូចនេះនៅពេលសុំកូនពេញលេញបានបញ្ចប់នោះ នាមត្រកូលនៃសុំចិញ្ចឹមត្រូវប្តូរដោយយកនាមត្រកូលរបស់ឪពុកម្តាយបង្កើតវិញ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ច្បាប់នៅតែទុកជម្រើសដល់ភាគីសុំចិញ្ចឹមក្នុងការប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនផងដែរ។

### ខ. ញាតិភាពនៃកូនសុំ និងឪពុកម្តាយចិញ្ចឹម

ក៏ដូចគ្នាការកាត់កាល់សុំកូនធម្មតាដែរ ការកាត់កាល់សុំកូនពេញលេញ បានបញ្ចប់ទំនាក់-ទំនងញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ក្រោយពេលដែលសាលក្រម ឬសាលដីកាចូលស្ថាពរ ហើយញាតិភាពដូចខាងក្រោម ក៏បញ្ចប់ផងដែរ។

- បើកូនចិញ្ចឹមមានសហព័ទ្ធញាតិភាពរវាងសហព័ទ្ធរបស់កូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹម និងញាតិលោហិតនៃឪពុកម្តាយចិញ្ចឹមនោះ ក៏ត្រូវរលត់ដែរ។
- បើកូនចិញ្ចឹមនោះមានបច្ឆាញាតិផ្ទាល់ដូចជាកូន និងចៅ ញាតិភាពរវាងបច្ឆាញាតិផ្ទាល់របស់កូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹម និងញាតិលោហិតនៃឪពុកម្តាយចិញ្ចឹមនោះ ក៏ត្រូវបានរលត់ដែរ។

[66] មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧

[67] មាត្រា១០៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- បើបច្ឆាញាតិផ្ទាល់របស់កូនចិញ្ចឹមមានសហាព័ទ្ធ ញាតិភាពរវាងសហាព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ និងឪពុកម្ដាយចិញ្ចឹម និងញាតិលោហិតនៃឪពុកម្ដាយចិញ្ចឹមនោះ ត្រូវរលត់ដែរ។

## ផ្នែកទី២ សន្តតិកម្ម

ស្មុំកូនត្រូវបានបញ្ចប់តាមរយៈការកាត់កាល់ ដែលវាបណ្ដាលឲ្យមានអានុភាពទៅលើទំនាក់ទំនងសិទ្ធិរវាងកូនចិញ្ចឹម និងឪពុកម្ដាយចិញ្ចឹម និងរវាងកូនចិញ្ចឹម និងឪពុកម្ដាយបង្កើត ក្នុងការទទួលបាននូវទ្រព្យសម្បត្តិ នៅដែលពេលភាគីណាម្ខាងទទួលមរណៈភាព ។ នេះជាសិទ្ធិក្នុងការទទួលបាននូវសន្តតិកម្ម។នៅក្នុងផ្នែកនេះ យើងធ្វើការបែងចែកជា ២ គឺ ករណីសន្តតិកម្មរបស់ស្មុំកូនធម្មតា (កថាខណ្ឌទី១) និង ករណីសន្តតិកម្មរបស់ស្មុំកូនពេញលេញ។

### កថាខណ្ឌទី១ កូនស្មុំធម្មតា

នៅពេលដែលស្មុំកូនធម្មតាមានអានុភាព ការទទួលសន្តតិកម្មរបស់កូនសុំ គឺទទួលបាននូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្នុងទ្រព្យសម្បត្តិរបស់ឪពុកម្ដាយចិញ្ចឹម និងឪពុកម្ដាយបង្កើត[68]។ ក៏ប៉ុន្តែនៅពេលដែលទំនាក់ទំនងស្មុំកូនធម្មតាត្រូវបានបញ្ចប់តាមរយៈការកាត់កាល់ នោះវាបានធ្វើឲ្យទំនាក់ទំនងនៃឪពុកម្ដាយចិញ្ចឹម ជាមួយនឹងកូនសុំក៏ត្រូវបានបញ្ចាប់ដូចគ្នា ។ កូនសុំត្រូវបានបញ្ចាប់នូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្រោមមរតករបស់ជនដែលធ្លាប់ជាឪពុកម្ដាយចិញ្ចឹម ។ កូនសុំពុំមានសិទ្ធិនៅក្នុងការទទួលនៅចំណែកមរតករបស់បុគ្គលដែលធ្លាប់ជាឪពុកម្ដាយចិញ្ចឹមរបស់ខ្លួន ដូចកូនបង្កើតនោះទេ។ [69]

ក៏ប៉ុន្តែទំនាក់ទំនងនៃកូនសុំ ជាមួយឪពុកម្ដាយបង្កើត ត្រូវបានបង្កើតឡើងវិញ ដូចនេះកូនសុំគាត់មានសិទ្ធិគ្រប់គ្រាន់នៅក្នុងការទទួលចំណែកមរតករបស់ឪពុកម្ដាយបង្កើតវិញ ក្នុងនាមជាសន្តតិជនដែលមានលំដាប់ទី១ ដែលត្រូវទទួលសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្រោមមរតរបស់ឪពុកម្ដាយបង្កើតរបស់ខ្លួន។

### កថាខណ្ឌទី២ ស្មុំកូនពេញលេញ

នៅពេលដែលស្មុំកូនពេញលេញមានអានុភាព ការទទួលសន្តតិកម្មរបស់កូនសុំ គឺទទួលបាននូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្នុងទ្រព្យសម្បត្តិរបស់ឪពុកម្ដាយចិញ្ចឹម ។ ក៏ប៉ុន្តែ

---

[68] ស្មុំកូនធម្មតា គឺពុំបានកាត់ផ្ដាច់នៅទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចរវាងឪពុកម្ដាយបង្កើត ជាមួយកូនសុំនោះឡើយ។ ដូចនេះនៅពេលដែលទំនាក់ទំនងស្មុំកូនធម្មតា កើតឡើង កូនសុំអាចមានសិទ្ធិទទួលមរតក ទាំងឪពុកម្ដាយចិញ្ចឹម និងឪពុកម្ដាយបង្កើត។

[69] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នៅពេលដែលទំនាក់ទំនងសុំកូនពេញលេញត្រូវបានបញ្ចប់តាមរយៈការកាត់កាល់ នោះវាបានធ្វើឲ្យទំនាក់ទំនងនៃឪពុកម្ដាយចិញ្ចឹម ជាមួយនឹងកូនសុំក៏ត្រូវបានបញ្ចាប់ដូចគ្នា ។ កូនសុំត្រូវបានបញ្ចាប់នូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្រោមមរតករបស់ជនដែលធ្លាប់ជាឪពុកម្ដាយចិញ្ចឹម។ កូនសុំពុំមានសិទ្ធិនៅក្នុងការទទួលនៅចំណែកមរតករបស់បុគ្គលដែលធ្លាប់ជាឪពុកម្ដាយចិញ្ចឹមរបស់ខ្លួន ដូចកូនបង្កើតនោះទេ ។[70]

ក៏ប៉ុន្តែទំនាក់ទំនងនៃកូនសុំ ជាមួយឪពុកម្ដាយបង្កើត ត្រូវបានបង្កើតឡើងវិញ ដូចនេះកូនសុំគាត់មានសិទ្ធិគ្រប់គ្រាន់នៅក្នុងការទទួលចំណែកមរតករបស់ឪពុកម្ដាយបង្កើតវិញ ក្នុងនាមជាសន្តតិជនដែលមានលំដាប់ទី១ ដែលត្រូវទទួលសិទ្ធិ និងករណីកិច្ចទាំងអស់ដែលស្ថិតនៅក្រោមមរតករបស់ឪពុកម្ដាយបង្កើតរបស់ខ្លួន។

## ផ្នែកទី៣ សិទ្ធិ និងករណីកិច្ចផ្សេងៗទៀត

នៅពេលដែលការកាត់កាល់សុំកូនមានអានុភាព នោះវានឹងធ្វើឲ្យទំនាក់ទំនងនៃញាតិត្រូវបានកាត់ផ្ដាច់រវាងកូនចិញ្ចឹម និងឪពុកម្ដាយចិញ្ចឹម។ ដូចនេះសិទ្ធិ និងករណីកិច្ចមួយចំនួនក៏ត្រូវបានកាត់ផ្ដាច់ដូចគ្នា។ ជាក់ស្តែងដូចជា សិទ្ធិ និងករណីកិច្ច ពាក់ព័ន្ធទៅនឹង អាហារកាតព្វកិច្ច(កថាខណ្ឌទី១) និង អំពើអនីត្យានុកូល (កថាខណ្ឌទី២) ។

### កថាខណ្ឌទី១ អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច ជាកិច្ចដែលត្រូវតែបំពេញតាមច្បាប់ ឬតាមសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់ៗ ឬច្រើននាក់ផ្ដល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា[71]។ ការផ្ដល់ជូននៅអាហារកាតព្វកិច្ច គឺអាចផ្ដល់បានតែចំពោះកូនដែលជាអនីតិជនតែប៉ុណ្ណោះ កូនជាអនីតិជនគាត់ពុំអាចមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការរួចពីអាហារកាតព្វកិច្ចដែលត្រូវបំពេញដោយអំណាចមេបានោះទេ[72]។

នៅពេលដែលសុំកូនត្រូវបានបញ្ចប់ដោយការកាត់កាល់ ករណីយកិច្ចរបស់បុគ្គលដែលធ្លាប់ជាឪពុកម្ដាយចិញ្ចឹម ក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់កូនចិញ្ចឹមនោះ ក៏ត្រូវបានបញ្ចាប់ផងដែរ។ ដូចនេះក្នុងករណីក្រោយពេលកាត់កាល់ អាហារកាតព្វកិច្ចសម្រាប់កូនចិញ្ចឹម ត្រូវជាបន្ទុករបស់ឪពុកម្ដាយបង្កើត ទោះបីក្នុងករណីសុំកូនធម្មតាក្តី សុំកូនពេញលេញក្តី ។ ប៉ុន្តែ ប្រសិនបើឪពុក

[70] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[71] សន្ទានុក្រម ក្រមរដ្ឋប្បវេណី លេខ២០២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[72] មាត្រា ១១៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ម្តាយបង្កើតនៃកូនចិញ្ចឹម គ្មានលទ្ធភាព ឬ មរណភាពនោះ តុលាការ ជាអ្នកវិនិច្ឆ័យអំពីជនដែលត្រូវទទួលបន្ទុកអាហារកាតព្វកិច្ចដល់កូនសុំនោះ[73]។

### កថាខណ្ឌទី២ អំពើអនីត្យានុកូល និងអភ័យឯកសិទ្ធិគ្រួសារ

#### ក. អំពើអនីត្យានុកូល

អំពើអនីត្យានុកូលគឺជាអំពើទាំងឡាយណាដែលបុគ្គលបានបំពានដោយខុសច្បាប់លើសិទ្ធិ ឬផលប្រយោជន៍អ្នកដ៏ទៃដោយកំហុសចេតនា ឬអចេតនា[74] ។ ក្នុងករណីដែលអំពើរបស់កូនចិញ្ចឹម ជាអនីតិជនដែលបានប្រព្រឹត្ត ហើយបានធ្វើឲ្យខូចប្រយោជន៍របស់ជនម្ខាងទៀត ក៏ប៉ុន្តែទង្វើរនេះ បានធ្វើបន្ទាប់ពីពេលកាត់កាល់រួច នោះវាលែងជាបន្ទុកនៃការទទួលខុសត្រូវរបស់ឪពុកម្តាយចិញ្ចឹម ក្នុងការសងការខូចខាតឡើយ។ ព្រោះថាសិទ្ធិ និងករណីយកិច្ចរបស់កូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានកាត់ផ្តាច់ទាំងស្រុងនៅក្រោយការកាត់កាល់។

#### ខ. អភ័យឯកសិទ្ធិគ្រួសារ

មួយវិញទៀត នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥៥ បានកំណត់ទាក់ទងទៅនឹងអភ័យឯកសិទ្ធិគ្រួសារ ដែលបានបញ្ញត្តិពាក់ព័ន្ធទៅនឹងការមិនអាចផន្ទាទោសព្រហ្មទណ្ឌបានទេក្នុងករណី ដែលទាក់ទងទៅនឹងការលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬ បច្ឆាញាតិ នៃឪពុកម្តាយចិញ្ចឹម ក៏ប៉ុន្តែនៅក្រោយពេលកាត់កាត់រួចរាល់ ទំនាក់ទំនងនៃកូនសុំ និងឪពុកម្តាយចិញ្ចឹមត្រូវបានកាត់ផ្តាច់ទាំងស្រុង ដូចនេះ មាត្រា៣៥៥ នៃក្រមព្រហ្មទណ្ឌពុំអាចមានអានុភាពគតិយុត្តអនុវត្តចំពោះករណីនេះឡើយ ។ ក្នុងករណីនេះប្រសិនកូនសុំប្រព្រឹត្តបទល្មើសលួចទ្រព្យសម្បត្តិរបស់ជនដែលធ្លាប់ជាឪពុកម្តាយចិញ្ចឹម នោះកូនសុំក៏ត្រូវទទួលទោសបញ្ញត្តិដូចគ្នាទៅនឹងជនទូទៅដែល[75]។

[73] មាត្រា ១១៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[74] សន្ទានុក្រមលេខ ២០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[75] មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទនៃ "ការកាត់កាល់" រួចមក ក្រុមរបស់យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថា ៖ការសិក្សាទៅលើប្រធានបទនៃ "ការកាត់កាល់" គឺពិតជាមានសារៈសំខាន់ណាស់ ដែល នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧បានកំណត់និយមន័យ[76]នៃពាក្យកាត់កាល់ថា ៖ ការកាត់កាល់គឺជាហេតុនៃការបញ្ចប់នូវទំនាក់ទំនងញាតិភាពរវាង ឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលជាហេតុនាំឲ្យមានការកាត់ផ្តាច់នូវទំនាក់ទំនងនូវសិទ្ធិ និងកាតព្វកិច្ច ដូចជាអាហារកាតព្វកិច្ច[77] និងសន្តតិកម្ម[78]ជាដើម។

មួយវិញទៀតក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ នៅឆ្នាំ ២០០៧ បានបញ្ញត្តិទាក់ទងនឹងប្រភេទនៃការកាត់កាល់មាន២ ៖ការកាត់កាល់សុំកូនពេញលេញ និងការកាត់កាល់សុំកូនធម្មតា

ការកាត់កាល់សុំកូនពេញលេញ គឺជាការកាត់ផ្តាច់នូវទំនាក់ទំនងអចិន្ត្រៃយ៍ និងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាង កូនសុំ និងឪពុកម្តាយចិញ្ចឹម ។ ហើយបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ និងបង្កើតសិទ្ធិ និងកាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើតឬអ្នកអាណាព្យាបាល របស់កូននោះសារជាថ្មី[79]។

ចំនែកឯការកាត់កាល់សុំកូនធម្មតា គឺជាការកាត់ផ្តាច់នូវទំនាក់ទំនងនូវសិទ្ធិ និងកាតព្វកិច្ចរវាងកូនសុំ ដែលអាចជា នីតិជន ឬអនីតិជន ជាមួយនឹង ឪពុកម្តាយចិញ្ចឹម ហើយបង្កើតឡើងវិញជាថ្មីនូវទំនាក់ទំនងនៃសិទ្ធិ និងកាតព្វកិច្ចរវាងកូន និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលនៃកូននោះ។

ការកាត់កាល់ អាចមានអានុភាពគតិយុត្តអនុវត្តទៅបានលុះត្រាណាតែមានមូលហេតុសមរម្យ និងច្បាស់លាស់ និងត្រូវធ្វើឡើងដោយអ្នកមានសិទ្ធិដែលបានទទួលស្គាល់ដោយច្បាប់ ។ មូលហេតុនៃកាត់កាល់ និងអ្នកមានសិទ្ធិក្នុងការកាត់កាល់ ប្រែប្រួលទៅតាមប្រភេទនៃទំនាក់ទំនងឪពុកម្តាយ និងកូននីមួយៗ។ ចំណែកឯ នីតិវិធីនៃការកាត់កាល់ ដូចដែលក្រុមរបស់យើងខ្ញុំបានធ្វើការបកស្រាយពីខាងលើ នៅក្នុងនីតិវិធីនៃការកាត់កាល់ គឺយកបានធ្វើឡើងជា ២ របៀប គឺ៖ ការកាត់កាល់ដែលកើតឡើងដោយការព្រមព្រៀង គឺយើងធ្វើឡើងតាមរយៈពាក្យសុំ ទៅតុលាការ។ រីឯ ការកាត់កាល់ដែលកើតឡើងដោយច្បាប់កំណត់ គឺយើងធ្វើឡើងតាមរយៈពាក្យបណ្តឹងទៅតុលាការ។លើសពីនេះទៅទៀត អានុភាពក្រោយការកាត់កាល់ គឺមានអានុភាពទៅលើ ទំនាក់ទំនង

[76] មាត្រា៩៩២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[77] អាហារកាតព្វកិច្ច៖ ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់មានកាតព្វកិច្ចជាមួយ បុគ្គលម្នាក់ឬច្រើននាក់ផ្តល់នូវទ្រព្យ ឬប្រាក់ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ។

[78] សន្តតិកម្ម៖ ជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជន ទៅឲ្យសន្តតិជនម្នាក់ឬច្រើននាក់ តាមឆន្ទះ ឬតាមច្បាប់។

[79] មាត្រា៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស

នៃញាតិ ដែល ធ្វើការកាត់ផ្តាច់នូវទំនាក់ទំនងនៃញាតិ រវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ និងបង្កើតនូវទំនាក់ទំនងញាតិជាថ្មីរវាង ឪពុកម្តាយបង្កើត ជាមួយកូន ឬអាណាព្យាបាល ជាមួយនឹងកូន។ មួយវិញទៀត ការកាត់កាល់ ក៏មានអានុភាពអនុវត្តទៅលើទ្រព្យសម្បត្តិ សន្តតិកម្ម អាហារកាតព្វកិច្ច រវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមដូចគ្នា ដែលត្រូវបានបញ្ចប់ និងបង្កើតសារជាថ្មីនូវទ្រព្យសម្បត្តិ សន្តតិកម្ម អាហារកាតព្វកិច្ច រវាងឪពុកម្តាយបង្កើត ជាមួយនឹងកូន ឡើងវិញជាថ្មី។

សរុបសេចក្តីមក ការកាត់កាល់ គឺធ្វើឡើងនូវក្នុងធាននូវផលប្រយោជន៍ នៃកូនសុំ ដែលទទួលរងនូវការបំពានផលប្រយោជន៍ ដោយការធ្វើបាបពីសំណាក់ឪពុកម្តាយចិញ្ចឹម ដោយការបោះបង់កូនសុំចូលដោយគំនិតទុច្ចរឹត ឬទទួលរងការបំពានផលប្រយោជន៍ធ្ងន់ធ្ងរពីសំណាក់ឪពុកម្តាយចិញ្ចឹម។ មួយវិញទៀត លទ្ធភាពនៃឪពុកម្តាយបង្កើត ក៏ជាកត្តាមួយដែលអាចធ្វើឲ្យមានការកាត់កាល់បានដែរ ។ ក៏ប៉ុន្តែបើយើងក្រឡែកទៅមើលសង្គមខ្មែរបច្ចុប្បន្ន ប្រជាពលរដ្ឋបានធ្វើការកាត់កាល់កូនរបស់ខ្លួនតាមរយៈបណ្តាញសារព័ត៌មាន ដូចជាកាសែត ទស្សនាវដ្តី ហើយខ្លះទៀតគឺធ្វើឡើងតាមការបង្ហោះ តាមបណ្តាញទំនាក់ទំនងសង្គម(ហ្វេសប៊ុក)ក្នុងគោលបំណងចង់ផ្តាច់នូវទំនាក់ទំនងញាតិ និងរួចផុតពីទំនួលខុសត្រូវផ្សេង ដែលបណ្តាលមកពីអំពើអនីត្យានុកូលរបស់កូនខ្លួន។ នៅក្នុងអត្ថន័យនេះ ការកាត់កាល់តាមរយៈបណ្តាញសារព័ត៌មាន ដូចជាកាសែតទស្សនាវដ្តី ឬតាមរយៈបណ្តាញទំនាក់ទំនងសង្គម(ហ្វេសប៊ុក)គឺពុំមានអនុភាពគតិយុត្តសម្រាប់អនុវត្តនោះទេ ។ ការកាត់កាល់ដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ យើងពុំបានកំណត់អំពី ៖ ការកាត់កាលកូនបង្កើតនោះទេ នេះបង្ហាញថាច្បាប់មិនបានអនុញ្ញាតអោយធ្វើការកាត់កាល់កូន បង្កើតនោះទេ ហើយការកាត់កាល់លើកូនសុំទាំងពីរប្រភេទខាងលើនេះ គឺមានបែបបទ និងនីតិវិធី ច្បាស់លាស់ដែលបានកំណត់ក្នុងច្បាប់ ដោយត្រូវធ្វើឡើងតាមរយៈតុលាការដែលមានសមត្ថកិច្ច និងសម្រេចអំពីការកាត់កាល់តាមរយៈសេចក្តីសម្រេច (ដីកាសម្រេច ឬ សាលក្រម) នៃតុលាការ ដែលមានសមត្ថកិច្ចនោះ ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាយបំភ្លឺ និងធ្វើសេចក្តីសន្និដ្ឋានលើប្រធានបទជារួមរួចមក ក្នុងនាមយើងខ្ញុំជានិស្សិត និងជាទំពាំងស្នងឫស្សីសម្រាប់ប្រទេសជាតិ យើងខ្ញុំសូមផ្តល់ជូននូវ អនុសាសន៍មួយចំនួន ដើម្បីជាគន្លឹះ និងជាការពង្រឹងនូវការអនុវត្ត និងជាការបណ្តុះនូវព័ត៌មានជូនទៅដល់ប្រជាពលរដ្ឋ ក្នុងការធានាឲ្យបាននូវការអនុវត្តត្រឹមត្រូវតាមស្មារតីនៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដូចខាងក្រោម៖

- បណ្តុះស្មារតីឲ្យប្រជាពលរដ្ឋបានយល់ឲ្យច្បាស់ ពាក់ព័ន្ធទៅនឹង ការកាត់កាល់ តាមរយៈការផ្សព្វផ្សាយ នៅក្នុងបណ្តាញសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ឬតាមបណ្តាញទំនាក់ទំនងសង្គម។
- បង្កើតនូវវគ្គអបរំ តាមរយៈសិក្ខាសាលា ឬវគ្គសិក្សាខ្លី អំពីគោលគំនិតនៃ មាត្រា ដែលបានចែងពី ការកាត់កាល់ ( ស៊ុំកូនធម្មតា ឬ ស៊ុំកូនពេញលេញ ) ដល់សិស្សនិស្សិត។
- ជម្រុញឲ្យមានការបកស្រាយច្បាស់លាស់អំពីខ្លឹមសារនៃការកាត់កាល់នេះ។
- ក្រសួងទទួលបន្ទុក ឬអង្គការវិជ្ជាជីវៈ គួរតែកំណត់ឲ្យបានច្បាស់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការកាត់កាល់ តាមរយៈការបង្កើតឲ្យមានន័យ សេចក្តីកំណត់មាត្រានីមួយៗ និងសេចក្តីពន្យល់ នៃក្រមរដ្ឋប្បវេណី។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### ❖ ច្បាប់ជាតិ

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១
- ច្បាប់ស្ដី "នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល" ឆ្នាំ២០១០
- ច្បាប់ស្ដីពី "នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង" ឆ្នាំ២០១០
- ច្បាប់ស្ដីពី "សុំកូនអន្តរប្រទេស" ឆ្នាំ២០០៩

### ❖ ច្បាប់អន្តរជាតិ

- អនុសញ្ញាទីក្រុងឡាអេស្ដីពី "ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស" ត្រូវបានផ្ដល់សច្ចាប័នយល់ព្រមដោយព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៧។
- អនុសញ្ញាស្ដីពី "សិទ្ធិកុមារ" ឆ្នាំ១៩៨៩

### ❖ លិខិតបទដ្ឋានគតិយុត្តជាតិ

- ប្រកាសស្ដីពី"ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្ដី និងមាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្ដីតុលាការក្រៅ
ពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្ដឹងរបស់ក្រសួងយុត្តិធម៌" ឆ្នាំ២០០៧

## ២. វចនានុក្រម និងសទ្ទានុក្រម

- វចនានុក្រម សម្ដេចសង្ឃរាជ ជួន ណាត ភាគ១ និង ២ ឆ្នាំ១៩៦៧
- វចនានុក្រមច្បាប់ អង់គ្លេស-ខ្មែរ របស់អង្គការមូលនិធិអាស៊ី បោះពុម្ព ឆ្នាំ១៩៩៧
- សន្ទានុក្រម នៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ឆ្នាំ១៩២០
- សន្ទានុក្រម នៃច្បាប់របស់ឯកឧត្តម ហ៊ីង ធីឫទ្ធិ បោះពុម្ពលើកទី៣ ឆ្នាំ២០១០

## ៣. សៀវភៅ និងឯកសារផ្សេងៗ

- សេចក្តីពន្យល់នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៩
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ៤ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១០
- សេចក្តីពន្យល់អំពី "ស៊ុំកូនក្នុងប្រទេស" របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០១៦
- មេរៀនស្តីពី "ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី"របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០១០
- តារាងប្រៀបធៀប ស៊ុំកូនពេញលេញ និងស៊ុំកូនធម្មតា របស់លោកស្រីមេធាវី **ទេព មុនល**
- កម្រងមេរៀនសង្ខេបស្តីពី នីតិរដ្ឋប្បវេណី របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១
- កំណត់ហេតុសិក្ខាសាលាស្តីអំពី "ស៊ុំកូនពេញលេញ និងស៊ុំកូនធម្មតា" ដោយក្រុមការងារ Jica នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំ២០១៧
- កំណត់ហេតុសិក្ខាសាលាស្តីអំពី អាពាហ៍ពិពាហ៍ និងគ្រួសារ

## ៤. បណ្តាញផ្សព្វផ្សាយ

- កិច្ចសម្ភាសន៍ជាមួយ លោកមេធាវី **អ៊ឹម ម៉ូលី** និងលោកមេធាវី **ស៊ីន់ សុជាតិ** ក្រោមប្រធានបទស្តីពី "ការកាត់កាល់"កម្មវិធី ច្បាប់ របស់ អគ្គនាយកដ្ឋានទូរទស្សន៍បាយ័នថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥

Website: https://youtu.be/KSS7Nzf6Qvg / https://youtu.be/Go9bttcnE8c

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ក្រមរដ្ឋប្បវេណី

**មាត្រា ១០០៦.–** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២

## សុំកូន

### កថាភាគទី ១

### សុំកូនពេញលេញ

**មាត្រា ១០០៧.–** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.–** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.–** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្តាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.-** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.-** ការបញ្ចប់ទំនាក់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.-** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្តាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។

**មាត្រា ១០១៦.-** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.-** អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយស្មុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.-** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃស្មុំកូនពេញលេញ

ប្រសិនបើបានបង្កើតស្មុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីស្មុំកូនឡើយ ។

**មាត្រា ១០១៩.-** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្ដីពីស្មុំកូនបាន ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

## កថាភាគទី ២
## ស្មុំកូនធម្មតា

**មាត្រា ១០២០.-** ពាក្យសុំនៃស្មុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតស្មុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាច

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.–** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹម មានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.–** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.–** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.–** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

នោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឳពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឳពុក ឬ ម្ដាយ ដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០២៥.-** សុំកូន រវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

**មាត្រា ១០២៦.-** អានុភាពនៃសុំកូនធម្មតា ចំពោះបុគ្គលភាព

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឳពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឳពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឳពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់

អាហារកាតព្វកិច្ច ។

**មាត្រា ១០២៧.–** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និង សហព័ទ្ធនោះ ។

**មាត្រា ១០២៨.–** ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្ដាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្ដាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

**មាត្រា ១០២៩.-** ការកាត់កាល់រវាងប្តីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្តីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្តាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្តីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្តីប្រពន្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

**មាត្រា ១០៣០.-** ការវិនិច្ឆ័យអំពីការកាត់កាល់ស៊ុំកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់ស៊ុំកូនបាន លុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយ និង កូន ។

**មាត្រា ១០៣១.-** មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃស៊ុំកូន អាចដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឱ្យមានការពិបាកក្នុងការបន្តស៊ុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា

១-អានុភាពទាំងឡាយនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនស្មុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃស្មុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតស្មុំកូនធម្មតា ត្រូវសរសេរការបង្កើតស្មុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

## ជំពូកទី ៥

## អំណាចមេបា

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.-** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយ

## គន្ថីទី ៩

## អវសានប្បញ្ញត្តិ

### ជំពូកតោល

### អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.- កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**

តរល.០៧១២.៦២២

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខ:៥៧៤ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**យុន ជិនគេន**

453/453

# សន្ទានុក្រម
# ផ្នែករដ្ឋប្បវេណី

ដកស្រង់ពី

**"សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី"**

ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
និង បោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ ២០០៧

ផ្សេងទៀត។ ឧ. ស្រែក្រោមមានសេរីភាព ខាងទទួលទឹកពីស្រែលើ។ ស្រែក្រោមហៅថា ស្រែបម្រើ ហើយស្រែលើហៅថា ស្រែប្រើ។

១៦៦. **ស្ថាប័នរដ្ឋបាល**
Eng. **a**dministrative governmental institution
Fr. **i**nstitution administrative

១-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកិច្ចការរដ្ឋបាលសាធារណៈ។
២-តាមក្រមរដ្ឋប្បវេណីនេះ មានន័យថា ស្ថាប័នសាធារណៈ ដែលច្បាប់ការងារប្រគល់អំណាចឱ្យ។

១៦៧. **សុំកូនធម្មតា**
Eng. **s**imple adoption
Fr. **a**doption simple

ការសុំកូន ដែលកូននោះអាចជាអនីតិជន ឬ នីតិជន ដោយមិនកាត់ផ្ដាច់ញាតិភាពពីឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

១៦៨. **សុំកូនពេញលេញ**
Eng. **f**ull adoption
Fr. **a**doption plénière

ការសុំអនីតិជន ដែលមានអាយុក្រោម៨ឆ្នាំយកធ្វើជាកូនសុំ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

១៦៩. **ស្វីការ**
Eng. **a**cceptance
Fr. **a**cceptation

ការសំដែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

# ក្រមនីតិវិធីរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

### ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

# ក្រម

# នីតិវិធីរដ្ឋប្បវេណី

# គន្ថីទី ២
# នីតិវិធីនៃការជម្រះក្តីលើកទី ១

## ជំពូកទី ១
## បណ្តឹង

**មាត្រា ៧៤.–** ផលប្រយោជន៍នៃបណ្តឹង

បណ្តឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង ដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម ។

**មាត្រា ៧៥.–** របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

១-ការប្តឹង ត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ទៅតុលាការ ។

២-នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។

៣-នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី ២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង ។

៤-ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវចាត់ជាឯកសារត្រៀមផងដែរ ។

**មាត្រា ៧៦.–** បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនៅពេលអនាគត

បណ្តឹងទាមទារការផ្តល់តាវកាលិកនៅពេលអនាគត អាចធ្វើឡើងបាន លុះត្រាតែមាន

# ច្បាប់
## ស្ដីពី
# នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី
# ដែលមិនមែនជាបណ្ដឹង

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឍរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅនៃច្បាប់នេះ**

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ២.- គោលបំណងនៃច្បាប់នេះ**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ**

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
### ផ្នែកទី ១
### សមត្ថកិច្ចសាលាជម្រះក្តី

**មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច**

១- រឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

២- សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ ។

## មាត្រា ៥.- ការកំណត់តុលាការដែលមានសមត្ថកិច្ច

១- ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបាន ដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ ។

២- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្តឹងឧបាស្រ័យបានឡើយ ។

## មាត្រា ៦.- ការចាត់ចែងរឿងក្តីខុសសមត្ថកិច្ច

១- ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

២- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលដាក់ពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

## មាត្រា ៧.- សមត្ថកិច្ចជាអាទិភាព និង ការផ្ទេរ

១- ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះ ត្រូវមានសមត្ថកិច្ច ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យដើម្បីចាត់ចែងរឿងក្តី តុលាការអាចផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៣- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ។

ROYAUME DU CAMBODGE * PALAIS ROYAL

**មាត្រា ៨.- ការពិនិត្យតស្លុតាងដោយឆន្ទានុសិទ្ធិ**

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

**មាត្រា ៩.- បណ្តឹងជំទាស់**

១- ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០.- អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍**

១- ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឲ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២- តុលាការដែលទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានឡើយ ។

៣- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ រឿងក្តីនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរចាត់ការតាំងពីដើម ។

៤- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរ ត្រូវបញ្ជូនសំណុំរឿងអំពីរឿងក្តីនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

## ផ្នែកទី ២
## រចនាសម្ព័ន្ធនៃតុលាការ

**មាត្រា ១១.- ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

១- នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២- ចំពោះរឿងក្តីដែលតុលាការយល់ឃើញថា គួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃជនពាក់ព័ន្ធ និង បញ្ហាផ្សេងទៀត ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL

Ksl

៣- ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ (បី) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤- ដីកាសម្រេចឲ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយយោងតាមកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

## មាត្រា ១២.- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវធ្វើជាសាធារណៈទេ ។

២- ការពិភាក្សាត្រូវបានបើក និងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣- ចៅក្រមម្នាក់ៗ ត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤- ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់ ។

## មាត្រា ១៣.- ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២- ចៅក្រមម្នាក់ៗ ក្នុងក្រុមប្រឹក្សាជំនុំជម្រះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

# ផ្នែកទី ៣

# ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួន

## មាត្រា ១៤.- ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួនរបស់ចៅក្រម ជាអាទិ៍

១- បញ្ញត្តិស្តីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និងការដកខ្លួនរបស់ចៅក្រម និង ក្រឡាបញ្ជីតុលាការនៅក្នុងផ្នែកទី ៣ (ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជំទាស់) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងបញ្ញត្តិនៃផ្នែកទី ៣ (ការបែងចែករឿងក្តី

និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និងបណ្តឹងដិតចិត្ត) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានយកមកអនុវត្ត ដោយយោងតាមកថាខណ្ឌទី ១ ខាងលើនេះ ។

## ជំពូកទី ៣
## ជនពាក់ព័ន្ធ

### មាត្រា ១៥.- ជនពាក់ព័ន្ធ

ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ជនដាក់ពាក្យសុំ ភាគីម្ខាងទៀតនៃពាក្យសុំ និងជនផ្សេងទៀត ដែលទទួលឥទ្ធិពលផ្ទាល់ដល់សិទ្ធិរបស់ខ្លួន ឬ ដល់ឋានៈរបស់ខ្លួនតាមផ្លូវច្បាប់ដោយដីកាសម្រេចអំពីរឿងក្តីនោះ អាចចូលរួមក្នុងនីតិវិធីនៃរឿងក្តីនោះ ក្នុងនាមជាជនពាក់ព័ន្ធនៅក្នុងរឿងក្តីនោះ ។

### មាត្រា ១៦.- សមត្ថភាពរបស់ជនពាក់ព័ន្ធ

ជនដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) ខាងលើនេះ ត្រូវតែជាបុគ្គលដែលអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ។

### មាត្រា ១៧.- សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី

១- បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចធ្វើសកម្មភាពនៃនីតិវិធីចាំបាច់ ដោយតាំងខ្លួនជាជនពាក់ព័ន្ធក្នុងនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះបាន ។

២- អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើសកម្មភាពនៃនីតិវិធីសុពលបានឡើយ ប្រសិនបើសកម្មភាពនោះមិនបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបានកំណត់ខាងក្រោមនេះ ៖

ក- ករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯកឯង ។

ខ- ករណីដែលអនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើសកម្មភាពពាក់ព័ន្ធនឹងឋានៈរបស់ខ្លួន ។

៣- បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ត្រូវយកមកអនុវត្តចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ ខាងលើនេះ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

៤- បញ្ញត្តិចាប់ពីមាត្រា ៣៣ (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) ដល់មាត្រា ៣៨ (ការអនុវត្តដូចគ្នាចំពោះអ្នកតំណាងនៃនីតិបុគ្គល) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមត្ថភាពអាចធ្វើសកម្មភាពនៃនីតិវិធីសុពលក្នុងនាមជាជនពាក់ព័ន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ និង ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើនេះ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

## មាត្រា ១៨.- សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ

១- ជនពាក់ព័ន្ធអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីទាំងអស់ ដោយខ្លួនឯងផ្ទាល់ ឬ ធ្វើសកម្មភាពនោះ ដោយឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង ។

២- ទោះបីជនពាក់ព័ន្ធបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ជននោះអាចធ្វើសកម្មភាពទាក់ទងនឹងនីតិវិធីបានដែរ ។

## មាត្រា ១៩.- លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

១- អ្នកតំណាងដោយអាណត្តិដែលកំណត់ក្នុងមាត្រា ១៨ (សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ត្រូវតែជាមេធាវី ឬ ជនដែលបានទទួលនូវការអនុញ្ញាតពីតុលាការ ។

២- តុលាការអាចលុបចោលការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដែលផ្តល់ជនក្រៅពីមេធាវីនៅពេលណាក៏បាន ។

## មាត្រា ២០.- ការបញ្ជាក់នូវសិទ្ធិតំណាងដោយអាណត្តិ

សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ដែលត្រូវបានជ្រើសតាំងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១៨ (សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ) នៃច្បាប់នេះ ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះ

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

**មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី**

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

**មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី**

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីកាតី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

**មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី**

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី)ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឲ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

**មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី**

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

**មាត្រា ២៧.- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ**

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

**មាត្រា ២៨.- ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ**

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

**មាត្រា ២៩.-ការណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន**

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

**មាត្រា ៣០.- ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង**

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និង ចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរចម្លើយ ។

៣- ក្នុងករណីដែលបានដឹងតាមមុខនាទីរបស់ខ្លួនថា ករណីដែលតំណាងអយ្យការអាចដាក់ពាក្យសុំ ឬ ទាមទារបានកើតឡើង តុលាការ ស្ថាប័នរដ្ឋផ្សេងទៀត និង មន្ត្រីស្ថាប័នទាំងនោះ និង តំណាងអយ្យការ ត្រូវជូនដំណឹងអំពីករណីនោះទៅតំណាងអយ្យការអមតុលាការដែលមានសមត្ថកិច្ច ។

**មាត្រា ៣១.- ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍**

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ក្នុងចំណោមជនពាក់ព័ន្ធដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) នៃច្បាប់នេះ ចូលរួមក្នុងនីតិវិធីបាន ។

២- ជនដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចចូលរួមក្នុងនីតិវិធីបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ៣២.- ការទទួលបន្តនូវនីតិវិធី**

១- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬមូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះ តាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីនោះបាន ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះតាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ទទួលបន្តនូវនីតិវិធីនោះបាន ។

**មាត្រា ៣៣.- ការមើលសំណុំរឿង ជាអាទិ៍**

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យមើល ឬឲ្យថតចម្លងសំណុំរឿង ឬ អាចបង្គាប់ឲ្យក្រឡាបញ្ជីប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឯកសារដកស្រង់នៃសំណុំរឿង ឬ លិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តីបាន តាមពាក្យសុំរបស់ជនពាក់ព័ន្ធនឹងរឿងក្តីនោះ ដោយឲ្យបង់សោហ៊ុយ ។

២- ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ទាមទារឲ្យប្រគល់នូវឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃលិខិតដីកាសម្រេច ឬ ទាមទារឲ្យប្រគល់នូវលិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តី ក្រឡាបញ្ជីត្រូវប្រគល់ឯកសារ ឬ លិខិតនោះ ។

**មាត្រា ៣៤.- ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី**

១- បញ្ញត្តិស្តីពីកាលបរិច្ឆេទ អំឡុងពេល វិធីធ្វើសេចក្តីបញ្ជាក់ដំបូង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

២- បញ្ញត្តិស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ការសាកសួរសាក្សី ការសាកសួរភាគីកោសលវិច័យ ការត្រួតពិនិត្យ និងភស្តុតាងជាឯកសារ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីដែលកំណត់ក្នុងច្បាប់នេះ លើកលែងតែមានភាពផ្ទុយគ្នានឹងលក្ខណៈនៃនីតិវិធីនេះ ។

## ជំពូកទី ៦
## ការសម្រេចសេចក្តី

**មាត្រា ៣៥.- វិធីសម្រេចសេចក្តី**

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ ។

**មាត្រា ៣៦.- ការជូនដំណឹងអំពីដីកាសម្រេច**

ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ។ ការជូនដំណឹងអំពីដីកាសម្រេចនេះត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬ ការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

### មាត្រា ៣៧.- ការចូលជាស្ថាពរ និង ការបង្កើតអានុភាពនៃដីកាសម្រេច

១- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលកំណត់ក្នុងមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃច្បាប់នេះ ។

២- ការចូលជាស្ថាពរនៃដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះ ។

៣- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

### មាត្រា ៣៨.- អានុភាពអនុវត្តនៃដីកាសម្រេច

ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីយកិច្ចចុះបញ្ជី ឬ ផ្តល់គាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៧
## បណ្តឹងឧបាស្រ័យ

### មាត្រា ៣៩.- បណ្តឹងជំទាស់

១- បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

២- ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលបានដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន ។

### មាត្រា ៤០.- អំឡុងពេលសម្រាប់ប្តឹងជំទាស់

១- ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលនូវការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

ROYAUME DU CAMBODGE * SECRETARIAT DU PALAIS

២- ប្រសិនបើជនដែលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលនូវការជូនដំណឹងអំពីដីកាសម្រេច ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៦ (ការជូនដំណឹងអំពីដីកាសម្រេច) នៃច្បាប់នេះទេ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលជនដាក់ពាក្យសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

៣- ចំពោះរឿងក្តីដែលបានចាប់ផ្តើមឡើងដោយចន្ទានុសិទ្ធិ អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវគណនាពីថ្ងៃដែលជនបានទទួលក្រោយគេនូវការជូនដំណឹង បានទទួលដំណឹងនោះ ។

៤- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤១.- ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត

១- ក្នុងករណីដែលជនដែលអាចប្តឹងជំទាស់ មិនបានគោរពតាមអំឡុងពេលសម្រាប់ប្តឹងជំទាស់ ដោយគ្មានកំហុសរបស់ខ្លួន ជននោះអាចប្តឹងជំទាស់បានក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ ក្រោយពេលមូលហេតុនោះបានរលត់ហើយ ចំពោះជនដែលនៅបរទេសវិញ អំឡុងពេលនោះមានចំនួន ២ (ពីរ) ខែ។

២- អំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំអាចពន្យារបានឡើយ ។

## មាត្រា ៤២.- នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់

ក្រៅពីបញ្ញត្តិនៃជំពូកទី ៥ (ការវិនិច្ឆ័យ) នៃច្បាប់នេះ បញ្ញត្តិនៃជំពូកទី ៤ (បណ្តឹងជំទាស់) គន្តីទី ៣ (បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងជំទាស់ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងជំពូកទី ៧ នេះ ។

# ជំពូកទី ៨
# ការចាត់ចែងរក្សាការពារ

## មាត្រា ៤៣.- នីតិវិធីនៃការចាត់ចែងរក្សាការពារ

១-ក្នុងករណីមានពាក្យសុំអំពីរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ តុលាការអាចបង្គាប់ឲ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឬ ការចាត់ចែងរក្សាការពារចាំបាច់ផ្សេងទៀត ដោយដីកាសម្រេចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគ ដោយយោងតាមបញ្ញត្តិនៃច្បាប់នេះ ។

២- តុលាការត្រូវបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង ។

៣-ក្នុងករណីបានដាក់ពាក្យសុំឲ្យចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់នូវការចាត់ចែងរក្សាការពារដែលខ្លួនទាមទារ និង មូលហេតុនៃការទាមទារការចាត់ចែងរក្សាការពារនោះ ។

៤- អ្នកដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការទាមទារការចាត់ចែងរក្សាការពារ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៧ (ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ) នៃច្បាប់នេះ ក៏ដោយ ។

៥- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុ និង ពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ។

៦- ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវជូនដំណឹងទៅអ្នកទទួលដីកាសម្រេចនោះ ។ ដីកាសម្រេចអំពីការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានអានុភាពភ្លាមដោយការជូនដំណឹង ។

៧- អានុភាព និងការអនុវត្តនៃការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវអនុលោមតាមបញ្ញត្តិស្តីពីអានុភាព និង ការអនុវត្តនូវការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្ន នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

៨- បញ្ញត្តិនៃមាត្រា ៥៤៥ (ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៦ (កម្មវត្ថុនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៧ (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន) មាត្រា ៥៤៨ (ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ជាអាទិ៍) និង មាត្រា ៥៤៩ (វិធីចាត់ចែងជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ៤៤.- បណ្តឹងឧបាស្រ័យ**

១- ជនដែលបានដាក់ពាក្យសុំឲ្យចាត់ចែងរក្សាការពារ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ ( នីតិវិធីនៃការចាត់ចែងរក្សាការពារ ) ខាងលើនេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំនោះបាន ។

២- ជនដែលអាចប្តឹងជំទាស់ ចំពោះដីកាសម្រេចទទួលស្គាល់ពាក្យសុំអំពីអង្គសេចក្តី អាចប្តឹងជំទាស់ចំពោះការចាត់ចែងរក្សាការពារដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) ខាងលើនេះបាន ។

៣- ក្នុងករណីដែលបណ្តឹងជំទាស់ត្រូវបានធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ប្រសិនបើមានសេចក្តីបញ្ជាក់ជំបូងអំពីស្ថានភាពដែលច្បាស់ថា នឹងក្លាយជាមូលហេតុនៃការលុបចោលការចាត់ចែងរក្សាការពារ និងអំពីការណ៍ដែលមានការបារម្ភថា ការខូចខាតដែលមានការពិបាកនឹងធ្វើបដិទានឡើងវិញ នឹងកើតឡើងដោយសារការអនុវត្តការចាត់ចែងរក្សាការពារនោះ តុលាការនៃបណ្តឹងជំទាស់ អាចបង្គាប់ឲ្យធ្វើការចាត់ចែងដូចខាងក្រោមនេះ តាមពាក្យសុំ ៖

ក- ផ្អាកការអនុវត្តការចាត់ចែងរក្សាការពារ ដោយឲ្យដាក់ប្រាតិភោគ ឬ មិនឲ្យដាក់ប្រាតិភោគរហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងជំទាស់នោះបង្កើតអានុភាព ។

ខ- លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ ដោយឲ្យដាក់ប្រាតិភោគរហូតដល់ពេលដែលដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ បង្កើតអានុភាព ។

៤- ក្នុងអំឡុងពេលដែលសំណុំរឿងក្តី នៅតែមាននៅតុលាការដើម តុលាការដើមនោះក៏អាចបង្គាប់ឲ្យធ្វើការចាត់ចែងដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះបានដែរ ។

៥- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងមាត្រានេះ ។ បញ្ញត្តិនៃកថាខណ្ឌទី ៤ និង ទី ៥ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសេចក្តីបញ្ជាក់ជំបូងដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ហើយបញ្ញត្តិនៃមាត្រា ៧១ (វិធីដាក់ប្រាតិភោគ និង ការប្តូរប្រាតិភោគ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាតិភោគដែលកំណត់ក្នុងកថាខណ្ឌទី ៣ នោះ ។

៦- បញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចបង្គាប់ឲ្យធ្វើបដិទាន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចលុបចោលនូវដីកាសម្រេចចាត់ចែងរក្សាការពារដែល

កំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) ខាងលើនេះ ដោយផ្អែកលើបណ្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ។

## មាត្រា ៤៥.- ការលុបចោលការចាត់ចែងរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព

១- នៅក្រោយពេលដែលការចាត់ចែងរក្សាការពារ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) នៃច្បាប់នេះ បានចូលជាស្ថាពរ ប្រសិនបើមានការរលត់មូលហេតុនៃការចាត់ចែងរក្សាការពារនោះ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការអាចលុបចោលការចាត់ចែងរក្សាការពារនោះ តាមពាក្យសុំរបស់ជនដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤៤ (បណ្តឹងឧបាស្រ័យ) ខាងលើនេះ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៦ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះពាក្យសុំ និង ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ជនដែលបានដាក់ពាក្យសុំឲ្យធ្វើការចាត់ចែងរក្សាការពារ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលុបចោលការចាត់ចែងរក្សាការពារ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ។

៤- ជនដែលបានដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំនោះបាន ។ បញ្ញត្តិពីកថាខណ្ឌទី ៣ ដល់កថាខណ្ឌទី ៥ នៃមាត្រា ៤៤ (បណ្តឹងឧបាស្រ័យ) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីនេះ ។

៥- បញ្ញត្តិនៃមាត្រា ៥៥៥ (ដីកាសម្រេចឲ្យធ្វើបដិទាន) និង មាត្រា ៥៥៦ (អានុភាពនៃដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចលុបចោលការចាត់ចែងរក្សាការពារ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

## មាត្រា ៤៦.- ការគ្រប់គ្រង ការចាត់ចែងរក្សាការពារទ្រព្យសម្បត្តិ និង ការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការមើលថែរក្សាក្នុងករណីមានពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១- ក្នុងករណីមានពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅដែលកំណត់ក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន ឬ មើលថែរក្សាសាមីខ្លួន តុលាការអាចជ្រើសតាំង

ROYAUME DU CAMBODGE REGISTRE DU PALAIS ROYAL



Kol

អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ អាចកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន ឬ ការបើបាច់ក្សាសាមីខ្លួននោះ ចំពោះជនពាក់ព័ន្ធនឹងរឿងក្តីបានរហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅនោះ បង្កើតអានុភាពតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ដោយមិនឲ្យដាក់ប្រាតិភោគ ។

២- បញ្ញត្តិពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) ដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ក្នុងករណីមានពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ប្រសិនបើមានការចាំបាច់ពិសេសដើម្បីរក្សាការពារទ្រព្យសម្បត្តិរបស់សាមីខ្លួន តុលាការអាចបង្គាប់ឲ្យសាមីខ្លួនស្ថិតនៅក្រោមអាណាព្យាបាលរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ដែលត្រូវបានជ្រើសតាំងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់សាមីខ្លួននោះ លើកលែងតែសកម្មភាពដែលកំណត់ក្នុងវាក្យខណ្ឌទី ២ មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ បង្កើតអានុភាពតាមពាក្យសុំរបស់អ្នកដែលដាក់ពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅនោះ ។

៤- ដីកាសម្រេចដែលធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជូនដំណឹងទៅអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

៥- ប្រសិនបើដីកាសម្រេចត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ តុលាការត្រូវជូនដំណឹងអំពីការណ៍នោះ ទៅសាមីខ្លួនដោយគ្មានការយឺតយ៉ាវ ។

៦- អំឡុងពេលសម្រាប់ប្តឹងជំទាស់ ចំពោះដីកាសម្រេចដែលធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគិតពីថ្ងៃដែលមានការជូនដំណឹងទៅអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ ។ ក្នុងករណីនេះ ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិមានច្រើននាក់ ហើយអ្នកទាំងនោះបានទទួលការជូនដំណឹងនៅកាលបរិច្ឆេទខុសគ្នានោះ អំឡុងពេលសម្រាប់ប្តឹងជំទាស់ ត្រូវគិតពីថ្ងៃដែលមានការជូនដំណឹងចុងក្រោយ ។

៧- ប្រសិនបើដីកាសម្រេចត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ សាមីខ្លួន និង អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ អាចលុបចោលនូវសកម្មភាពរបស់សាមីខ្លួនដែលទាក់ទងនឹងទ្រព្យសម្បត្តិ លើកលែងតែសកម្មភាពដែលកំណត់ក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ២៦ (សិទ្ធិលុប

ROYAUME DU CAMBODGE • SECRETARIAT ROYAL • PALAIS ROYAL

បោលសកម្មភាព ) នៃក្រមរដ្ឋប្បវេណី ។ បញ្ញត្តិស្តីពីការលុបចោលនូវសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

## មាត្រា ៤៧.- ការគ្រប់គ្រង ការចាត់ចែងរក្សាការពារនូវទ្រព្យសម្បត្តិ និង ការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការបីបាច់រក្សា ក្នុងករណីមានពាក្យសុំឱ្យប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ

១- ក្នុងករណីដែលមានពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ ដែលកំណត់ក្នុងមាត្រា ២៨ ( ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិសាមីខ្លួន ឬ បីបាច់រក្សាសាមីខ្លួន តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ អាចកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន ឬ ការបីបាច់រក្សាសាមីខ្លួននោះ ចំពោះជនពាក់ព័ន្ធនឹងរឿងក្តីបានរហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំឲ្យប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភនោះបង្កើតអានុភាពតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ដោយមិនឲ្យដាក់ប្រាតិភោគ។

២- បញ្ញត្តិពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) ដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានជ្រើសតាំងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣- ក្នុងករណីមានពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ ប្រសិនបើមានការចាំបាច់ពិសេស ដើម្បីរក្សាការពារទ្រព្យសម្បត្តិរបស់សាមីខ្លួន តុលាការអាចបង្គាប់ឲ្យសាមីខ្លួនស្ថិតនៅក្រោមហិតូបត្ថម្ភរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលត្រូវបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបាន ចំពោះសកម្មភាពដែលកំណត់ក្នុងមាត្រា ៣០ ( សិទ្ធិលុបចោលសកម្មភាព ) នៃក្រមរដ្ឋប្បវេណី ក្នុងចំណោមសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់សាមីខ្លួននោះ រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ បង្កើតអានុភាពតាមពាក្យសុំរបស់អ្នកដែលដាក់ពាក្យសុំនោះ ។

៤- ដីកាសម្រេចដែលធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជូនដំណឹងទៅអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

៥- អំឡុងពេលសម្រាប់ប្ដឹងជំទាស់ ចំពោះដីកាសម្រេចដែលធ្វើឡើងដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគិតពីថ្ងៃចុងក្រោយក្នុងចំណោមថ្ងៃដែលមានការជូនដំណឹងដោយ

យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ នៃមាត្រា ៤៣ (នីតិវិធីនៃការចាត់ចែងរក្សាការពារ) នៃច្បាប់នេះ និងថ្ងៃដែលមានការជូនដំណឹង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ នៃមាត្រានេះ ។

៦- ប្រសិនបើដីកាសម្រេចត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ សាមីខ្លួននិងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ អាចលុបចោលបាននូវសកម្មភាពដែលកំណត់ក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី ក្នុងចំណោមសកម្មភាពទាក់ទងនឹងទ្រព្យសម្បត្តិ ដែលសាមីខ្លួនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិស្តីពីការលុបចោលនូវសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

## មាត្រា ៤៨.- ការព្យួរអំណាចមេបា ជាអាទិ៍ មុនពេលដែលដីកាសម្រេចឲ្យបង្កើតសុំកូនពេញលេញ បង្កើតអានុភាព

១-ក្នុងករណីដែលមានពាក្យសុំឲ្យចេញដីកាសម្រេចបង្កើតសុំកូនពេញលេញដែលកំណត់ក្នុងមាត្រា ១០០៧ (ទម្រង់នៃការបង្កើតសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីផលប្រយោជន៍របស់ជនដែលនឹងក្លាយជាកូនសុំ តុលាការអាចព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់ជនដែលនឹងក្លាយជាកូនសុំនោះបាន តាមពាក្យសុំរបស់អ្នកដែលដាក់ពាក្យសុំបង្កើតសុំកូននោះ រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យបង្កើតសុំកូនពេញលេញនោះបង្កើតអានុភាព ។ ក្នុងករណីនេះ ប្រសិនបើគ្មានអ្នកផ្សេងទៀតដែលមានអំណាចមេបា ឬ ដែលអនុវត្តកិច្ចការរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវជ្រើសតាំងអ្នកដែលអនុវត្តកិច្ចការនោះជំនួស ។

២- តុលាការអាចផ្លាស់ប្តូរអ្នកដែលអនុវត្តកិច្ចការជំនួស ដែលខ្លួនបានជ្រើសតាំងនោះពេលណាក៏បានដែរ ។

## មាត្រា ៤៩.- ការព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបា និង ការជ្រើសតាំងអ្នកធ្វើកិច្ចការជំនួស

១- ក្នុងករណីមានពាក្យសុំឲ្យប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបាដែលកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា) នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបាបាន តាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំនោះ រហូតដល់ពេលដែលដីកាសម្រេចអំពីពាក្យសុំឲ្យ

ប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា បង្កើតអានុភាព ។ ក្នុងករណីនេះ ប្រសិនបើគ្មានអ្នកដែលមានអំណាចមេបាផ្សេងទៀតទេ តុលាការត្រូវជ្រើសតាំងអ្នកដែលអនុវត្តកិច្ចការនោះជំនួស ។

២- តុលាការអាចផ្លាស់ប្តូរអ្នកដែលអនុវត្តកិច្ចការជំនួសដែលខ្លួនបានជ្រើសតាំងនោះ នៅពេលណាក៏បានដែរ ។

## ជំពូកទី ៩
## បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីផ្សេងៗ
## ផ្នែកទី ១
## រឿងក្តីអាណាព្យាបាល និង ហិតូបត្ថម្ភ ជាអាទិ៍

### មាត្រា ៥០.- ការពិនិត្យដោយវេជ្ជបណ្ឌិត ជាអាទិ៍ ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍

ដើម្បីចេញដីកាសម្រេចប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៤ (ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) ឬ ដីកាសម្រេចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨ (ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមរដ្ឋប្បវេណី តុលាការត្រូវស្តាប់មតិយោបល់ជំនាញរបស់វេជ្ជបណ្ឌិត ឬ ជនផ្សេងទៀតដែលអាចទទួលស្គាល់ថាសមរម្យអំពីស្ថានភាពស្មារតីរបស់សាមីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយល់ឃើញច្បាស់លាស់ថាមិនចាំបាច់ ។

### មាត្រា ៥១.- ការសួរសេចក្តីថ្លែងការណ៍របស់សាមីខ្លួន ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍

ដើម្បីចេញដីកាសម្រេចដែលកំណត់ក្នុងមាត្រា ៥០ (ការពិនិត្យដោយវេជ្ជបណ្ឌិត ជាអាទិ៍ ក្នុងករណីចាប់ផ្តើមអាណាព្យាបាលទូទៅ ជាអាទិ៍) ខាងលើនេះ តុលាការត្រូវផ្តល់ឱកាសឲ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ។

### មាត្រា ៥២.- ការគិតពិចារណាអំពីយោបល់របស់កូន

នៅពេលដែលចេញដីកាសម្រេចកំណត់អំពីអ្នកមានអំណាចមេបាលើកូន ឬ ការចាត់ចែងចាំបាច់ដែលទាក់ទងនឹងការបីបាច់រក្សាកូន យោបល់របស់កូនត្រូវបានយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ ។

**មាត្រា ៥៣.- ការគិតពិចារណាអំពីយោបល់របស់សាមីខ្លួន ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន**

បញ្ញត្តិនៃមាត្រា ៥២ (ការគិតពិចារណាអំពីយោបល់របស់កូន) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចអំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលកំណត់ក្នុងមាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) នៃក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២
## រឿងក្តីបាត់ខ្លួន

**មាត្រា ៥៤.- ការដាស់តឿនជាសាធារណៈ**

១- ការដាស់តឿនជាសាធារណៈដែលកំណត់ក្នុងមាត្រា ៤២ (ការដាស់តឿនជាសាធារណៈ) នៃក្រមរដ្ឋប្បវេណី ត្រូវធ្វើឡើងតាមវិធីផ្សាយជាសាធារណៈ ។

២- ការផ្សាយជាសាធារណៈ ត្រូវធ្វើដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ និងចុះផ្សាយនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ ។

៣- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើការផ្សាយជាសាធារណៈតាមការចុះផ្សាយនៅក្នុងសារព័ត៌មានប្រចាំថ្ងៃ ឬ តាមវិធីផ្សេងទៀតដែលយល់ឃើញថាសមរម្យបាន ដោយបន្ថែមលើវិធីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

៤- ការផ្សាយជាសាធារណៈដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបញ្ជាក់អំពីចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ។

ខ- ឈ្មោះ និង អាសយដ្ឋានចុងក្រោយដែលត្រូវបានដឹង និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកអវត្តមាន ។

គ- កំណត់ថា អ្នកអវត្តមានត្រូវផ្តល់ព័ត៌មានអំពីការរស់នៅរបស់ខ្លួននៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ហើយបើមិនបានផ្តល់ព័ត៌មានមុនអំឡុងពេលនេះទេ អ្នកអវត្តមាននោះនឹងទទួលការប្រកាសអំពីការបាត់ខ្លួន ។

ឃ- កំណត់ថា ជនដែលដឹងអំពីការនៅរស់ ឬ មរណភាពរបស់អ្នកអវត្តមាន ត្រូវផ្តល់ព័ត៌មាន នៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ។



Kol

ង- ថ្ងៃចប់អំឡុងពេលនៃការដាក់តឿនជាសាធារណៈ ។

៥- អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ត្រូវមានមិនតិចជាង ៦ (ប្រាំមួយ) ខែ ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) នៃក្រមរដ្ឋប្បវេណី ហើយមិនតិចជាង ២ (ពីរ) ខែ ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រាដដែល ។

**មាត្រា ៥៥.- ការផ្សាយជាសាធារណៈ និងការជូនដំណឹងអំពីការចូលជាស្ថាពរនៃដីកាសម្រេច**

១- ប្រសិនបើដីកាសម្រេចប្រកាសអំពីការបាត់ខ្លួនចូលជាស្ថាពរ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈអំពីការណ៍នោះ និង ត្រូវជូនដំណឹងអំពីការណ៍នោះ ទៅបុគ្គលដែលទទួលបន្ទុកការងារអគ្រានុកូលដ្ឋានរបស់ជនដែលទទួលការប្រកាសអំពីការបាត់ខ្លួននោះ ដោយគ្មានការយឺតយ៉ាវ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដីកាសម្រេចលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ចូលជាស្ថាពរ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៥៦.- កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ**

ច្បាប់នេះ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព.រ.ល.០៧១០.៥៨៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្ស វឌ្ឍនា

លេខ: ៥៤៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

25/12

## មាតិកា


**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ........ ១

**មាត្រា ១.-** គោលដៅនៃច្បាប់នេះ ........ ១

**មាត្រា ២.-** គោលបំណងនៃច្បាប់នេះ ........ ១

**មាត្រា ៣.-** វិសាលភាពនៃច្បាប់នេះ ........ ១

**ជំពូកទី ២ តុលាការ** ........ ១

**ផ្នែកទី ១ សមត្ថកិច្ចសាលាជម្រះក្តី** ........ ១

**មាត្រា ៤.-** តុលាការដែលមានសមត្ថកិច្ច ........ ១

**មាត្រា ៥.-** ការកំណត់តុលាការដែលមានសមត្ថកិច្ច ........ ២

**មាត្រា ៦.-** ការបាត់បែងរឿងក្តីខុសសមត្ថកិច្ច ........ ២

**មាត្រា ៧.-** សមត្ថកិច្ចជាអាទិភាព និងការផ្ទេរ ........ ២

**មាត្រា ៨.-** ការពិនិត្យកស្តុតាងដោយឆន្ទានុសិទ្ធិ ........ ៣

**មាត្រា ៩.-** បណ្តឹងជំទាស់ ........ ៣

**មាត្រា ១០.-** អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍ ........ ៣

**ផ្នែកទី ២ រចនាសម្ព័ន្ធនៃតុលាការ** ........ ៣

**មាត្រា ១១.-** ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ........ ៣

**មាត្រា ១២.-** ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ ........ ៤

**មាត្រា ១៣.-** ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ ........ ៤

**ផ្នែកទី ៣ ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ចិត្ត និងការដកខ្លួន** ........ ៤

**មាត្រា ១៤.-** ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ចិត្ត និងការដកខ្លួនរបស់ចៅក្រម ជាអាទិ៍ ........ ៤

**ជំពូកទី ៣ ជនពាក់ព័ន្ធ** ........ ៥

**មាត្រា ១៥.-** ជនពាក់ព័ន្ធ ........ ៥

**មាត្រា ១៦.-** សមត្ថភាពរបស់ជនពាក់ព័ន្ធ ........ ៥

**មាត្រា ១៧.-** សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ........ ៥

**មាត្រា ១៨.-** សកម្មភាពនៃនីតិវិធីដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ ........ ៦


ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Kol

**មាត្រា ១៩.–** លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ ...... ៦

**មាត្រា ២០.–** ការបញ្ជាក់នូវសិទ្ធិតំណាងដោយអាណត្តិ ...... ៦

**មាត្រា ២១.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ...... ៧

**ជំពូកទី ៤ ប្រាក់ប្រដាប់ក្តី** ...... ៧

**មាត្រា ២២.–** បន្ទុកនៃប្រាក់ប្រដាប់ក្តី ...... ៧

**មាត្រា ២៣.–** ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ...... ៨

**មាត្រា ២៤.–** ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី ...... ៨

**មាត្រា ២៥.–** ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន ...... ៩

**ជំពូកទី ៥ ការវិនិច្ឆ័យ** ...... ៩

**មាត្រា ២៦.–** របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ ...... ៩

**មាត្រា ២៧.–** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និងការពិនិត្យកស្តុតាងដោយឆន្ទានុសិទ្ធិ ...... ១០

**មាត្រា ២៨.–** ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ ...... ១០

**មាត្រា ២៩.–**ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន ...... ១០

**មាត្រា ៣០.–** ការចូលរួមរបស់តំណាងអយ្យការ និងការជូនដំណឹង ...... ១០

**មាត្រា ៣១.–** ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍ ...... ១១

**មាត្រា ៣២.–** ការទទួលបន្តនូវនីតិវិធី ...... ១១

**មាត្រា ៣៣.–** ការមើលសំណុំរឿង ជាអាទិ៍ ...... ១១

**មាត្រា ៣៤.–** ការអនុវត្តដូចគ្នាតាមក្រមនីតិវិធីរដ្ឋប្បវេណី ...... ១២

**ជំពូកទី ៦ ការសម្រេចសេចក្តី** ...... ១២

**មាត្រា ៣៥.–** វិធីសម្រេចសេចក្តី ...... ១២

**មាត្រា ៣៦.–** ការជូនដំណឹងអំពីដីកាសម្រេច ...... ១២

**មាត្រា ៣៧.–** ការចូលជាស្ថាពរ និងការបង្កើតអានុភាពនៃដីកាសម្រេច ...... ១៣

**មាត្រា ៣៨.–** អានុភាពអនុវត្តនៃដីកាសម្រេច ...... ១៣

**ជំពូកទី ៧ បណ្តឹងឧបាស្រ័យ** ...... ១៣

**មាត្រា ៣៩.–** បណ្តឹងជំទាស់ ...... ១៣

**មាត្រា ៤០.–** អំឡុងពេលសម្រាប់ប្តឹងជំទាស់ ...... ១៣

**មាត្រា ៤១.–** ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត ...... ១៤


ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៤២.-** នីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងជំទាស់ ........ ១៤
**ជំពូកទី ៨ ការចាត់ចែងរក្សាការពារ** ........ ១៤
**មាត្រា ៤៣.-** នីតិវិធីនៃការចាត់ចែងរក្សាការពារ ........ ១៤
**មាត្រា ៤៤.-** បណ្ដឹងឧបាស្រ័យ ........ ១៦
**មាត្រា ៤៥.-** ការលុបចោលការចាត់ចែងរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព ........ ១៧
**មាត្រា ៤៦.-** ការគ្រប់គ្រង ការចាត់ចែងរក្សាការពារនូវទ្រព្យសម្បត្តិ និងការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការបីបាច់រក្សាក្នុងករណីមានពាក្យសុំឲ្យប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ ........ ១៧
**មាត្រា ៤៧.-** ការគ្រប់គ្រង ការចាត់ចែងរក្សាការពារនូវទ្រព្យសម្បត្តិ និងការកំណត់ចំណុចត្រូវធ្វើដែលទាក់ទងនឹងការបីបាច់រក្សា ក្នុងករណីមានពាក្យសុំឲ្យប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ ........ ១៩
**មាត្រា ៤៨.-** ការព្យួរអំណាចមេបា ជាអាទិ៍ មុនពេលដែលដីកាសម្រេចឲ្យបង្កើតសុំកូនពេញលេញ បង្កើតអានុភាព ........ ២០
**មាត្រា ៤៩.-** ការព្យួរការអនុវត្តកិច្ចការរបស់អ្នកមានអំណាចមេបា និងការជ្រើសតាំងអ្នកធ្វើកិច្ចការជំនួស ........ ២០
**ជំពូកទី ៩ បទប្បញ្ញត្តិពិសេសស្ដីពីរឿងក្ដីផ្សេងៗ** ........ ២១
**ផ្នែកទី ១ រឿងក្ដីអាណាព្យាបាល និងហិតូបត្ថម្ភ ជាអាទិ៍** ........ ២១
**មាត្រា ៥០.-** ការពិនិត្យដោយវេជ្ជបណ្ឌិត ជាអាទិ៍ ក្នុងករណីចាប់ផ្ដើមអាណាព្យាបាលទូទៅ ជាអាទិ៍ ........ ២១
**មាត្រា ៥១.-** ការសួរសេចក្ដីថ្លែងការណ៍របស់សាមីខ្លួន ក្នុងករណីចាប់ផ្ដើមអាណាព្យាបាលទូទៅ ជាអាទិ៍ ........ ២១
**មាត្រា ៥២.-** ការគិតពិចារណាអំពីយោបល់របស់កូន ........ ២១
**មាត្រា ៥៣.-** ការគិតពិចារណាអំពីយោបល់របស់សាមីខ្លួន ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ........ ២២
**ផ្នែកទី ២ រឿងក្ដីបាត់ខ្លួន** ........ ២២
**មាត្រា ៥៤.-** ការដាស់តឿនជាសាធារណៈ ........ ២២
**មាត្រា ៥៥.-** ការផ្សាយជាសាធារណៈ និងការជូនដំណឹងអំពីការចូលជាស្ថាពរនៃដីកាសម្រេច ........ ២៣
**ជំពូកទី ១០ អវសានប្បញ្ញត្តិ** ........ ២៣
**មាត្រា ៥៦.-** កាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ ........ ២៣

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

Kol

**តារាងឧបសម្ព័ន្ធ**

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ១ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី២ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការប្រកាសអត្ថធីនភាពចំពោះអនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា២១ (ល័ក្ខខ័ណ្ឌនៃអត្ថធីនភាព) | តុលាការនៃលំនៅឋានរបស់អនីតិជន |
| | ២ ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ និងការលុបចោលនូវការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់ជនដែលត្រូវបានដាក់ពាក្យសុំឱ្យចាប់ផ្តើមអាណាព្យាបាលទូទៅ |
| | ៣ ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅដោយយោងតាមបញ្ញត្តិនៃមាត្រា២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ |
| | ៤ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ និងការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) | តុលាការនៃលំនៅឋានរបស់ជនដែលត្រូវបានដាក់ពាក្យសុំឱ្យចាប់ផ្តើមហិតូបត្ថម្ភ |
| | ៥ ការចាត់ចែងទាក់ទងនឹងហិតូបត្ថម្ភ ដែលបានកំណត់នៅក្នុងចំណុច៣ មាត្រា៣០ (សិទ្ធិលុបចោលសកម្មភាព) | តុលាការនៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ |
| | ៦ ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ដោយយោងតាមបញ្ញត្តិនៃមាត្រា៣១ (ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ) | តុលាការនៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ |
| | ៧ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ដោយយោងតាមបញ្ញត្តិនៃមាត្រា៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) | តុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន |
| | ៨ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ដោយយោងតាមបញ្ញត្តិពីមាត្រា៣៨ (ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) ដល់មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការដែលចេញដីកាសម្រេចដោយផ្អែកលើមាត្រា៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) |
| | ៩ ការប្រកាសអំពីការបាត់ខ្លួន ដោយយោងតាមបញ្ញត្តិនៃមាត្រា៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) | តុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន |
| | ១០ ការលុបចោលការប្រកាសអំពីការបាត់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា៤៤ (ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រលប់មកវិញ) | តុលាការដែលប្រកាសអំពីការបាត់ខ្លួនដោយផ្អែកលើមាត្រា៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសការបាត់ខ្លួន) |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

Ksl

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ១ | ១១ ការជ្រើសតាំងអភិបាលបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃមាត្រា៦០ (អភិបាលបណ្តោះអាសន្ន) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១២ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា៦១ (អ្នកតំណាងពិសេស) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៣ ការបង្គាប់ឱ្យរំលាយនីតិបុគ្គល ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៦៥ (បណ្តឹងទាមទារការរំលាយ) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៤ ការជ្រើសតាំងអ្នកជម្រះបញ្ជី ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា៦៨ (ការកាន់តំណែងនៃអ្នកជម្រះបញ្ជី) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៥ ការដកហូតតំណែងរបស់អ្នកជម្រះបញ្ជី ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា៦៩ (ការដកហូតតំណែងរបស់អ្នកជម្រះបញ្ជី) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៦ ការអនុញ្ញាតឱ្យសង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៧៤ (ការសងក្នុងអំឡុងពេលដើម្បីបង្ហាញសិទ្ធិលើបំណុល) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៧ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៧៦ (ការសងសិទ្ធិលើបំណុល) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៨ ការជ្រើសតាំងអ្នករក្សាទុក ដោយយោងតាមបញ្ញត្តិនៃមាត្រា៨១ (ការរក្សាទុកឯកសារ) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ១៩ ការជ្រើសតាំងអធិការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ២០ ការជំនុំជម្រះឱ្យផ្លាស់ប្តូរ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ២១ ការអនុញ្ញាតឱ្យកោះប្រជុំមហាសន្និបាត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៩៣ (មហាសន្និបាតសាមញ្ញ) | តុលាការនៃលំនៅឋានរបស់នីតិបុគ្គល |
| | ២២ ការបំពេញបង្គ្រប់លក្ខន្តិកៈរបស់នីតិបុគ្គលមូលនិធិ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២ (ការបំពេញបង្គ្រប់លក្ខន្តិកៈ) | តុលាការនៃលំនៅឋានរបស់អ្នកបង្កើតនីតិបុគ្គលពេលទទួលមរណភាព |

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *

Ksl

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ២ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៣ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃមាត្រា១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) | តុលាការដែលបានកំណត់នៅក្នុងមាត្រា ១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) |
| ៣ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៤ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការអនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤២៣ (ល័ក្ខខ័ណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទេសកម្ម) | តុលាការនៃលំនៅឋានរបស់កូនបំណុល |
| | ២ ការអនុញ្ញាតឱ្យលក់ដេញថ្លៃនូវវត្ថុដែលជាកម្មវត្ថុនៃការសង ដោយយោងតាមបញ្ញត្តិនៃមាត្រា៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) | តុលាការនៃកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច |
| ៤ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៧ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការសម្រេចសេចក្តីជំនួសការយល់ព្រមចំពោះអាពាហ៍ពិពាហ៍របស់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៩៥៣ (ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជន |
| | ២ ការចាត់ចែងទាក់ទងនឹងចំណែកបន្ទុកនៃសោហ៊ុយដែលកើតឡើងពីអាពាហ៍ពិពាហ៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧១ (ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍) | តុលាការនៃលំនៅឋានរបស់ភាគីម្ខាងទៀត |
| | ៣ ការសម្រេចសេចក្តីអំពីការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា៩៧៤ (ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៤ ការអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៥ ពាក្យសុំលែងលះដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧៩ (ការលែងលះដោយការព្រមព្រៀង) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៦ ការបែងចែកទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្តី ឬប្រពន្ធ |
| | ៧ ពាក្យសុំឱ្យបង្កើតសុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០០៧ (ទម្រង់នៃការបង្កើតសុំកូនពេញលេញ) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៨ ការទាមទារឱ្យបង្ហាញនូវសំណុំរឿងអំពីសុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០១៩ (សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ) | តុលាការដែលរក្សាទុកនូវសំណុំរឿងអំពីសុំកូនពេញលេញ |
| | ៩ ពាក្យសុំឱ្យបង្កើតសុំកូនធម្មតា ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាកូនសុំ |
| | ១០ ពាក្យសុំឱ្យកាត់កាល់សុំកូនដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១១ ការកំណត់អ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និងអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១២ ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៣៩ (ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១៣ ការសម្រេចសេចក្តីអំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទង និងចំណែកបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ និងកថាខណ្ឌទី៥ មាត្រា១០៤០ (សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន) | តុលាការនៃលំនៅឋានរបស់កូន |
| | ១៤ ការសម្រេចសេចក្តីជំនួសការពិភាក្សា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៤១ (សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ១៥ ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៤៨ (ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ១៦ ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៤៩ (ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដែលបានទទួលការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា |
| | ១៧ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា |
| | ១៨ ការអនុញ្ញាតឱ្យទទួលបដិទាននូវអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យទទួលបដិទាននូវអំណាចមេបា |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ១៩ ការប្រកាសការផ្លាស់ប្តូរអ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៥១ (ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ២០ ការជ្រើសតាំង និងការផ្លាស់ប្តូរអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) | តុលាការនៃលំនៅឋានរបស់កូន |
| | ២១ ការចាត់ចែងទាក់ទងនឹងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិជាអាទិ៍) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៤ មាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) | តុលាការដែលចេញដីកាសម្រេច ដោយផ្អែកលើកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ មាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) |
| | ២២ ការព្យួរ ឬការដកហូតសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦១ (ការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ២៣ ការលុបចោលការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦២ (ការលុបចោលការប្រកាសការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកដែលបានទទួលការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ |
| | ២៤ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ |
| | ២៥ ការអនុញ្ញាតឱ្យទទួលបដិទាននូវសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យទទួលបដិទាននូវសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិ |
| | ២៦ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) | តុលាការនៃលំនៅឋានរបស់កូន |
| | ២៧ ការចាត់ចែងទាក់ទងនឹងអ្នកជំនួសអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ នៃមាត្រា១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និងអំណាចមេបា) មាត្រា១០៣៩ (ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) កថាខណ្ឌទី៤ និងកថាខណ្ឌទី៥ នៃមាត្រា១០៤០ (សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិន | តុលាការដែលមានសមត្ថកិច្ចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ ចាប់ពីចំណុច១១ ដល់ចំណុច២៦ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | រស់នៅជាមួយកូន) កថាខណ្ឌទី២ នៃមាត្រា១០៤១ (សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន) មាត្រា១០៤៨ (ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) មាត្រា១០៤៩ (ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) កថាខណ្ឌទី១ នៃមាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) កថាខណ្ឌទី២ នៃមាត្រា១០៥១ (ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) កថាខណ្ឌទី៤ នៃមាត្រា១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន) មាត្រា១០៦១ (ការប្រកាសការព្យួរ ឬការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) មាត្រា១០៦២ (ការលុបចោលការប្រកាសការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) កថាខណ្ឌទី១ នៃមាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) កថាខណ្ឌទី២ នៃមាត្រា១០៦៣ (ការលាឈប់ និងបដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ឬមាត្រា ១០៦៥ (ករណី ដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា ១០៦៦ (អ្នកជំនួសអំណាចមេបា) | |
| | ២៨ ការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និងមូលដ្ឋាននៃការជ្រើសតាំង) ឬកថាខណ្ឌទី២ មាត្រា១០៧៥ (អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ២៩ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣០ ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិ នៃមាត្រា១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៣១ ការចាត់ចែងទាក់ទងនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៧១ (ការលាឈប់នៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន) មាត្រា១០៧៣ (ការបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ឬមាត្រា១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១០៧៨ (បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣២ ការពន្យារអំឡុងពេលធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភ័ណ្ឌ) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៣ ការអនុញ្ញាតឱ្យចាត់ចែងអចលនវត្ថុដែលប្រើជាលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៨៥ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៤ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៦៥(ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១០៨៦ (សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអនីតិជននៅក្រោមអាណាព្យាបាល មានភាពផ្ទុយគ្នា) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៥ ការផ្តល់កម្រៃចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៦ ការគ្រប់គ្រងថែរក្សាអនីតិជននៅក្រោមអាណាព្យាបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ ឬការចាត់ចែងផ្សេងទៀតដែលទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៨៩ (ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៣៧ ការជ្រើសតាំង និងការផ្លាស់ប្តូរអ្នកអនុវត្តគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៣៨ ការបាត់បែងទាក់ទងនឹងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៨០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិជាអាទិ៍) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៤ មាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) | តុលាការដែលចេញដីកាសម្រេច ដោយផ្អែកលើកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ នៃមាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) |
| | ៣៩ ការបួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៩៥ (ល័ក្ខខ័ណ្ឌនៃការបួចពីអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៤០ ការពន្យាអំឡុងពេលសម្រាប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១០៩៧ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជននៅក្រោមអាណាព្យាបាល |
| | ៤១ ការបាត់បែងទាក់ទងនឹងអាណាព្យាបាលសម្រាប់អនីតិជនដែលអនុវត្តអំណាចមេបាជំនួស ចំពោះកូនរបស់អនីតិជននៅក្រោមអាណាព្យាបាល ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា១០៨១ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភ័ណ្ឌ) មាត្រា១០៨៥ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) មាត្រា១០៨៦ (សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអនីតិជននៅក្រោមអាណាព្យាបាលមានភាពផ្ទុយគ្នា) មាត្រា១០៨៨ (កម្រៃរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី២ នៃមាត្រា១០៨៩ (ការត្រួតពិនិត្យតួនាទីរបស់អាណាព្យាបាលសម្រាប់អនីតិជន) កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) កថាខណ្ឌទី៤ នៃមាត្រា១០៩៤ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអនីតិជននៅក្រោមអាណាព្យាបាល) កថាខណ្ឌទី១ នៃមាត្រា១០៩៥ (ល័ក្ខខ័ណ្ឌនៃការបួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន) ឬវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា១០៩៧ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ វត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន) ដែលត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១១០៣(ការអនុវត្តអំណាចមេបាជំនួសអនីតិជននៅក្រោមអាណាព្យាបាល) | តុលាការដែលមានសមត្ថកិច្ចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ ចាប់ពីចំណុច ៣២ ដល់ចំណុច៤០ |

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៤២ ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ឬអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) ឬមាត្រា១១១០ (អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៣ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៤ ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៥ ការចាត់ចែងពាក់ព័ន្ធនឹងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១២១ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) ឬមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១១១៣ (បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នា) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៦ ការពន្យារអំឡុងពេលសម្រាប់ការធ្វើបញ្ជីសារពើភណ្ឌ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១១១៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភ័ណ្ឌ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៧ ការពន្យារអំឡុងពេលសម្រាប់ការធ្វើបញ្ជីសារពើភណ្ឌ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១១១៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិ និងការធ្វើបញ្ជីសារពើភ័ណ្ឌ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយបញ្ញត្តិនៃមាត្រា១១១៨ (ការយកមកអនុវត្តដូចគ្នា ចំពោះករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិសកល) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៤៨ ការអនុញ្ញាតឱ្យចាត់ចែងអចលនវត្ថុដែលប្រើជាលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២១ (ការអនុញ្ញាតឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៤៩ ការជ្រើសតាំងអ្នកតំណាងពិសេស ដោយយោងតាមបញ្ញត្តិនៃមាត្រា ១០៦៥ (ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និងកូនមានភាពផ្ទុយគ្នា) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយមាត្រា១១២២ (សកម្មភាពដែលផលប្រយោជន៍របស់អ្នកអាណាព្យាបាលទូទៅ និងជននៅក្រោមអាណាព្យាបាលទូទៅមានភាពផ្ទុយគ្នា) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥០ ការផ្តល់កម្រៃចំពោះអ្នកអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥១ ការរាយការណ៍អំពីតួនាទីនៃអាណាព្យាបាលទូទៅ ការដាក់បញ្ជីសារពើភ័ណ្ឌ ការស្រាវជ្រាវអំពីជីវភាព ការថែទាំព្យាបាល ឬស្ថានភាពទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ការចាត់ចែងដែលទាក់ទងនឹងជីវភាព ការថែទាំព្យាបាល ឬការគ្រប់គ្រងទ្រព្យសម្បត្តិ ឬការចាត់ចែងផ្សេងទៀតដែលទាក់ទងនឹងអាណាព្យាបាលទូទៅ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២៥ (ការត្រួតពិនិត្យតួនាទីអ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥២ ការជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យជននៅក្រោមអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |
| | ៥៣ ការចាត់ចែងទាក់ទងនឹងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិជាអាទិ៍) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៤ មាត្រា១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអ្នកនៅក្រោមអាណាព្យាបាលទូទៅ) | តុលាការដែលចេញដីកាសម្រេចដោយផ្អែកលើកថាខណ្ឌទី២ ឬកថាខណ្ឌទី៣ នៃមាត្រា១១៣០ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យអ្នកនៅក្រោមអាណាព្យាបាលទូទៅ) |
| | ៥៤ ការពន្យារអំឡុងពេលសម្រាប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា១១៣១ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងវត្តមានរបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៥៥ ការចាត់ចែងទាក់ទងនឹងហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២និងកថាខណ្ឌទី៣ នៃមាត្រា១១០៥ (ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១១៣៧ (ការជ្រើសតាំងហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់ហិតូបត្ថម្ភកៈ |
| | ៥៦ ការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្តោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ ឬកថាខណ្ឌទី៤ មាត្រា១១៣៧ (ការជ្រើសតាំងហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៥៧ ការជ្រើសតាំងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១១៣៨ (អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៥៨ ការចាត់ចែងទាក់ទងនឹងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១០៦ (ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ) មាត្រា១១០៨ (ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ) ឬមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១១៣៨ (អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៥៩ ការចាត់ចែងទាក់ទងនឹងហិតូបត្ថម្ភកៈ ដោយយោងតាមបញ្ញត្តិនៃមាត្រា១១២៤ (កម្រៃរបស់អ្នកអាណាព្យាបាលទូទៅ) ឬមាត្រា១១២៥ (ការត្រួតពិនិត្យតួនាទីរបស់អ្នកអាណាព្យាបាលទូទៅ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី៣ មាត្រា១១៣៩ (តួនាទីរបស់ហិតូបត្ថម្ភកៈ) | តុលាការនៃលំនៅឋានរបស់អ្នកនៅក្រោមហិតូបត្ថម្ភ |
| | ៦០ ការចាត់ចែងទាក់ទងនឹងអាហារកាតព្វកិច្ច ដោយយោងតាមបញ្ញត្តិពីមាត្រា១១៤០ (ទំហំ និងលំដាប់នៃជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច) ដល់ មាត្រា១១៤៣ (ការផ្លាស់ប្តូរ ឬលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច) | តុលាការនៃលំនៅឋានរបស់ភាគីម្ខាងទៀត |



| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៨ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការកំណត់អ្នកទទួលបន្តនូវសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ មាត្រា១១៤៧ (ការទទួលបន្តនូវមត៌ក) ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី៣ នៃកថាខណ្ឌដដែលនោះ | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២ ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន និងការលុបចោលនូវការផ្តាច់មត៌កនោះ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) មាត្រា១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) និងមាត្រា១១៥៤ (ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន) | តុលាការនៃលំនៅឋានរបស់មតកជន ឬកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៣ ការបញ្ជាក់មតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម ឬលំនៅឋានរបស់ម្ចាស់បណ្តាំ |
| | ៤ ការលុបចោលអច្ច័យទាន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៩៣ (ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៥ ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២១៣ (ការពិនិត្យបញ្ជាក់ និងការបើកលិខិតមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៦ ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២១៨ (ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៧ ការផ្តល់កម្រៃចំពោះអ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិ នៃកថាខណ្ឌទី២ មាត្រា១២២៦ (កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៨ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកប្រតិបត្តិមតកសាសន៍ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា១២២៧ (ការលាឈប់ និងការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៣១ (ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ១០ ការអនុញ្ញាតឱ្យបោះបង់ភាគបម្រុង ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៤៦ (ការបោះបង់ភាគបម្រុង) | តុលាការនៃលំនៅឋានរបស់មតកជន |
| | ១១ ការពន្យារអំឡុងពេលនៃការយល់ព្រម ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី២ កថាខណ្ឌទី១ មាត្រា ១២៥៥ (អំឡុងពេលនៃការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្ដី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ១២ ការទទួលពាក្យសុំលុបចោលការយល់ព្រមដោយមានកម្រិត ឬការបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា ១២៥២(ការលុបចោលការយល់ព្រម ឬការបោះបង់) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៣ ការទទួលពាក្យសុំយល់ព្រមសន្តតិកម្មដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៥៧ (វិធីនៃការយល់ព្រមដោយកម្រិត) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៤ ការទទួលពាក្យសុំបោះបង់សន្តតិកម្ម ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៦០ (ការបោះបង់សន្តតិកម្ម) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៥ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៦ ការចាត់ចែងដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី ៣ មាត្រា ១២៦៤ (អ្នកគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៧ ការបែងចែកមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ១២៧០ (ការបែងចែកដោយតុលាការ) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៨ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ១៩ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា១២៨៦ (ការប្ដូរមត៌កជាប្រាក់) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ២០ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៨៩ (ករណីដែលមានសន្តតិជនច្រើននាក់) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ២១ ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ២២ ការអនុញ្ញាតឱ្យចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩២ (សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |
| | ២៣ ការផ្ដល់កម្រៃចំពោះអ្នកគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា១២៩៣ (កម្រៃសម្រាប់អ្នកគ្រប់គ្រង) | តុលាការនៃកន្លែងចាប់ផ្ដើមសន្តតិកម្ម |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៥ | ២៤ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ឬកថាខណ្ឌទី១ មាត្រា១២៨៦ (ការប្តូរមត៌កជាប្រាក់) ដែលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយកថាខណ្ឌទី២ មាត្រា១២៩៦ (ការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៥ ការចាត់ចែងទាក់ទងនឹងការគ្រប់គ្រងមត៌ក ដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |
| | ២៦ ការចាត់ចែងមត៌ក ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) | តុលាការនៃកន្លែងចាប់ផ្តើមសន្តតិកម្ម |

# ច្បាប់
## ស្ដីពី
## នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល

# ព្រះរាជក្រម

នស/រកម/០៦១០/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ ១៧២០
ថ្ងៃទី២៧/០៧ ឆ្នាំ២០១០ ម៉ោង
បញ្ជូនទៅ

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE ... ROYAL *
ទីស្តីការគណៈរដ្ឋមន្ត្រី

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

ROYAUME DU CAMBODGE

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលដៅនៃច្បាប់នេះ:

ច្បាប់នេះ មានគោលដៅបញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ២.-** គោលបំណងនៃច្បាប់នេះ:

ច្បាប់នេះ មានគោលបំណងធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**មាត្រា ៣.-** វិសាលភាពនៃច្បាប់នេះ:

ច្បាប់នេះ មានវិសាលភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរួមមានបណ្តឹងដូចខាងក្រោមនេះ ៖

ក- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

ខ- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី ។

គ- បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឃ- បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) និងមាត្រា៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ង-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ច- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឆ- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព តាមបញ្ញត្តិនៃមាត្រា ១០០៤ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និង មាត្រា ១០០៥ (បណ្តឹងទាមទារឱ្យបញ្ជាក់

អំពីអត្ថិភាពនៃមាតុភាពពីម្ដាយ) នៃក្រមរដ្ឋប្បវេណី ។

ជ- បណ្ដឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា១០១៦ (ការកាត់កាល់នៃស៊ុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ។

ឈ- បណ្ដឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល់) នៃក្រមរដ្ឋប្បវេណី។

ញ- បណ្ដឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គល។

## ជំពូកទី ២
## ការចូលរួមរបស់តំណាងអយ្យការ

**មាត្រា ៤.-** ការអះអាងអង្គហេតុដោយតំណាងអយ្យការ ជាអាទិ៍

ចំពោះបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលតំណាងអយ្យការបានចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦ (ការចូលរួមរបស់តំណាងអយ្យការ) នៃក្រមនីតិវិធីរដ្ឋប្បវេណី តំណាងអយ្យការនោះ អាចធ្វើការអះអាងអង្គហេតុ ឬ អាចស្នើសុំឱ្យពិនិត្យភស្តុតាងបាន ។

## ជំពូកទី ៣
## តុលាការ

**មាត្រា ៥.-** សមត្ថកិច្ច

១- បណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬ លំនៅឋាននៅពេលដែលភាគីនោះទទួលមរណភាព ។

២- បើលំនៅឋានដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

៣- ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ ។

Kol

**មាត្រា ៦.-** ការផ្ទេរបណ្ដឹងដើម្បីចៀសវាងការយឺតយ៉ាវ

ទោះបីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដើម្បីចៀសវាងការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និង សាក្សីដែលត្រូវសាកសួរ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

## ជំពូកទី ៤
## ភាគី

**មាត្រា ៧.-** ចុងចម្លើយ

១- ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយភាគីម្ខាងនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនោះ ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

២- ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយជនដែលមិនមែនជាភាគីនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនេះ ភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គលនេះ ត្រូវក្លាយជាចុងចម្លើយ ហើយនៅក្រោយពេលដែលភាគីណាមួយបានទទួលមរណភាព ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

៣- ក្នុងករណីដែលជនដែលត្រូវក្លាយជាចុងចម្លើយនៃបណ្ដឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ទទួលមរណភាព ហើយគ្មានជនណាត្រូវក្លាយជាចុងចម្លើយទេនោះ តំណាងអយ្យការត្រូវក្លាយជាចុងចម្លើយ ។

**មាត្រា ៨.-** សមត្ថភាពក្នុងការធ្វើបណ្ដឹង ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍

១- ចំពោះសកម្មភាពបណ្ដឹងក្នុងនីតិវិធីបណ្ដឹងនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃមាត្រា ១៨ (សិទ្ធិលុបចោលសកម្មភាព) មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ៣ នៃមាត្រា ៣២ (សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្ដឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង) និង មាត្រា ៣៣ (បញ្ញត្តិពិសេសស្ដីពីសកម្មភាពបណ្ដឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង មានបំណងធ្វើសកម្មភាពបណ្ដឹងដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចជ្រើសតាំងមេធាវីឱ្យធ្វើជាអ្នកតំណាងតាមពាក្យសុំបាន ។

៣- ទោះបីជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង មិនដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក៏ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចបង្គាប់ឱ្យជ្រើសតាំងមេធាវីជាអ្នកតំណាង ឬ អាចជ្រើសតាំងមេធាវីជាអ្នកតំណាងដោយឆន្ទានុសិទ្ធិបាន ។

៤- ចំនួនទឹកប្រាក់នៃកម្រៃដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង ត្រូវបង់ឱ្យមេធាវីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំងជាអ្នកតំណាង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជាចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ។

៥- ក្នុងចំណោមកម្រៃនិងសោហ៊ុយដែលបានបង់ឱ្យទៅមេធាវី ដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី៣ខាងលើនេះ ឬ បង់ឱ្យទៅមេធាវីដែលជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងបានជ្រើសតាំង ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ត្រូវក្លាយជាប្រាក់ប្រដាប់ក្ដី ។

**មាត្រា ៩.-** សិទ្ធិអំណាចរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍

១- ប្រសិនបើជនដែលត្រូវក្លាយជាដើមចោទ ឬ ចុងចម្លើយនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ជាជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅសម្រាប់ជននោះអាចប្ដឹង ឬ អាចត្រូវបានប្ដឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅនោះបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកអាណាព្យាបាលទូទៅនោះ ជាភាគីម្ខាងទៀតនៃបណ្ដឹងនោះ ។

២- ក្នុងករណីដែលកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅអាចប្ដឹង ឬ អាចត្រូវបានប្ដឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅបាន ។

## ជំពូកទី ៥
## ប្រាក់ប្រដាប់ក្ដី

**មាត្រា ១០.-** ប្រាក់ប្រដាប់ក្ដី

ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្ដីដែលតំណាងអយ្យការ ត្រូវទទួលបន្ទុកដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបន្ទុករបស់រដ្ឋ ។

# ជំពូកទី ៦
# នីតិវិធីនៃបណ្តឹង

**មាត្រា ១១.-** ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាតដែលកើតមានឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារ ពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ អាចធ្វើដោយបណ្តឹងតែមួយបាន ទោះបីមានបញ្ញត្តិមាត្រា ៧៧ ( ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ១២.-** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និង បណ្តឹងតប

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៤ នៃមាត្រា ៨៤ ( ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ) កថាខណ្ឌទី ១ នៃមាត្រា ៨៦ ( បណ្តឹងតប ) និង មាត្រា ២៧៦ ( ការដាក់ពាក្យបណ្តឹងតប ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ នៅក្នុងនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារបាន ហើយចុងចម្លើយអាចប្តឹងតបបានរហូតដល់ពេលចប់ ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី ១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ១៣.-** បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនត្រូវយកមកអនុវត្ត

១- មាត្រា ៩៤ ( ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមស្រប ) កថាខណ្ឌទី ១នៃមាត្រា ៩៦ ( ការចាត់ទុកថាបានសារភាព ) កថាខណ្ឌទី ២ នៃមាត្រា ១៤០ ( ការសាកសួរសាមីភាគី ) មាត្រា ១៥៣ ( អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍ ) កថាខណ្ឌទី ៤ នៃមាត្រា ១៥៦ ( ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ ) មាត្រា ២០០ ( សាលក្រមកំបាំងមុខដើមចោទ ) កថាខណ្ឌទី ២ នៃមាត្រា ២០១ ( សាលក្រមកំបាំងមុខចុងចម្លើយ ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងផ្នែកទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៣ ( គោលការណ៍សម្រេចសេចក្តីដោយកស្តុតាង ) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

២- បញ្ញត្តិពីមាត្រា ២២០ ( ការផ្សះផ្សាលើបណ្តឹង ) ដល់មាត្រា ២២២ ( អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍ ) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះកម្មវត្ថុនៃបណ្តឹង នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

Ksl

**មាត្រា ១៤.-** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។ ក្នុងករណីនេះ តុលាការត្រូវសួរមតិពីភាគីអំពីអង្គហេតុនោះ ។

**មាត្រា ១៥.-** ការបង្គាប់ឱ្យសាមីភាគីមកបង្ហាញខ្លួន ជាអាទិ៍

១- នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលសាកសួរសាមីភាគី តុលាការអាចបង្គាប់ឱ្យភាគីនោះមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីដែលត្រូវបានបង្គាប់ឱ្យមកបង្ហាញខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ។

**មាត្រា១៦.-** ការមិនធ្វើជាសាធារណៈនៃការទាញហេតុផលដោយផ្ទាល់មាត់

១- ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនត្រូវធ្វើជាសាធារណៈឡើយ ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដោយធ្វើជាសាធារណៈ ឬ អាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បានដែរ ។

**មាត្រា ១៧.-** វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ ។

២-ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដោយយកមូលហេតុផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) នៃក្រមរដ្ឋប្បវេណី ហើយបើការទាមទារនេះត្រូវបានច្រានចោល ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរដែលច្រានចោលការទាមទារនោះ មានអានុភាពចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន លុះត្រាតែសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុននោះ បានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងការទាមទារនោះ ដោយយោងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

Kol

**មាត្រា ១៨.–** ការហាមមិនឱ្យដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬ សាល-ដីកាចូលជាស្ថាពរ

១- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ដើមចោទមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលស្តីពីទំនាក់ទំនងឋានៈបុគ្គលដដែល ដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការបន្ថែម ឬ ការផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារ ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

២- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ចុងចម្លើយមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលស្តីពីទំនាក់ទំនងឋានៈបុគ្គលដដែលដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការដាក់ពាក្យបណ្តឹងតបក្នុងបណ្តឹង ទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលក្រម ឬ សាលដីកាដែលបានលើកបណ្តឹងចោលដោយហេតុថាបណ្តឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់ ។

**មាត្រា ១៩.–** មរណភាពរបស់ដើមចោទ

ក្នុងករណីដែលដើមចោទនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទទួលមរណភាព នៅពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការ នោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវចប់ដោយស្វ័យប្រវត្តិ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស ។

**មាត្រា ២០.–** មរណភាពរបស់ចុងចម្លើយ

១- ក្នុងករណីដែលភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គល ត្រូវក្លាយជាចុងចម្លើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើភាគីណាមួយទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធី ដោយយកភាគីម្នាក់ទៀតនោះមកធ្វើជាចុងចម្លើយ ។ ក្នុងករណីនេះ បញ្ញត្តិនៃចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើចុងចម្លើយទាំងអស់ទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធី ដោយយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ ។

៣- ក្នុងករណីដែលចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណងលែងលះគ្នា ឬ កាត់កាល់ ទទួលមរណភាព នៅពេលដែលបណ្តឹងនេះកំពុងត្រូវបានចាត់ការបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនេះត្រូវចប់ដោយស្វ័យប្រវត្តិ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ។

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

Kol

# ជំពូកទី ៧
# ការចាត់ចែងរក្សាការពារ

**មាត្រា ២១.-** ការចាត់ចែងរក្សាការពារ

១- ក្នុងករណីដែលមានពាក្យបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចបង្គាប់ឱ្យធ្វើការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្ន ឬ ការរក្សាការពារផ្សេងទៀតដែលចាំបាច់ ដែលកំណត់ក្នុងគន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយឆន្ទានុសិទ្ធិបាន ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣២ (ស្ថាប័នចាត់ចែងរក្សាការពារជាបណ្ដោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនៃមាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្ដូរស្ថានភាព) និង មាត្រា ៥៥៩ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារស្ថានភាពពិសេស) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

# ជំពូកទី ៨
# ករណីពិសេសនៃបណ្ដឹងស្ដីពីទំនាក់ទំនងអាពាហ៍ពិពាហ៍

**មាត្រា ២២.-** សេចក្ដីសម្រេចស្ដីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍

១-ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្ដឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្ដីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ។

២-ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្ដល់តាវកាលិកផ្សេងទៀត ក្នុងសាលក្រម ឬ សាលដីកា ដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះបាន។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៨២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះការសម្រេចសេចក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ។

៤-នៅពេលដែលតុលាការធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ ។

Kol

**មាត្រា២៣.–** ដីកាសម្រេចបង្គាប់ឱ្យអនុវត្ត

១-ក្នុងករណីដែលមានបុគ្គលណាធ្វេសប្រហែសមិនអនុវត្តនូវករណីយកិច្ចដែលមានគោលបំណងឱ្យបង់ប្រាក់ ឬ ឱ្យផ្តល់តាវកាលិកនូវទ្រព្យសម្បត្តិផ្សេង ដែលកំណត់ដោយសេចក្តីសម្រេច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២២ (សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍) ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការដែលបានធ្វើការសម្រេចសេចក្តីនេះ អាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកមានករណីយកិច្ច អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យមួយតាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន ។

២- ដើម្បីបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកមានករណីយកិច្ចនោះ ។

៣- ប្រសិនបើបុគ្គលដែលត្រូវបានបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានធ្វើតាមការបង្គាប់នោះដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការដែលបានបង្គាប់ឱ្យអនុវត្តករណីយកិច្ចនោះ អាចបង្គាប់ឱ្យពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដោយដីកាសម្រេចបាន ។

៤- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

## ជំពូកទី ៩
## ករណីពិសេសនៃបណ្តឹងអំពីទំនាក់ទំនងឪពុកម្តាយ និង កូន (បុត្តភាព)

**មាត្រា ២៤.–** ភាគីនៃបណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក ជាអាទិ៍

១- ក្នុងករណីដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាពមុនកំណើតរបស់កូន ឬ ក្នុងករណីដែលជននោះបានទទួលមរណភាពក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) នៃក្រមរដ្ឋប្បវេណី ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ជនដែលត្រូវបានបំពានសិទ្ធិសន្តតិកម្មដោយសារកូននោះ ឬ ញាតិលោហិតផ្សេងទៀត ក្នុង ៣ (បី) ថ្នាក់របស់ជនដែលត្រូវបានសន្មតថាជាឪពុកអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលជនត្រូវបានសន្មតថាជាឪពុកនោះបានទទួលមរណភាព ។

២- ក្នុងករណីដែលជនដែលបានត្រូវសន្មតថាជាឪពុក បានទទួលមរណភាពក្រោយពេលបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ជនដែលអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ)ឆ្នាំ គិតពីថ្ងៃដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា

ROYAUME DU CAMBODGE
LE SECRÉTARIAT DU PALAIS ROYAL



Ksl

១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៥.-** ភាគីនៃបណ្តឹងបដិសេធបិតុភាពពីកូន ជាអាទិ៍

១- ក្នុងករណីដែលកូនបានទទួលមរណភាព ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធនូវបិតុភាព មុននឹងក្លាយជានីតិជន ឬ ដោយមិនបានដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី បច្ឆាញាតិផ្ទាល់របស់កូនដែលបានទទួលមរណភាពនោះ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។

២- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព បច្ឆាញាតិផ្ទាល់របស់កូនដែលទទួលមរណភាពនោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៦.-** ភាគីនៃបណ្តឹងទាមទារឱ្យទទួលស្គាល់ ជាអាទិ៍

១- នៅក្នុងបណ្តឹងទាមទារឱ្យទទួលស្គាល់ កូនត្រូវដាក់ពាក្យបណ្តឹង ដោយយកឪពុកមកជាចុងចម្លើយ ។ ក្រោយមរណភាពរបស់ឪពុក ត្រូវយកតំណាងអយ្យការមកជាចុងចម្លើយ ។

២- ប្រសិនបើឪពុកដែលជាចុងចម្លើយ ទទួលមរណភាព នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹងទាមទារឱ្យទទួលស្គាល់នោះ តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្តឹងនោះ ។

៣- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះទទួលមរណភាព ទោះបីអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៥ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី បានកន្លងផុតក៏ដោយ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាកនិងការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ២៧.-** គោលការណ៍នៃវិធានការអន្តរកាល

១- ច្បាប់នេះត្រូវអនុវត្តចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យ បណ្តឹងត្រូវបាន



Ksl

ដាក់ក្រោយពេលដែលច្បាប់នេះត្រូវបានអនុវត្ត ។

២- ចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យបណ្តឹងត្រូវបានដាក់មុនពេលដែលច្បាប់នេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ទោះបីមានបញ្ញត្តិស្តីពីការធ្វើវិសោធនកម្មនូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ២៨._** ការមិនអនុវត្តបញ្ញត្តិស្តីពីការហាមមិនឱ្យដាក់ពាក្យបណ្តឹងក្រោយពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ

បញ្ញត្តិនៃមាត្រា ១៨ (ការហាមមិនឱ្យដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរ) នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាលក្រម ឬ សាលដីកានៃរឿងក្តីដែលពាក្យបណ្តឹងត្រូវបានដាក់មុនពេលដែលច្បាប់នេះត្រូវបានអនុវត្ត បានចូលជាស្ថាពរ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ២៩._** ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។

**មាត្រា ៣០._** អានុភាពនៃបញ្ញត្តិដែលមានភាពផ្ទុយពីច្បាប់នេះ

បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី០៤ ខែមិថុនាឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

នស/រកម.០៦១០.០០៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

**អង្គ វង្ស វឌ្ឍានា**

លេខ: ៤៤០ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible]ឌីនកេន**

13/13/12

# ប្រកាស

## ស្ដីពី

## ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ
## និងចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេច
## សេចក្ដីនិងមាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ
## និងតម្លៃកម្មវត្ថុនៃបណ្ដឹង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ២៨៥.កយ.ប្រក/០៧

# ប្រកាស

## ស្តីពី

## ប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី និង មាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង

## រដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦.ក្រ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងយុត្តិធម៌

- យោងតាមមាត្រា ៦០ មាត្រា ៦១ មាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- យោងតាមភាពចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## ស ម្រេ ច

### ប្រការ ១.- បទប្បញ្ញត្តិទូទៅ

ប្រកាសនេះ កំណត់ពីបញ្ហាដែលទាក់ទងជាមួយនឹងប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី និង មាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង បន្ថែមលើបញ្ញត្តិដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ។

### ប្រការ ២.- ពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ

ពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ ។

### ប្រការ ៣.- សកម្មភាពដែលតម្រូវឱ្យបង់ពន្ធ

ជនទាំងឡាយណាដែលមានបំណងធ្វើសកម្មភាព ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ២ ត្រូវបង់ពន្ធទៅតាមចំនួនដែលបានកំណត់សម្រាប់សកម្មភាពនីមួយៗនោះ ។

### ប្រការ ៤.- ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

ក្នុងចំណោមចំណុចដែលតម្រូវឱ្យបង់សោហ៊ុយជាប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលបានកំណត់នៅក្នុងមាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី សោហ៊ុយដែលត្រូវបង់សម្រាប់ចំណុចនីមួយៗ មានកំណត់នៅក្នុងឧបសម្ព័ន្ធ ៣ ។

### ប្រការ ៥.- មាត្រដ្ឋានក្នុងការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង

ត្រូវយកឧបសម្ព័ន្ធ ៤ មកប្រើជាមាត្រដ្ឋាន នៅក្នុងការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងការកំណត់របស់តុលាការដោយផ្អែកលើបទដ្ឋានុសិទ្ធិសមហេតុផលរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌទី ៣ មាត្រា ៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ ។

ប្រការ ៦.- អានុភាពអនុវត្ត

ប្រកាសនេះមានអានុភាពអនុវត្តចាប់ពីកាលបរិច្ឆេទដែលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុវត្ត ។/.

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

<u>ចម្លងជូន :</u>

- តុលាការគ្រប់ជាន់ថ្នាក់
  "ដើម្បីអនុវត្ត"
- មហាអយ្យការអមតុលាការកំពូល
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមតុលាការគ្រប់ខេត្ត-ក្រុង
- តុលាការយោធា
- អយ្យការអមតុលាការយោធា
- អគ្គាធិការដ្ឋានកិច្ចការតុលាការ
- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១

| | ប្រភេទនៃពាក្យសុំ ដែលតម្រូវឱ្យបង់ពន្ធ | មាត្រាយោង | តម្លៃពន្ធ ( |
|---|---|---|---|
| ១ | ពាក្យប្ដឹងជិតចិត្ត | ២៨ | ៥ ០០០ |
| ២ | ពាក្យសុំចូលរួមជួយអន្តរាគមន៍ ពាក្យសុំចូលរួមអន្តរាគមន៍ក្នុងសហបណ្ដឹង | ៤៣ ៤៩ | ៥ ០០០ |
| ៣ | ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្ដឹង | ១៦៤ កថាខណ្ឌ ២ | ៥ ០០០ |
| ៤ | ពាក្យប្ដឹងទាស់ | ២០៤ | ៥ ០០០ |
| ៥ | ពាក្យប្ដឹងជំទាស់ | ៣០១ | ៥ ០០០ |
| ៦ | ពាក្យសុំតវ៉ាចំពោះការអនុវត្ត | ៣៨៤ | ៥ ០០០ |
| ៧ | ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករ | ៣៥៣ | ៥ ០០០ |
| ៨ | ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត | ៣៦២ | ៥ ០០០ |
| ៩ | ពាក្យសុំឱ្យផ្អាក និង ការលុបចោលការអនុវត្តដោយបង្ខំ | ៣៧០ | ៥ ០០០ |
| ១០ | ពាក្យសុំឱ្យដីកាសម្រេចបង្គាប់ឱ្យប្រគល់ | ៣៩០ ៤៥០ ៤៥៩ ៤៨៣ | ៥ ០០០ |
| ១១ | ពាក្យសុំទាមទារឱ្យចែកចំណែក | ៣៩៤ ៤០៩ ៤២៦ | ៥ ០០០ |
| ១២ | ពាក្យសុំការចាត់ចែងការរក្សាការពារ | ៤២៩ | ៥ ០០០ |
| ១៣ | ពាក្យសុំឱ្យលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា | ៤៦១ | ៥ ០០០ |
| ១៤ | ពាក្យសុំការអនុញ្ញាតឱ្យនាវាធ្វើដំណើរ | ៤៦២ | ៥ ០០០ |
| ១៥ | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ | ៥៥០ | ៥ ០០០ |
| ១៦ | ពាក្យសុំឱ្យផ្អាកការអនុវត្តរក្សាការពារ | ៥៥១ | ៥ ០០០ |
| ១៧ | ពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ | ៥៥៧ ៥៥៨ ៥៥៩ | ៥ ០០០ |

ឧបសម្ព័ន្ធ ២

| | សកម្មភាពដែលតម្រូវឱ្យបង់ពន្ធ | មាត្រាយោង | តម្លៃពន្ធ (រៀល) |
|---|---|---|---|
| (១) | ការទាមទារមើល ឬការទាមទារថតចម្លងសំណុំរឿង ។ ប៉ុន្តែក្នុងករណី ដែលភាគីទាមទារនៅពេលដែលរឿងក្ដីកំពុងចាត់ការមិនតម្រូវឱ្យបង់ទេ ។ ចំពោះការចំណាយក្នុងការថតចម្លងឯកសារសំណុំរឿង ជាបន្ទុករបស់អ្នកទាមទារ ។ | មាត្រា ២៥៨ ៣៧៨ ៥៣៨ | ៥ ០០០ ក្នុងមួយ |

| | | | |
|---|---|---|---|
| ២ | ការប្រគល់ឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង | មាត្រា ២៥៨ ៣៧៨ ៥៣៨ | ៥ ០០០ ក្នុងឯកសា[illegible] មួយឈុត |
| ៣ | ការប្រគល់នូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេច | មាត្រា ២៥៨ ៣៧៨ និង ៣៥៥ កថាខណ្ឌ ២ ជាអាទិ៍ | ៥ ០០០ ក្នុងឯកសា មួយឈុត |
| ៤ | ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត | មាត្រា ៣៥៥ ជាអាទិ៍ | ៥ ០០០ |

IV POLY
Attorney-At-Law

## ឧបសម្ព័ន្ធ ៣

| | ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធដាក់ពាក្យសុំ | ចំនួនសោហ៊ុយក្នុងមួយថ្ងៃ/យប់ (រៀល) |
|---|---|---|
| ១ | សោហ៊ុយធ្វើដំណើរសម្រាប់ចៅក្រម | ៨៦.០០០ រៀល + ថ្លៃធ្វើដំណើរជាមធ្យម តាម មធ្យោបាយធ្វើដំណើរសាធារណៈ ឆ្ពោះទៅកាន់គោលដៅ |
| ២ | សោហ៊ុយធ្វើដំណើរសម្រាប់ក្រឡាបញ្ជី | ២៣.០០០ រៀល + ថ្លៃធ្វើដំណើរជាមធ្យម តាមមធ្យោបាយធ្វើដំណើរសាធារណៈ ឆ្ពោះទៅកាន់គោលដៅ |
| ៣ | សោហ៊ុយស្នាក់នៅសម្រាប់ចៅក្រម | ៨០.០០០ រៀល |
| ៤ | សោហ៊ុយស្នាក់នៅសម្រាប់ក្រឡាបញ្ជី | ៤០.០០០ រៀល |
| ៥ | សោហ៊ុយបញ្ជូនឯកសារតាមលិខិតអនុសិដ្ឋ | ចំនួនដូចគ្នានឹងថ្លៃចំណាយក្នុងការបញ្ជូនឯកសារជាសំបុត្រអនុសិដ្ឋ ដោយមានរបាយការណ៍បញ្ជាក់ការដល់នៃភណ្ឌិការ (កញ្ចប់ផ្ញើតាមប្រៃសណីយ៍) |

កំណត់សំគាល់ : សោហ៊ុយស្នាក់នៅអាចផ្តល់ជូន តែក្នុងករណីដែលចំងាយធ្វើដំណើរលើសពី ៤០ គីឡូម៉ែត្រ ប៉ុណ្ណោះ លើកលែងតែ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និង ខេត្តបន្ទាយមានជ័យ ដែលសោហ៊ុយស្នាក់នៅអាចផ្តល់ជូន ក្នុងករណីដែលចំងាយធ្វើដំណើរលើសពី ៣០ គីឡូម៉ែត្រ ។

## ឧបសម្ព័ន្ធ ៤

កំណត់សំគាល់ : ចំពោះរាល់ការគណនាតម្លៃនៃវត្ថុត្រូវធ្វើឡើងដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង ។ សេចក្តីបញ្ជាក់ដំបូងអាចធ្វើឡើងដោយការបង្ហាញបង្កាន់ដៃ ឬដោយឯកសារកិច្ចសន្យា ជាអាទិ៍ ។ នៅក្នុងករណី ដែលពុំអាចរកឯកសារទាំងនោះបានទេ តម្លៃនៃវត្ថុត្រូវកំណត់តាមសេចក្តីបញ្ជាក់ដំបូងរបស់ដើមចោទ ។

### តារាងគណនាតម្លៃកម្មវត្ថុនៃបណ្តឹង

| | ប្រភេទនៃបណ្តឹង | វិធីគណនា | សេចក្តីយោង |
|---|---|---|---|
| | បណ្តឹងទាមទារអោយបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត | | |
| ១ | សិទ្ធិលើកម្មសិទ្ធិ និង ភោគៈ | តម្លៃសរុបនៃវត្ថុ | |
| ២ | សិទ្ធិកាន់កាប់ | ១/៣ នៃតម្លៃវត្ថុ | |
| ៣ | សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ | ១. ១/២ នៃតម្លៃវត្ថុដែលជាកម្មវត្ថុ<br>២. ចំពោះសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុដែលពាក់ព័ន្ធត្រឹមផ្នែកដែលសិទ្ធិអាស្រ័យនៅត្រូវបានទទួលស្គាល់ | |
| ៤ | សេវភាព | ១/៣ នៃតម្លៃ ដីបម្រើ ឬ ដីប្រើ | ការជ្រើសរើសយកតម្លៃដីប្រើ ឬតម្លៃដីបម្រើ ដើម្បីធ្វើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងគឺ |

| | | | |
|---|---|---|---|
| | | | អាស្រ័យលើដើមចោទ ។ |
| ៥ | សិទ្ធិប្រាតិភោគប្រត្យក្ស | ចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។ ប្រសិនបើសិទ្ធិលើបំណុល ដែលត្រូវបានធានា មានតម្លៃលើសពីតម្លៃវត្ថុដែលដាក់ ដើម្បីធានាកាតព្វកិច្ច គឺត្រូវយកតម្លៃវត្ថុនោះ ។ | ១. ចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវតែពោនាទៅតាមចំនួននៃប្រាក់ដើម ។<br>២. ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែតដែលមិនទាន់បានកំណត់ជាស្ថាពរ និងការបញ្ចាំដើម្បីធានាបំណុលអណ្ដែត ត្រូវយកចំនួនអតិបរមាមកធ្វើជាមូលដ្ឋាន ។<br>៣. ចំនួននៃសិទ្ធិលើបំណុលត្រូវសម្រេច ទៅតាមការចុះបញ្ជី ឬ តាមកិច្ចសន្យា ។<br>៤. បើទោះជាមានប្រាតិភោគមួយផ្សេងទៀតមានអត្ថិភាពមុនក៏ដោយ ក៏ចំនួននៃតម្លៃមិនប្រែប្រួលដែរ ។ |
| ៦ | ទំហំនៃអានុភាពហ៊ីប៉ូតែក ( ម.៨៤៦ នៃក្រមរដ្ឋប្បវេណី) | តម្លៃនៃវត្ថុភ្ជាប់ | |
| ៧ | សិទ្ធិប្រត្យក្សដែលបង្កើតឡើងដោយច្បាប់ដោយឡែក | -ករណីដែលអាចធ្វើអនុប្បទានបាន ត្រូវយកតម្លៃនៃផលប្រយោជន៍ដែលបានមកពីអនុប្បទាន<br>-ករណីដែលមិនអាចធ្វើអនុប្បទានទេ ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល | |

| | | | |
|---|---|---|---|
| | ជាអាទិ៍ | ភតិសន្យា ឬការបញ្ចប់កិច្ចសន្យា ត្រូវយក ១/២ នៃតម្លៃវត្ថុ។<br>- បើផ្អែកទៅលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ។ | កាន់កាប់ត្រូវចាត់ទុកថាជាកម្មសិទ្ធិករចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។ |
| ៤ | ការទាមទារឱ្យបញ្ឈប់ ឬបង្ការជាមុននូវការរារាំងការអនុវត្តសិទ្ធិ | - បើផ្អែកទៅលើកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុ។<br>- បើផ្អែកទៅលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ | ភោគីនៃអចលនវត្ថុដែលមានបណ្ណសំគាល់សិទ្ធិកាន់កាប់ត្រូវចាត់ទុកថាជាកម្មសិទ្ធិករចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស។ |
| ៥ | ការប្រគល់ឯកសារដែលត្រូវប្រើប្រាស់ជាមធ្យោបាយបញ្ជាក់<br>2014 1981 66 | ថ្លៃចាំបាច់ដើម្បីចេញឯកសារម្តងទៀត ឬសម្រាប់ធ្វើឯកសារម្តងទៀត។<br>2012 . 2013 2014 2015 . 2016 - 2017<br>62 63 64 65 66 68 | ១. ក្នុងករណីដែលឯកសារធ្វើដោយបុគ្គលឯកជន ត្រូវយកថ្លៃសម្រាប់ចេញឯកសារថ្មី<br>២. សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងតាមរយៈលិខិតបញ្ជាក់ដែលចេញដោយតតិយជន។ ក្នុងករណីដែលមានការលំបាកក្នុងការធ្វើឯកសារនេះ សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយការបង្ហាញ សេចក្តីបញ្ជាក់ដំបូងរបស់ដើមចោទ។ |
| ៦ | ការប្រគល់លិខិតសិទ្ធិប្រទាន | ១.ក្នុងករណីដែលការទាមទារផ្អែកទៅលើកម្មសិទ្ធិ ឬ ការបញ្ចប់កិច្ចសន្យា ត្រូវយក ១/២ នៃតម្លៃនៃសិទ្ធិដែលមានចែងនៅក្នុងលិខិតសិទ្ធិប្រទាន។<br>២. ក្នុងករណីដែលការទាមទារផ្អែកទៅលើសិទ្ធិកាន់កាប់ត្រូវយក ១/៣ នៃតម្លៃសិទ្ធិ ដែលមានចែងនៅក្នុងលិខិតសិទ្ធិ | ចំពោះការធ្វើសេចក្តីបញ្ជាក់ដំបូង តុលាការ ត្រូវបង្គាប់ឱ្យភាគីដាក់នូវលិខិតបញ្ជាក់ ទៅតាមលក្ខណៈនៃរឿងក្តី។ ប្រសិនបើការដាក់ លិខិតបញ្ជាក់មានការលំបាក សេចក្តីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយការបង្ហាញសេចក្តីបញ្ជាក់ដំបូង |

| | | ប្រទាន ។ | របស់ដើមចោទ ។ |
|---|---|---|---|
| ៧ | ការប្រគល់ឯកសារក្រៅពីឯកសារដែលត្រូវប្រើដើម្បីជាមធ្យោបាយបញ្ជាក់ | ១. ក្នុងករណីដែលការទាមទារផ្អែកលើកម្មសិទ្ធិ ត្រូវយក ១/២ នៃតម្លៃឯកសារ ។<br>២. ក្នុងករណីដែលការទាមទារផ្អែកទៅលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃឯកសារ ។ | ១.សេចក្ដីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយបង្ហាញលិខិតបញ្ជាក់ដែលចេញដោយតតិយជន ប្រសិនបើលិខិតនោះ មានតម្លៃទីផ្សា ។<br>២. ប្រសិនបើមានការលំបាកក្នុងការធ្វើឯកសារដែលចេញដោយតតិយជន ឬប្រសិនបើមិនមានតម្លៃទីផ្សាទេ ត្រូវយកតម្លៃដែលដើមចោទបានធ្វើសេចក្ដីបញ្ជាក់ដំបូង ។ |
| ៨ | ការទាមទារឱ្យផ្សព្វផ្សាយសេចក្ដីសុំអភ័យទោសជាសាធារណៈ ( ម. ៧៥៧ នៃក្រមរដ្ឋប្បវេណី) | ១. ក្នុងករណីដែលសេចក្ដីសុំអភ័យទោសត្រូវចុះផ្សាយតាមរយៈសារព័ត៌មាន ឬទស្សនាវដ្ដី ត្រូវយកតម្លៃចុះផ្សាយ ។<br>២. ក្នុងករណីដែលសេចក្ដីសុំអភ័យទោសត្រូវផ្សព្វផ្សាយតាមរយៈបញ្ជូនដំណឹង ឬ មធ្យោបាយផ្សព្វផ្សាយផ្ទៃក្នុង ត្រូវយកតម្លៃសុំជូនដំណឹង ។ | ១.សេចក្ដីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយតារាងវាយតម្លៃ ឬដោយលិខិតបញ្ជាក់ ប្រសិនបើមានការកំណត់ថ្លៃចុះផ្សាយរួចហើយ ។<br>២. ប្រសិនបើពុំមានការកំណត់ថ្លៃចុះផ្សាយទេ ត្រូវយកចំនួនទឹកប្រាក់នៃការចំណាយលើការផ្សព្វផ្សាយសេចក្ដីសុំអភ័យទោសជាសាធារណៈ ដែលដើមចោទបានអះអាងដោយការធ្វើសេចក្ដីបញ្ជាក់ដំបូង ។ |
| ៩ | ការទាមទារប្រើដីដែលជាប់គ្នា ( ម. ១៤៣ នៃក្រមរដ្ឋប្បវេណី) | ១/៣ នៃតម្លៃដីជាប់គ្នាដែលដើមចោទស្នើសុំប្រើ ។ | |

| | | | |
|---|---|---|---|
| | របស់ភតិបតី ( ម. ៦០៣ នៃក្រមរដ្ឋប្បវេណី) | | តាមរយៈវិក័យប័ត្រ នៃការប៉ាន់ប្រមាណ ។ |
| ១៦ | ការទាមទារឱ្យហាមកុំឱ្យចូល | -បើផ្អែកទៅលើសិទ្ធិប្រត្យក្សក្រៅពីសិទ្ធិកាន់កាប់ ត្រូវយក ១/២ នៃតម្លៃអចលនវត្ថុដែលជាកម្មវត្ថុ ។<br>-ប្រសិនបើផ្អែកលើសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃអចលនវត្ថុ ដែលជាកម្មវត្ថុ ។<br>-ប្រសិនបើផ្អែកទៅលើសិទ្ធិផ្សេងទៀតក្រៅពីសិទ្ធិទាំងពីរខាងលើ ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល ។ | |
| | ការចុះបញ្ជីដីធ្លី | | |
| ១ | ការផ្ទេរកម្មសិទ្ធិ | តម្លៃនៃដី | |
| ២ | ការចុះបញ្ជី ការធ្វើអនុប្បទាន ឬ ការលុបចោលនូវការចុះបញ្ជីចំពោះការជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ | ១/២ នៃតម្លៃដី ។ | |
| ៣ | ការចុះបញ្ជី ឬ ការរំលត់សេវភាព | ១/៣ នៃតម្លៃដីបម្រើ ឬ នៃតម្លៃនៃដីប្រើ ។ | ការជ្រើសរើសយកតម្លៃនៃដីបម្រើ ឬ ដីប្រើដើម្បីធ្វើការគណនាតម្លៃកម្មវត្ថុនៃបណ្តឹងគឺអាស្រ័យទៅលើដើមចោទ ។ |

| | | | |
|---|---|---|---|
| ៤ | ការចុះបញ្ជីសិទ្ធិប្រាតិភោគ | តម្លៃនៃសិទ្ធិលើបំណុល ដែលមានប្រាតិភោគ ។ ប្រសិនបើដីមានតម្លៃទាបជាងសិទ្ធិលើបំណុល គឺត្រូវយកតម្លៃ ដី ។ | តម្លៃនៃសិទ្ធិលើបំណុល ត្រូវគណនាដោយផ្អែកតែលើប្រាក់ដើមប៉ុណ្ណោះ ។ |
| | ញាតិ ឬ សន្តតិកម្ម | | |
| ១ | រឿងក្តីដែលពាក់ព័ន្ធនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនង ឪពុក-ម្តាយ និង កូន | ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល ។ | |
| ២ | ការទាមទារនូវសំណងដែលភ្ជាប់ទៅនឹងបណ្តឹងក្នុងចំណុច ១ | ចំនួនដែលខ្ពស់ជាងគេ ដែលអាចជា ៥.៥០០.០០០ រៀល ឬចំនួននៃប្រាក់សំណង ។ | |
| ៣ | ពាក្យសុំឱ្យបែងចែកទ្រព្យសម្បត្តិ ឬ ការកំណត់ការចាត់ចែងទាក់ទងទៅនឹងការបីបាច់ថែរក្សាកូន ដែលដាក់បញ្ចូលរួមគ្នា នៅក្នុងបណ្តឹងសុំលែងលះ ឬ សុំមោឃៈភាពអាពាហ៍ពិពាហ៍ | មិនតម្រូវឱ្យបង់ពន្ធទេ ។ | |
| ៤ | ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម (ម. ១៣០១ នៃក្រមរដ្ឋប្បវេណី) | -បើជាសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃនៃវត្ថុទាំងមូល ។<br>-បើជាសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ ។<br>-បើជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃ | |

| | | | |
|---|---|---|---|
| ៤ | ការចុះបញ្ជីសិទ្ធិប្រាតិភោគ | តម្លៃនៃសិទ្ធិលើបំណុល ដែលមានប្រាតិភោគ ។ ប្រសិនបើដីមានតម្លៃទាបជាងសិទ្ធិលើបំណុល គឺត្រូវយកតម្លៃ ដី ។ | តម្លៃនៃសិទ្ធិលើបំណុល ត្រូវគណនាដោយផ្អែកតែលើប្រាក់ដើមប៉ុណ្ណោះ ។ |
| | ញាតិ ឬ សន្តតិកម្ម | | |
| ១ | រឿងក្តីដែលពាក់ព័ន្ធនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និង ទំនាក់ទំនង ឪពុក-ម្តាយ និង កូន | ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល ។ | |
| ២ | ការទាមទារនូវសំណងដែលភ្ជាប់ទៅនឹងបណ្តឹងក្នុងចំណុច ១ | ចំនួនដែលខ្ពស់ជាងគេ ដែលអាចជា ៥.៥០០.០០០ រៀល ឬ ចំនួននៃប្រាក់សំណង ។ | |
| ៣ | ពាក្យសុំឱ្យបែងចែកទ្រព្យសម្បត្តិ ឬ ការកំណត់ការចាត់ចែងទាក់ទងទៅនឹងការបីបាច់ថែរក្សាកូន ដែលដាក់បញ្ចូលរួមគ្នា នៅក្នុងបណ្តឹងសុំលែងលះ ឬ សុំមោឃៈភាពអាពាហ៍ពិពាហ៍ | មិនតម្រូវឱ្យបង់ពន្ធទេ ។ | |
| ៤ | ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម (ម. ១៣០១ នៃក្រមរដ្ឋប្បវេណី) | -បើជាសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃនៃវត្ថុទាំងមូល ។<br>-បើជាសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុ ។<br>-បើជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃ | |

១

| | | | |
|---|---|---|---|
| | | តម្លៃសរុបនៃមរតក × ៥% × អំឡុងពេលហាមឃាត់ × ចំណែកតាមច្បាប់របស់ដើមចោទ ។<br>៥. ចំពោះការកំណត់នូវវិធីកាត់បន្ថយអច្ច័យទាន ( មាត្រា ១២៣៧ ចំណុច ៤) គឺ ចំនួននៃទ្រព្យដែលបានកាត់បន្ថយដោយផ្អែកលើវិធីដែលបានកំណត់-ចំនួននៃទ្រព្យដែលបានបន្ថយដោយ ផ្អែកលើបញ្ញត្តិស្តីពីការកាត់បន្ថយអច្ច័យទាន ( មាត្រា ១២៣៧) ។<br>៦. ចំពោះសិទ្ធិដែលមិនទាក់ទងទៅនឹងទ្រព្យសម្បត្តិ ដូចជាការទាមទារឱ្យទទួលស្គាល់ បញ្ហាដែលទាក់ទងទៅនឹងអាណាព្យាបាលទូទៅ បញ្ហាការប្រគល់អាណត្តិឱ្យតតិយជនកំណត់ពីវិធីបែងចែក ( មាត្រា ១១៨៣) ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍ ( មាត្រា ១១៨៦) ត្រូវចាត់ទុកថាមានចំនួន ៥.៥០០.០០០ រៀល ។ | |
| ៦ | ការទាមទារឱ្យបញ្ជាក់ពីមោឃៈភាពនៃការបោះបង់សន្តតិកម្ម | តម្លៃសរុបនៃមរតក × ចំណែកមតិកតាមច្បាប់របស់ដើមចោទ | |
| ៧ | ការទាមទារឱ្យបញ្ជាក់ពីមោឃៈភាពនៃកិច្ចសន្យាបែងចែកមរតក | តម្លៃសរុបនៃសន្តតិកម្ម × ចំណែកតាមច្បាប់ របស់ដើមចោទ<br>- ចំណែករបស់ដើមចោទដែលមានចែងនៅក្នុងកិច្ចសន្យាបែងចែកមរតក | |

| | | | |
|---|---|---|---|
| ៨ | ការទាមទារឱ្យបង្រួបំភាគបម្រុង | ១.ការទាមទារឱ្យសងជាប្រាក់ : ចំនួនទនៃទឹកប្រាក់ដែលដើរបណ្តឹងទាមទារឱ្យសង ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ :<br>-ចំពោះសិទ្ធិលើកម្មសិទ្ធិ : ត្រូវយកតម្លៃសរុបនៃវត្ថុ ។<br>-ចំពោះសិទ្ធិកាន់កាប់ : ត្រូវយក ១/៣ នៃតម្លៃវត្ថុ ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ : ត្រូវយក ១/២ នៃតម្លៃវត្ថុ ។<br>-ចំពោះសេវភាព : ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើដោយផ្អែកទៅលើចំណែកមតិក<br>៣. ការចុះបញ្ជីដីធ្លី : ត្រូវយកតម្លៃដីធ្លីនោះ ។ | |
| | **ការអនុវត្តដោយបង្ខំ** | | |
| ១ | បណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត ( ម. ៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) | ១/២ នៃតម្លៃដែលទាមទារនៅក្នុងលិខិតអនុវត្ត ។ | ប្រសិនបើការទាមទារនៅក្នុងលិខិតអនុវត្តនោះមានកម្មវត្ថុជា :<br>១.ការទាមទារឱ្យសងជាប្រាក់ ត្រូវយកចំនួននៃទឹកប្រាក់ដែលដើមចោទទាមទារឱ្យសងមកគិត ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ : |

| | | | |
|---|---|---|---|
| | | | -ចំពោះសិទ្ធិកម្មសិទ្ធិ ត្រូវយកតម្លៃសរុបនៃវត្ថុមកគិត ។<br>-ចំពោះសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើមកគិត ដោយផ្អែកទៅលើចំណែកមតិក ។<br>៣. ការចុះបញ្ជីដីធ្លី ត្រូវយកតម្លៃដីធ្លីនោះមកគិត ។ |
| ២ | បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ( ម: ៣៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) | ១/២ នៃតម្លៃនៃការទាមទារនៅក្នុងលិខិតអនុវត្ត ។ | ប្រសិនបើការទាមទារនៅក្នុងលិខិតអនុវត្តនោះមានកម្មវត្ថុជា :<br>១.ការទាមទារឱ្យសងជាប្រាក់ ត្រូវយកចំនួននៃទឹកប្រាក់ដែលដើមចោទទាមទារឱ្យសងមកគិត ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ :<br>-ចំពោះសិទ្ធិកម្មសិទ្ធិ ត្រូវយកតម្លៃសរុបនៃ |

| | | | |
|---|---|---|---|
| | | | វត្ថុមកគិត ។<br>-ចំពោះសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើមកគិត ដោយផ្អែកទៅលើចំណែកមតិក ។<br>៣. ការចុះបញ្ជីដីធ្លី ត្រូវយកតម្លៃដីធ្លីនោះមកគិត ។ |
| ៣ | បណ្តឹងតវ៉ាចំពោះការទាមទារ<br>( ម.៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ) | ត្រូវយក ១/២ នៃតម្លៃនៃការទាមទារនៅក្នុងលិខិតអនុវត្តលើកលែង តែក្នុងករណីដូចខាងក្រោម :<br>១.ករណីដែលមានគោលបំណងទាមទារឱ្យលុបចោលការអនុវត្តជាក់ស្តែង គឺត្រូវយកវត្ថុដែលបានរឹបអូសមកគិត ។<br>២.ករណីដែលមានគោលបំណងទាមទារឱ្យលុបចោលការអនុវត្តដោយផ្អែកលើលិខិតអនុវត្ត ចំពោះការទាមទារដែលតំរូវឱ្យអនុវត្តតាវកាលិកជាបន្តបន្ទាប់ និងច្រើនដងតាមពេល ហើយ | ប្រសិនបើការទាមទារនៅក្នុងលិខិតអនុវត្តនោះមានកម្មវត្ថុជា :<br>១.ការទាមទារឱ្យសងជាប្រាក់ ត្រូវយកចំនួននៃទឹកប្រាក់ដែលដើមចោទទាមទារឱ្យសងមកគិត ។<br>២. ការទាមទារឱ្យប្រគល់វត្ថុ :<br>-ចំពោះសិទ្ធិលើកម្មសិទ្ធិ ត្រូវយកតម្លៃសរុបនៃវត្ថុមកគិត ។ |

| | | | |
|---|---|---|---|
| | | ប្រសិនបើបណ្តឹងនោះ ផ្អែកទៅលើសំអាងហេតុថា សិទ្ធិលើបំណុលមិនមានអត្ថិភាព ឬ មិនបានកើតឡើងទេ គឺយកចំនួននៃការទាមទារចាប់ពីពេល នៃការកើតឡើងនូវសិទ្ធិលើបំណុលរហូតដល់រយៈពេល ១២ ខែក្រោយពីដាក់ពាក្យបណ្តឹង។<br>៣. ប្រសិនបើបណ្តឹងនោះមានគោលបំណងត្រឹមតែទាមទារឱ្យបញ្ឈប់ជាបណ្តោះអាសន្ននូវអានុភាពអនុវត្តបណ្តោះទេ តម្លៃកម្មវត្ថុនៃបណ្តឹងត្រូវគណនាដូចខាងក្រោម :<br>ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនៅក្នុងលិខិតអនុវត្ត × អំឡុងពេលដែលដើមចោទទាមទារឱ្យបញ្ឈប់ × (៥%/ឆ្នាំ) | -ចំពោះសិទ្ធិកាន់កាប់ ត្រូវយក ១/៣ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ ត្រូវយក ១/២ នៃតម្លៃវត្ថុមកគិត ។<br>-ចំពោះសេវភាព ត្រូវយក ១/៣ នៃតម្លៃដីប្រើ ឬ ដីបម្រើមកគិត ដោយផ្អែកទៅលើគំរោងមកគិត ។<br>៣. ការចុះបញ្ជីដីធ្លី ត្រូវយកតម្លៃដីធ្លីនោះមកគិត ។ |
| ៤ | បណ្តឹងតវ៉ារបស់តតិយជន (ម. ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី) | ១. បើសិទ្ធិទប់ស្កាត់ការផ្ទេរ ឬ ការប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ជាសិទ្ធិក្រៅពីសិទ្ធិកាន់កាប់ ត្រូវយក ១/២ នៃតម្លៃវត្ថុ។<br>២. បើសិទ្ធិទប់ស្កាត់ការផ្ទេរ ឬ ការប្រគល់នូវវត្ថុដែលត្រូវអនុវត្តដែលជាសិទ្ធិកាន់កាប់ គឺ ១/៣ ត្រូវយកតម្លៃវត្ថុ។<br>៣. ប្រសិនបើបណ្តឹងតវ៉ាធ្វើឡើងចំពោះការអនុវត្តលើចលនវត្ថុដែលជាវត្ថុដែលអាចជួញដូរបាន ឬ សិទ្ធិលើបំណុលរបស់តតិយជន គឺ យកតម្លៃ នៃវត្ថុដែលអាចជួញដូរបានដែលត្រូវបាន | តម្លៃកម្មវត្ថុយ៉ាងច្រើនបំផុតគឺត្រឹមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលកំណត់នៅក្នុងលិខិតអនុវត្ត |

| | | | |
|---|---|---|---|
| | | រឹបអូស ឬ សិទ្ធិលើបំណុលនោះ ។ | |
| ៥ | បណ្តឹងតវ៉ារបស់ម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត ដែលបានថ្លែងសេចក្តីតវ៉ា ចំពោះការសរសេរលើតារាងចែកចំណែក ( ម. ៤៩២ និង ម. ៤៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) | ១. បណ្តឹងតវ៉ាដែលធ្វើឡើងដោយម្ចាស់បំណុល : ចំនួននៃការកើនឡើងដោយការកែតម្រូវ ឬការលុបចោល និងកែប្រែនៃតារាងចែកចំណែក ។<br>២. បណ្តឹងតវ៉ាដែលធ្វើឡើងដោយកូនបំណុល : គឺចំនួនសិទ្ធិលើបំណុល ដែលបានតវ៉ា ដោយមិនគិតដល់ចំនួនដែលលើស ។ | |

16

013